00302241

E1/7.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>
# <u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”</u>

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម សួយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពេទីត *(Mr. Robert Petit)*

លោក យ៉េត ចរិយា

លោក វាលៀម ស្មីត *(Mr. William Smith)*

លោក តាន់ សេណារ៉ុង

លោក សេង ប៊ុនឃាង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ជឺហ្គិន អាស្មាន*(M.r Jurgen Assmann)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ព្យែរ អូលីវីយេ ស៊័រ

*(Mr. Pierre Olivier Sur)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក សាន់ រ៉ាដា

# កិច្ចដំណើរការនីតិវិធី

[០៩:០៨:០០]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**លោកស្រី សែ កុលវុឌ្ឍី៖**

អង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការតទៅទៀត ។ ដំណើរការសនវការកាលពីម្សិលមិញយើងបានដល់បញ្ហាមួយអំពីពីនិត្យសំណើរបស់ភាគី និងដំណោះស្រាយលើសំណើរបស់ភាគីដោយអង្គជំនុំជម្រះ ។ កាលពីម្សិលមិញអង្គជំនុំជម្រះ បានដំណើការសវនាការដល់បញ្ហានេះ តែដោយពេលវេលានៃដំណើរការសវនាការត្រូវផុត ហើយបញ្ហាសំណើនិងដំណោះស្រាយមិនទាន់បានធ្វើឲ្យបានដាច់ស្រេចនៅថ្ងៃពីម្សិលមិញ ហើយថ្ងៃនេះយើងលើកបញ្ហានេះមកបន្តទៀត ។

នៅក្នុងនោះគឺមានបញ្ហាដូចខាងក្រោម៖

ទីមួយ គឺអង្គជំនុំជម្រះកត់សម្គាល់នូវសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យបង្ហាញអំពីអង្គហេតុបានព្រមព្រៀងគ្នាជាសាធារណៈនៅក្នុងសវនាការនេះ ដែលបានព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញាជាមួយនឹងមេធាវីការពារក្តី ។ បញ្ហានេះអង្គជំនុំជម្រះនឹងសួរទៅមេធាវីការពារក្តី ហើយនឹងបើមានការព្រមព្រៀងជាក់លាក់នោះ គឺអង្គជំនុំជម្រះនឹងកំណត់ការបង្ហាញជាសាធារណៈនៅក្នុងសាលសវនាការនេះអំពីអង្គហេតុព្រមព្រៀងនៅចុងម៉ោងនៅថ្ងៃនេះ ។

ទីពីរ ការពីម្សិលមិញមានការប៉ុនប៉ងដាក់នូវសំណើមួយចំនួន ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមដាក់សំណើពីម្សិលមិញនេះ ដើម្បីធ្វើការបានកាត់តែច្បាស់លាស់នៅពេលនេះ ហើយអង្គជំនុំជម្រះនឹងកត់ត្រានូវសំណើទាំងអស់នូវភាគីដែលបានលើកឡើង ដើម្បីយកទៅពិចារណា ពិភាក្សាសម្រេច ។

ជាកិច្ចបន្តគឺអង្គជំនុំជម្រះសូមសួរទៅភាគី ថាតើមានសំណូមពរអ្វីបន្ថែមទៀតទេ? ហើយនាពេលនេះសូមរំឭកដល់មេធាវីការពារក្តី តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ទីមួយគឺសូមធ្វើការតាមលំដាប់លេខរៀង គឺក្រុម១ ក្រុម២ ក្រុម៣ ក្រុម៤ ។ ទីពីរ នៅពេលដែលអស់លោក លោកស្រី នាងកញ្ញាអញ្ជើញក្រោកឈរជាដំបូងៗមុននឹងនិយាយ សូមជម្រាបប្រាប់អង្គសវនាការអំពីឈ្មោះរបស់លោក លោកស្រី និងក្រុមរបស់លោកស្រី ដែលជាតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីផង ពីព្រោះអង្គ

សវនាការ ទាំងមូលមិនបានស្គាល់អំពីឈ្មោះអស់លោក លោកស្រីទេ ។

ជាកិច្ចបន្តសូមអញ្ជើញភាគីណាដែលមានបំណងក្នុងការលើកឡើងនូវសំណូមពរផ្សេងៗបន្ថែមទៀតមកអង្គជំនុំជម្រះ ដែលដើម្បីសុំឲ្យអង្គជំនុំជម្រះពិភាក្សាដោះស្រាយនោះ ។

សូមអញ្ជើញ ។

[០៩:១២:៥៧]

**លោក អាឡាំង វ៉ែនណឺ៖**

សូមជម្រាបសួរ ខ្ញុំឈ្មោះ អាឡាំង វ៉ែនណឺ ខ្ញុំជាសហមេធាវីការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី១ ។ ខ្ញុំជាមានសំណើមួយ ដើម្បីសុំការណែនាំពីលោកប្រធាន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០៩ លោកបានចេញការណែនាំមួយទាក់ទងអំពីដីកាសម្រេចសវនាការ ហើយនៅក្នុងចំណុចទី៩ នៃការណែនាំនោះបានពន្យល់ហើយបញ្ជាក់ថា ភស្តុតាងនានានឹងត្រូវបានបែងចែកទៅជាប្រធានបទ ហើយលោកប្រធានបានចង្អុលបង្ហាញអំពីប្រធានបទ៧ ។ ដូច្នេះ ហើយបានបំភ្លឺតទៅទៀតថា នៅក្នុងប្រធានបទនីមួយៗ ទី១ អំពីនិយាយអំពីជនជាប់ចោទនឹងត្រូវសួរជនជាប់ចោទ ហើយនឹងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ បន្ទាប់មកគឺសាក្សី បន្ទាប់មកគឺអ្នកជំនាញ ចំពោះប្រធានបទនីមួយៗ ។

ដូច្នេះលោកប្រធាន ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនដែលនៅក្នុងក្រុមរបស់យើងនោះនឹងអញ្ជើញមកបង្ហាញខ្លួននៅចំពោះមុខតុលាការដើម្បីនិយាយ ហើយគេមិនមានអ្វីដើម្បីនិយាយអំពីប្រធានបទនោះទេ ។ បើសិនជាគេមាន គឺភាគច្រើននឹងនិយាយទាក់ទងទៅនឹងជាពិសេសអ្នកដែលត្រូវបានឃុំខ្លួននៅស-២១ គឺមិនទាក់ទងទៅនឹងម-១៣ នោះទេ ។ ជាពិសេសទាក់ទងទៅនឹងជនជាប់ចោទ ហើយយើងខ្ញុំនៅសូមថ្លែងអំណរគុណប្រសិនបើលោកប្រធាន បញ្ជាក់អំពីបញ្ហានេះដល់យើង ដែលថាតើពេលណាលោកប្រធាននឹងងកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីនោះ? ហើយវាសំខាន់ណាស់សម្រាប់យើងដើម្បីឲ្យយើងបានត្រៀមខ្លួន ។

ជាពិសេសមានដើមបណ្តឹងរដ្ឋប្បវេណីពីរ គឺថាអាយុ៨៦ E៨៦ ហើយ E៨៧ ហើយដែលនឹងអញ្ជើញមកតុលាការនេះ ហើយយើងសង្ឃឹមថាអាចនឹងគាត់ជម្រាបជូនលោកប្រធាន ហើយគាត់មិននៅក្នុងប្រទេសកម្ពុជាទេ អ្នកទាំងពីរនោះ ។ តាមពិតគឺគាត់ទាំងពីររស់នៅឆ្ងាយណាស់ពីនេះ ។

អ៊ីចឹង យើងត្រូវការឲ្យជូនដំណឹងគាត់ជាមុនថាពេលណាគាត់ត្រូវបង្ហាញខ្លួននៅតុលាការនេះដើម្បីឲ្យពួកគាត់ ហើយយើងអាចបំភ្លឺទៅពួកគាត់បាន ។

ទាំងអស់នោះគឺជាសេចក្តីស្នើសុំរបស់ខ្ញុំ ។ សូមអរគុណលោកប្រធាន ។

[០៩:១៥:៣៣]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំគួរតែនិយាយប្រាប់ឈ្មោះខ្ញុំគ្រប់ពេលទាំងអស់នៅពេលដែលខ្ញុំក្រោកឈរនិយាយឬក៏យ៉ាងម៉េច? ខ្ញុំសូមធ្វើការបំភ្លឺទៅលើបញ្ហានេះ ប្រហែលជាអង្គជំនុំជម្រះស្គាល់ខ្ញុំហើយ ឈ្មោះរបស់គឺ ស្ទូតហ្សីនស្គី គឺជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

ខ្ញុំសូមដាក់សំណើមួយ គឺពាក់ព័ន្ធទៅនឹងការវិសោធនកម្មនៃដីកាកំណត់សវនាការ ដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការបញ្ជូនមកយើងខ្ញុំ គឺយើងទទួលបានការជូនដំណឹងថា មេធាវីការពារក្តីនឹងធ្វើការសន្និដ្ឋាន ។ ហើយនៅថ្ងៃច័ន្ទ យើងបានដឹងថា គឺមានការចង់លើកសេចក្តីសន្និដ្ឋាន ហើយគឺជនជាប់ចោទបានធ្វើការសន្និដ្ឋានកាលពីម្សិលមិញ ។

ខ្ញុំសូមលើកឡើងនៅទីនេះអំពីការផ្តើម សេចក្តីផ្តើមខ្លីមួយ ដើមបណ្តឹងរដ្ឋប្បវេណី គឺភាគីមួយនៅក្នុងដំណើរការក្តី ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួម ថាតើមានន័យយ៉ាងម៉េចចំពោះសិទ្ធិនៅក្នុងការចូលរួម? វាមានន័យថា គឺគាត់ត្រូវតែមានវត្តមានជារូបវន្តនៅទីនេះ គឺមិនមែនថាវត្តមានទាំងអស់នៅទេ ។

សិទ្ធិនៃការចូលរួមមាន សិទ្ធិស្តាប់នូវសំឡេងរបស់យើងខ្ញុំ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្តាប់អំពីសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ហើយគាត់បានលើកឡើងកាលពីថ្ងៃច័ន្ទ និងម្សិលមិញផងដែរ ។ ធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានបំណងក្នុងការឆ្លើយតបចំពោះសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ហើយចង់ធ្វើការសម្តែងនូវការព្រួយបារម្ភ និងការយល់ឃើញរបស់ពួកគេ ។

ចំណុចនេះ គឺសម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ក្នុងការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះដែលគាត់មានសិទ្ធិក្នុងសម្តែងការយល់ឃើញរបស់គាត់នៅក្នុងតុលាការមានលក្ខណៈអន្តរជាតិនេះ ហើយគាត់ជាភាគីនៅក្នុងដំណើរការក្តី ។ ដូច្នេះ ពួកគេគួរតែទទួលសិទ្ធិក្នុងការឆ្លើយតបទៅនឹងសិទ្ធិ និងសិទ្ធិសារវន្តទាក់ទងទៅនឹងសិទ្ធិទទួលបានយុត្តិធម៌ក្នុងការថ្លែងប្រាស្រ័យ ។

[០៩:១៩:០៦]

ដូច្នេះ ខ្ញុំសូមធ្វើការទាញអារម្មណ៍អង្គជំនុំជម្រះសាលាដំបូង អំពីយុត្តិសាស្ត្ររបស់តុលាការ

ព្រហ្មទណ្ឌអន្តរជាតិ ។ នៅក្នុងរឿងក្ដី *លូបាងហ្គា* អង្គបុរេជំនុំជម្រះទី១ បានសម្រេចនៅថ្ងៃទី២២ ឆ្នាំ២០០៦ ។ ជនរងគ្រោះ គឺជាអ្នកចូលរួម ហើយមានសិទ្ធិទទួលការថ្លែងប្រាស្រ័យ ហើយនៅក្នុងគ្រប់ដំណាក់កាលទាំងអស់ នៅគ្រប់ដំណាក់កាលនីតិវិធីទាំងអស់ នេះជាចំណុចសំខាន់ ។ ប្រសិនបើ មានការពាក់ព័ន្ធនឹងផលប្រយោជន៍របស់ពួកគេ ពួកគេជាអ្នកចូលរួម ដូច្នេះពួកគេទទួលសិទ្ធិនេះ ហើយអង្គបុរេជំនុំជម្រះទី១ បានពន្យល់ពីសិទ្ធិបានចូលរួម មានន័យថានៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ មានន័យថា ជនរងគ្រោះដែលចូលរួម គឺអនុញ្ញាតឲ្យធ្វើការសន្និដ្ឋានបើក និងធ្វើការសន្និដ្ឋានបញ្ចប់ ។

ដូច្នេះហើយ ចំណុចនោះគឺអង្គបុរេជំនុំជម្រះទី១ បានបញ្ជាក់ចំពោះការយល់ឃើញរបស់អង្គបុរេជំនុំនៅទីនោះ អំពីសិទ្ធិនៃការចូលរួមថាតើវាមានន័យយ៉ាងម៉េច? ជាការពិតសិទ្ធិនៃការចូលរួមមិនត្រូវបានកម្រិតត្រឹមតែឲ្យមានវត្តមានជារូបវន្តនៅទីនេះនោះទេ ហើយវាមិនគ្រប់គ្រាន់ដែលថា គាត់ទទួលបានសិទ្ធិក្នុងការស្ដាប់ ការថ្លែងប្រាស្រ័យនៅចំណុចចុងក្រោយដែលអង្គជំនុំជម្រះនឹងអញ្ជើញភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន មិនមែនទាំងអស់នេះនោះទេ ។

ដូច្នេះហើយខ្ញុំសូមលើកឡើងថា សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគួរតែទទួលបាននូវគ្រប់ដំណាក់កាលនីតិវិធីទាំងអស់ រួមទាំងនៅថ្ងៃទី១ នៅពេលដែលជនជាប់ចោទខ្លួនឯងបានធ្វើការថ្លែងប្រាស្រ័យនៅក្នុងសេចក្ដីសន្និដ្ឋានបើក ។ ហើយគឺនៅក្នុងកាលវិភាគកំណត់របស់យើង គឺមិនមានការលើកឡើងនូវបញ្ហានៃការផ្ដល់ចំណុច ផ្ដល់យោបល់ទៅលើសេចក្ដីសន្និដ្ឋាននៅក្នុងចំណុចទី៨តែប៉ុណ្ណោះ ។

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការចាប់អារម្មណ៍ក្នុងការស្វែងរកយុត្តិធម៌ ចំពោះជនរងគ្រោះ គឺបានន័យថា ជនរងគ្រោះគួរតែអាចមានធ្វើការបង្ហាញការយល់ឃើញចំពោះការសុំទោសរបស់ជនជាប់ចោទដែលបានលើកឡើងកាលពីម្សិលមិញ ហើយជនរងគ្រោះគួរតែអាចផ្ដល់ការយល់ឃើញអំពីអ្វីដែលជនជាប់ចោទបាននិយាយកាលពីម្សិលមិញ រួមទាំងអ្វីដែលគាត់ជាជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ហើយជាផលប្រយោជន៍យុត្តិធម៌ ជនរងគ្រោះគួរតែផ្ដល់សិទ្ធិក្នុងការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់ជនជាប់ចោទ ។ ហើយជាទូទៅគឺថាគួរជនរងគ្រោះគួរតែមានសិទ្ធិជាទូទៅ ។

[០៩:២២:៣៥]

ដូច្នេះយើងខ្ញុំស្នើសុំឲ្យធ្វើការផ្ដល់សិទ្ធិក្នុងការឆ្លើយតបយ៉ាងហោចណាស់ទៅនឹងសេចក្ដីសន្និដ្ឋានបើករបស់ជនជាប់ចោទ ។ គឺមិនមែននេះ មិនមែនជាសំណើដូចដែលយើងបានដាក់កាលពីពីរអាទិត្យទៅមិញនោះទេ ដែលយើងបានដាក់ស្នើសុំសិទ្ធិធ្វើការសន្និដ្ឋានបើក ។ នេះគឺជាសំណើសុំ ដែលយើងបាន

កែប្រែមួយ ដែលយើងខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងជនជាប់ចោទ ហើយយើងខ្ញុំសូមអនុវត្តសិទ្ធិក្នុងការឆ្លើយតបទៅលើជនជាប់ចោទ ។ ដូច្នេះ ខ្ញុំស្នើសុំអង្គជំនុំជម្រះដោយគោរពឲ្យធ្វើការសម្រេចចំពោះសំណើមួយនេះ ដែលខ្ញុំបានដាក់ជូនលោកចៅក្រម ។ សូមអរគុណ លោក លោកស្រីចៅក្រម ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំមេធាវី ម៉ុច សុវណ្ណារី គឺជាមេធាវីនៅក្នុងក្រុមមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុម៣ ហើយជាដំបូងនាងខ្ញុំសូមគោរពដល់លោកប្រធានហើយនិងអង្គជំនុំជម្រះទាំងមូល ។ នាងខ្ញុំមានសំណើមួយដែលបន្ថែមទៅលើសំណើដែលមេធាវីរបស់ខាងនាងខ្ញុំបានលើកពីម្សិលមិញរួចទៅហើយ ហើយថ្ងៃនេះនាងខ្ញុំមានសំណើមួយបន្ថែមទៀត ។ នាងខ្ញុំសូមស្នើសុំដល់លោកប្រធាន ហើយនិងអង្គជំនុំជម្រះទាំងមូល សូមការណែនាំមួយពីអង្គជំនុំជម្រះទាំងមូលទាក់ទងជាមួយនឹងបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណី ។ បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះបម្រុងនឹងកោះហៅគាត់ដើម្បីនឹងស្ដាប់ចម្លើយគាត់ ជាមួយនឹងកាលវិភាគ ជាមួយនឹងកាលបរិច្ឆេទ តើថ្ងៃណាដែលដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ គាត់ត្រូវចូលរួមនៅក្នុងការស្ដាប់ចម្លើយនេះ ។ នាងខ្ញុំសូមអរគុណ ។

**លោក គង់ ពិសី៖**

ខ្ញុំបាទឈ្មោះ គង់ ពិសី ជាមេធាវីនៅក្នុងក្រុម១ ។ ខ្ញុំបាទសូមឲ្យអង្គជំនុំជម្រះមេត្តាធ្វើការសង្កេតនៅក្នុងសវនាការ ពីព្រោះថាខ្ញុំឃើញកម្មវិធីរបស់អង្គជំនុំជម្រះដាក់មក ទៅឲ្យចែកជូនទៅឲ្យអ្នកចូលរួមប្រជុំ គឺថាមានរួចហើយ ។ ក៏ប៉ុន្តែក្រោយមកទៀត គឺថានៅពេលដែលយើងធ្វើការពិភាក្សាទៅលើនៅក្នុងសវនាការនេះ គឺថាមានការជំទាស់ មានការជំទាស់អ៊ីចឹងទៅ ហើយទៅមានការតវ៉ាផ្សេងៗ ហើយទៅមានចៅក្រមចូលទៅពិភាក្សាអំពីបញ្ហាការជំទាស់ហ្នឹង ។ អ៊ីចឹងឃើញថា កម្មវិធីនេះ វាមិនស៊ីគ្នាទៅនៅក្នុងកម្មវិធី ដែលបានដាក់ជូនមកទេ អាហ្នឹងចំណុចមួយ ។

ចំណុចមួយទៀត គឺថានៅពេលដែលមេធាវី ដែលមានការធ្វើការជំទាស់ហើយហ្នឹងក៏សុំឲ្យដើមបណ្ដឹង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺថាឲ្យមានសិទ្ធិនៅក្នុងការតវ៉ានេះដែរ បាទសូមអរគុណពីរចំណុចនេះ ។

[០៩:២៦:២០]

**លោក ព្យែរ អូលីវីយេ ស័រ៖**

ខ្ញុំឈ្មោះ ព្យែរ អូលីវីយេស័រ ខ្ញុំជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៤ ហើយខ្ញុំឯក-

ភាពទាំងស្រុងជាមួយនឹងសហសេរិកខ្ញុំ ដែលនិយាយទាក់ទងអំពីការការសម្រេចកាលវិភាគសវនាការនេះ ។ ហើយយើងសូមស្នើថា យើងនឹងជួយដល់កូនក្តីរបស់យើងឱ្យបានសមស្របក្នុងដំណាក់កាលសវនាការនេះ ។ អាស្រ័យទៅលើសមភាពនៃអំណាចរវាងមេធាវីការពារ និងដើមបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍បើក ដោយជនជាប់ចោទកាលពីម្សិលមិញ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានសំណួរអ្វីផ្សេងទៀតទេ?

បើមិនមានទេ គឺអង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តី សួរថាតើការព្រមព្រៀងអង្គហេតុដែលលោកលើកឡើងពីម្សិលមិញជាមួយនឹងសហព្រះរាជអាជ្ញានោះ តើមានពិតមែនដែរឬទេ?

ទីពីរ ថាបើសិនជាមាន តើលោកអាចធ្វើការបង្ហាញជាសាធារណៈនៅក្នុងអង្គជំនុំជម្រះនេះ បានដែរឬទេ? ដោយសូមឱ្យធ្វើសង្ខេប ហើយបញ្ជាក់ថា ការធ្វើនេះ មិនមែនធ្វើឥឡូវនេះទេ គឺយើងពន្យារពេលចុងម៉ោងនៃថ្ងៃនេះ ដើម្បីទុកលទ្ធភាពនៃការរៀបចំរបស់លោក ដើម្បីដំណើរការ ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម! យើងបានជូន ជូននូវអង្គជំនុំជម្រះកាលពីម្សិលមិញនៅការព្រមព្រៀងទៅលើអង្គហេតុនានា ដែលយើងបានធ្វើការរួមជាមួយសហព្រះរាជអាជ្ញា ហើយនិងជនជាប់ចោទផងដែរ ។ ហើយឯកសារទាំងនោះ ដែលយើងបានដាក់ជូនពីម្សិលមិញនោះ អាចនឹងផ្សាយជាសាធារណៈបាន ។ អង្គជំនុំជម្រះ គឺមានទទួលបានឯកសារនេះតាំងពីម្សិលមិញ ក្រោយពីសវនាការនាថ្ងៃនោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមបំភ្លឺជំហររបស់យើងខ្ញុំ យើងចង់ឱ្យលោកបង្ហាញសេចក្តីសង្ខេបទៅលើអង្គហេតុព្រមព្រៀងរបស់លោក ដើម្បីឱ្យភាគីនិងអង្គជំនុំជម្រះបានដឹង ថាតើលោកបានរៀបចំដែលឬទេ ចំពោះសេចក្តីសង្ខេបនោះ?

[០៩:៣០:០៧]

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញនោះឯង ប្រសិនបើយើងបានផ្តល់នូវសេចក្តីសង្ខេបនោះ យើងនឹងត្រូវអានយ៉ាងណាស់គឺពីរម៉ោងដែរ ទើបអានចប់ ។ ខ្ញុំគិតថា អាចនឹង

មានការពិបាកក្នុងការគោរពតាម ។ ប្រសិនបើអង្គជំនុំជម្រះចាត់យល់ឃើញថា មានការចំបាច់សម្រាប់សាធារណៈនៃសវនាការ យើងនឹងធ្វើដូច្នោះ ។ ប៉ុន្តែ ខ្ញុំសូមជម្រាបថា វានឹងមានការចាំបាច់ក្នុងការគោរពទៅតាមទម្រង់នៃឯកសារ ដែលបានបញ្ជូនពីដំបូងដោយសហព្រះរាជអាជ្ញា ដែលថាកថាខណ្ឌនីមួយៗ មុននឹងចង្អុលបង្ហាញថា តើយើងឯកភាព ឬមិនឯកភាព ឬក៏យើងឯកភាពមួយផ្នែក ឬក៏យើងមិនជំទាស់នឹងអង្គហេតុនោះ? នឹងប្រើពេលច្រើនណាស់ ប្រសិនបើអង្គជំនុំជម្រះចង់ឱ្យយើងខ្ញុំធ្វើដូច្នោះ យើងមិនធ្វើសង្ខេបបែបនោះទេ យើងនឹងធ្វើនីមួយៗ ។

**លោក រ៉ូបឺត ពើទីត៖**

អរគុណលោកប្រធាន លោក លោកស្រីចៅក្រម អរុណសួស្តី ។ ជាការពិត ខ្ញុំគាំទ្រទៅលើយោបល់របស់មេធាវីការពារក្តី ខ្ញុំនឹងគោរពទៅតាមលោក លោកស្រីចៅក្រម ហើយយើងមិនមានលទ្ធភាព ឬក៏មិនមានប្រយោជន៍ចំពោះសាធារណជន ហើយវាមិនមានផលប្រយោជន៍ច្រើនចំពោះសាធារណជននោះទេ ដែលថាលោកអង្គជំនុំជម្រះចង់ឱ្យមានសេចក្តីសង្ខេប ដូចដែលយើងបានលើកឡើងវាក្យខណ្ឌមួយនៃដីកាដំណោះស្រាយដែលយើងផ្អែកទៅលើអង្គហេតុ ដែលព្រមព្រៀងគ្នា គឺយើងមានដាក់នៅក្នុងឯកសារជូនលោក លោកស្រីចៅក្រម ។ កថាខណ្ឌទាំងអស់នោះ គឺយើងបានបែងចែកជាអង្គហេតុផ្សេងៗ ដែលយើងបានយល់ស្របថា មេធាវីការពារក្តីបានយល់ស្រប ។

យើងបានគិតថា ការព្រមព្រៀងទៅលើអង្គហេតុទាំងអស់នោះ មានសារសំខាន់ចំពោះអង្គជំនុំជម្រះសាលាដំបូង ។ នៅពេលនេះខ្ញុំដឹងថា ប្រហែលជា-- ដើម្បីជាពេលវេលាសំខាន់ និងសន្សំពេលវេលាសម្រាប់អង្គជំនុំជម្រះ គឺយើងបានស្នើសុំថា យើងបានសុំដាក់ទៅលើអង្គហេតុសង្ខេបនោះនៅក្នុងសំណុំរឿងជាលាយលក្ខណ៍អក្សរ ។ ខ្ញុំបញ្ជាក់ថាឡើងវិញថា គឺយើងបានដាក់ជូនមេធាវីការពារក្តីក្នុងខែមករា ហើយយើងបានទទួលជាភាសាបារាំង ហើយនិងភាសាខ្មែរនៅថ្ងៃព្រហស្បតិ៍ ។

ដូច្នេះ យើងទទូចឱ្យអង្គជំនុំជម្រះ ឱ្យជ្រាបទៅលើបញ្ហាហ្នឹង ប្រសិនបើយើងអាចជួយផ្សេងៗបាននោះ គឺយើងអាចអានអង្គហេតុនេះ ដែលយើងបានព្រមព្រៀងគ្នា ហើយអង្គហេតុនេះអាចចំណាយពេលរហូតទៅដល់ពីរម៉ោង ហើយគឺយើងនឹងអាចបំភ្លឺ ថាតើជំហររបស់មេធាវីការពារក្តីយ៉ាងម៉េចទាក់ទងទៅនឹងអង្គហេតុដែលពាក់ព័ន្ធ? ហើយប្រសិនបើអង្គជំនុំជម្រះចង់ឱ្យយើងធ្វើការអានទៅលើអង្គហេតុ ដើម្បីបំភ្លឺនោះ គឺយើងសូមធ្វើការគោរពតាម ។ ហើយខ្ញុំសូមបញ្ជាក់ថា គឺនីតិវិធីរបស់យើងគឺការអាននោះ គឺថាពេលខ្លះទៅវាចំណាយពេលច្រើន ហើយវាក៏មិនអាចជាផលប្រយោជន៍ច្រើនដែរ ។

[០៩:៣៣:៥៥]

*[ពីម៉ោង០៩:៣៣:៥៧ ដល់ម៉ោង ០៩:៣៩:១៥ ចៅក្រមពិភាក្សាគ្នា]*

[០៩:៣៩:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមសួរទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិនជាមួយនឹងបញ្ហាការព្រមព្រៀងអង្គហេតុរវាងសហព្រះរាជអាជ្ញាជាមួយនឹងមេធាវីការពារក្តីនេះ ។ តើមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានយោបល់យ៉ាងម៉េចដែរ ជុំវិញបញ្ហាការព្រមព្រៀងអង្គហេតុនេះ?

អស់លោក លោកស្រី នាងកញ្ញា បានស្តាប់ហើយអម្បាញ់មិញ គឺមានការប៉ុនប៉ងមួយដើម្បីបង្ហាញជាសាធារណៈចំពោះ-- អំពីអង្គហេតុដែលបានព្រមព្រៀង ប៉ុន្តែការបង្ហាញរបស់សហព្រះរាជអាជ្ញាក៏ដូចជាសហមេធាវីការពារក្តីដែរ គឺមានហេតុផលដែលនៅក្នុងការអនុវត្ត នៅក្នុងការបង្ហាញដល់គូភាគីនេះ ។

អ៊ីចឹង គឺអង្គជំនុំជម្រះសូមសួរទី១ គឺសម្រាប់មេធាវីក្រុម១ តើមានយោបល់យ៉ាងម៉េចដែរ ពាក់ព័ន្ធនឹងបញ្ហានេះ?

សូមអញ្ជើញមេធាវីក្រុម១ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធានជាទីគោរព ។ សូមអរគុណ ។ ដែលលោកប្រធានបានសំណើ យើងមិនបានពិនិត្យឃើញអង្គហេតុដែលបានឯកភាពទេ ។ អ៊ីចឹង គឺយើងមានសំណួរថា តើយើងចង់ឲ្យអាន ឬមិនអានអង្គហេតុនេះដែរ? ប៉ុន្តែ ចំពោះក្រុមយើងខ្ញុំវិញ គឺអាស្រ័យទៅលើការសម្រេចរបស់លោកប្រធាន និងអង្គជំនុំជម្រះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវី... *(មិនឮសំឡេង)*

[០៩:៤១:០៣]

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ទ៉ី៖**

លោក លោកស្រីចៅក្រម ដូចដែលសហសេវិករបស់ខ្ញុំបានលើកឡើងយើងមិនទាន់ទទួលបានអង្គហេតុដែលបានព្រមព្រៀងគ្នានៅឡើងនោះទេ ។ ហើយថា តើយើងដំណើរការទៅយ៉ាងដូចម្តេចនោះ?

ហើយដោយសារតែវាចំណាយពេលច្រើនក្នុងការអានទៅលើអង្គហេតុព្រមព្រៀងគ្នានោះជាសាធារណៈ ។ ហើយយើងដឹងហើយថា គឺអង្គហេតុនោះគឺវាជាន់ទៅនឹងដីកាបញ្ជូនទៅជំនុំជម្រះ ។

[០៩:៤១:៣៥]

ដូច្នេះកាលពីម្សិលមិញយើងបានស្នើសុំថា អង្គហេតុព្រមព្រៀងគ្នានោះ គួរតែដាក់ចូលទៅក្នុងសំណុំរឿងទៅ ។ យើងមិនគួរៗអាន-- ការអានសេចក្តីសង្ខេបនោះ គឺមិនមែនជាគុណប្រយោជន៍នោះទេ ។ ដូច្នេះហើយគឺ-- ប្រសិនបើយើងអានជាធារណៈនោះ យើងគួរតែអានទាំងអស់ ។ ប៉ុន្តែ យើងខ្ញុំចង់ឲ្យធ្វើភ្ជាប់ទៅក្នុងសំណុំរឿងវិញ ជាជាងការអានដោយផ្ទាល់ជូនសាធារណជន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងក្រុម៣ ។

[០៩:៤២:៣១]

**លោកស្រី ម៉ាទីន ហ្សាកឃ្វីន៖**

សូមអរគុណលោកចៅក្រម លោកប្រធាន ។ ខ្ញុំសូមបញ្ជាក់ឡើងវិញថា សំណើដែលខ្ញុំបានលើកឡើងពីម្សិលមិញ គឺថានៅទីនេះទាក់ទងទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីហើយតាមពិតនោះ ខ្ញុំគិតថា នឹងប្រើពេលពីរម៉ោងដើម្បីអានអង្គហេតុនោះ ។ គឺថាគឺជាពេលតិចទេ ទាក់ទងទៅនឹងរយៈពេលនៃសវនាការទាំងមូលដែលបានកំណត់នោះ ។

ខ្ញុំគិតថា វាមានសារសំខាន់ណាស់ដែលបានស្តាប់ទៅ នៅក្នុងផ្នែកមួយដែលថា ចម្លើយសារភាពហើយនិងវិប្បដិសារីរបស់គាត់ដែលបានបញ្ជាក់នៅក្នុងអង្គហេតុ ។ គឺអង្គហេតុដែលថា បញ្ជាក់ពីពិរុទ្ធភាព ដែលថា តើអ្វីខ្លះនៅក្នុងសំណុំរឿងដែលបានឯកភាព? កន្លែងណាដែលគាត់បានជំទាស់នោះ? គឺថាមានចំណុចជាច្រើនដែលយើងដាក់បញ្ចូល ដែលថាចំណុចណាដែលគាត់ជំទាស់ គាត់មិនព្រមនោះនេះជាចំណុចសំខាន់ ។ ដូច្នោះ ហើយយើងអាចដាក់អង្គហេតុទាំងអស់នោះជាសធារណៈ ។ ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចគ្នា ដើម្បីសាធារណជនអាចតាមដានសវនាការនេះបាន ។ ដូច្នេះហើយវាមានសារសំខាន់ណាស់នៅក្នុងដីកាបញ្ជូនទៅជម្រះនោះ គឺថាអង្គហេតុសំខាន់ៗក៏ត្រូវបានដាក់ជូនក្នុងសំណុំរឿង ។ ហើយគឺថា តើអង្គហេតុទាំងអស់នោះ បានទទួលស្គាល់ព្រមទេ?

ដូច្នេះហើយ យើងនឹងសង្កត់ធ្ងន់ទៅលើធាតុផ្សំនីមួយៗណាដែលមិនមានការព្រមព្រៀង ។ ដូច្នេះយើងនឹងពិនិត្យមើលភាពសារសំខាន់ថា តើឯកភាពឬមិនឯកភាពលើចំណុចណា? នេះគឺជាចំណុច

សំខាន់ ។ ជាចំណុចចាប់ផ្តើមថាតើអង្គហេតុណាបានឯកភាព? ចំណុចណាដែលមិនការឯកភាពគ្នា ។ អ៊ីចឹងហើយគឺថា បើយើមានការលំបាកក្នុងការអនុវត្តនីតិវិធីនេះ គឺថាចំណុចដែលថាមានការជំទាស់នោះ គឺជាចំណុចសំខាន់ ប៉ុន្តែជាចំណុចតូចដែលទាក់ទងទៅនឹងចំណុចមួយចំនួនដែលបានឯកភាពនេះហើយ ។ អ៊ីចឹងហើយ ចាប់ពីចំណុចចាប់ផ្តើមទៅ តើអ្វីដែលជាអង្គហេតុមិនបានជំទាស់ទាក់ទងទៅនឹង-- ជាអង្គហេតុសំខាន់ដែលថា ទទួលស្គាល់ហើយយើងនឹងចាត់វិធានការលើអង្គហេតុទាំងអស់នេះគឺទាក់ទងទៅនឹងចំណុចសវនាការសាធារណៈ ។

ដូច្នេះហើយដើម្បីបន្តសវនាការនេះតទៅទៀតបាននោះ ហើយមួយផ្នែកគប្បីតែ-- ខ្ញុំគិតថា អាចនឹងនាំឲ្យមានការលំបាក ប្រសិនបើមិនមានការឯកភាពរវាងសាធារណជននិងអង្គជំនុំជម្រះលើអង្គហេតុនេះទេនោះ ។ សូមអរគុណ ។

[០៩:៤៤:៥៣]

**លោក ព្យែរ អូលីវីយេ ស័រ៖**

*(គ្មានការបកប្រែ)*

លោក, យើងបានចង់បង្ហាញពីមេធាវីការពារក្តីនិងជនជាប់ចោទ គឺទាក់ទងទៅនឹងគោលការណ៍នៃអង្គហេតុដែលបានយល់ស្រប ហើយជនជាប់ចោទបានធ្វើការទទួលស្គាល់ទៅលើបញ្ហាមួយចំនួន ។ ធាតុផ្សំនោះគឺវាមានសារសំខាន់ណាស់ក្នុងលក្ខណៈពិស្តារ ហើយឯកសារដែលវាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចំណុចនីមួយៗ ។ ខ្ញុំគិតថា វាមានភាពចាំបាច់ដែលយើងត្រូវបញ្ចូលនៅក្នុងសំណុំរឿង ហើយយើងគួរតែធ្វើការពិនិត្យនៅក្នុងដំណាក់កាលដែលយើងធ្វើការដេញដោល ។ ជាពិសេសនៅក្នុងដំណើរការសវនាការអង្គសេចក្តីរបស់យើង ។

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុម៤ ?

សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ។ រួចហើយ?

*អូខេ* ។ សូមអញ្ជើញលោកមេធាវីការពារក្តី ។

[០៩:៤៦:២៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព!

មេធាវីការពារក្តីលើកឡើង ខ្ញុំបានដឹងអំពីបញ្ហាដែល *ហ្សាកកាំង* បានលើកឡើងជូនយើងខ្ញុំ ដើម្បីបញ្ជាក់ចំណុចនេះឲ្យបានច្បាស់ យើងអាចអនុវត្តបញ្ហានេះក្នុងពីរវិធី គឺសហព្រះរាជអាជ្ញានឹងអានកថាខណ្ឌដែលគាត់បានស្នើចំពោះយើងខ្ញុំ ហើយនៅពេលដែលចប់កថាខណ្ឌទាំងអស់នោះ ខាងមេធាវីការពារក្តីនឹងក្រោកឈរ ហើយយើងនិយាយថា "យល់ស្រប ឬក៏យើងនឹងបញ្ជាក់អំពីយោបល់ដែលជនជាប់ចោទគាត់ចង់ផ្តល់" ហើយបន្ទាប់មក គឺវាលក្ខណៈជាក់លាក់នៅក្នុងសេចក្តីសន្និដ្ឋាននោះ ។ គឺថាចំណុចនេះនឹងលើកឡើងដោះស្រាយទៅលើបញ្ហារបស់លោក លោកស្រី *ហ្សាកកាំង* ។ ហើយនេះ គឺសំណើរបស់ខ្ញុំដែលសូមត្រូវដាក់ជូន ហើយខ្ញុំមិនដឹងថា តើសហព្រះរាជអាជ្ញាគាត់មានយោបល់ ឬក៏យ៉ាងណានោះទេ ។

[០៩:៤៧:៥៣]

**លោក រ៉ូប៊ឺត ពើទីត៖**

ហើយខ្ញុំគិតថា កាលណាយើងនិយាយកាន់តែច្រើន កាន់តែស្មុគស្មាញ ។ ដូចដែលខ្ញុំបានបញ្ជាក់ខាងដើម គឺថាអង្គហេតុភាគច្រើនត្រូវបានឯកភាពគ្នារួចហើយ ។ ហើយយើងសង្ឃឹមថានឹងមានសារ-ប្រយោជន៍ដល់អង្គជំនុំជម្រះខ្លះ ។ អង្គហេតុសំខាន់ៗខ្លះមិនបានឯកភាពគ្នារវាងយើង ឬក៏រវាងមេធាវីការពារ ។ រីឯជនជាប់ចោទខ្លួនឯងវិញគឺថា នីតិវិធីដែលបានអនុវត្តគឺ ខ្លួនឯងគាត់បានផ្តល់យោបល់ទៅលើអង្គហេតុពិសេសៗមួយចំនួននោះ ។

ឥឡូវនេះ ដោយជាក់ស្តែងគឺថាមេធាវីអាចដាក់ជូននូវឯកសារណាមួយដែលខ្លួនដាក់ជូនដោយមានយោបល់របស់ខ្លួន ហើយនិងអាចនឹងលើកមកពិភាក្សាគ្នាបាន ពីព្រោះថាជាឯកសារត្រូវធ្វើការពិភាក្សា ។ ប៉ុន្តែ ខ្ញុំមានការព្រួយបារម្ភថា ប្រសិនបើយើងត្រូវអានឲ្យចូលទៅក្នុងកំណត់ត្រាសំណុំរឿង គឺថាយើងអានមតិយោបល់ដោយជនជាប់ចោទនោះ យើងនឹងមានការពិភាក្សាដេញដោលគ្នា ។

ម្យ៉ាងវិញទៀត ខ្ញុំមានការព្រួយបារម្ភថា ប្រសិនបើជនជាប់ចោទប្រើមធ្យោបាយនេះ គឺថាដើម្បីនឹងផ្តល់សក្ខីចំពោះអង្គហេតុខ្លះនោះ វាអាចនឹងនាំទៅដល់ឲ្យមានការពិភាក្សាមួយដែលយើងនឹងមាននៅក្នុងពេលក្រោយពេលណាមួយនៅក្នុងដំណើរការនីតិវិធី នៅពេលដែលជនជាប់ចោទនឹងធ្វើមតិយោបល់ទៅលើអង្គហេតុនីមួយៗនោះ ។

ខ្ញុំសូមស្នើថា ខ្ញុំឃើញថា សំណើនោះ ហើយនិងយោបល់មកពីមេធាវីការពារនោះ ប្រហែលជាសមស្រប ប្រសិនបើដើម្បីឲ្យមានភាពប្រាកដប្រជានោះ ។ នៅក្នុងដំណាក់កាលនេះ យើងពិតជាអាន

ដើម្បីឲ្យមានការកត់ត្រាថាអ្វីដែលមានការឯកភាព ។ ហើយតាមពិតយើងនឹងអានសំណើទៅតាមប្រធានបទ ឬក៏ទាំងមូលប្រសិនជាឲ្យមេធាវីការពារនឹងលើកគោលជំហររបស់ខ្លួន ។ ហើយនៅក្នុងកំណត់ត្រាឯកសារនោះគឺច្បាស់ណាស់ដែលថា អ្វីដែលភាគនោះបានឯកភាព ថាចំណុចដែលមិនឯកភាពសម្រាប់យើងពិភាក្សានៅក្នុងដំណាក់កាលណាមួយ ចំណុចណាមួយនៅក្នុងដំណាក់កាលសវនាការលើអង្គសេចក្ដីនេះ ។

ខ្ញុំសូមអនុញ្ញាតស្នើថា ប្រហែលជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីយើងសម្រេចបាននូវការវិវឌ្ឍន៍ទៅមានការស្រុះស្រួលមតិគ្នារវាងភាគីយើងទាំងពីរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដី ។

[០៩:៥០:៥០]

**លោក ហ្រ្វង់ស្វ័រ រូ៖**

ខ្ញុំយល់ស្រប។ ដូច្នេះ យើងនឹងបង្ហាញកថាខណ្ឌដែលជនជាប់ចោទ គាត់បានយល់ព្រម ឬក៏គាត់មិនបានតវ៉ា ។ ខ្ញុំយល់ស្របទៅលើចំណុចលើកឡើងនេះ ហើយយើងមិនអានកថាខណ្ឌទាំងឡាយដែលជនជាប់ចោទគាត់ផ្ដល់យោបល់នោះទេ ។ យើងផ្ដល់តែលើកថាខណ្ឌដែលជនជាប់ចោទគាត់បានព្រមព្រៀង ឬក៏កថាខណ្ឌផ្សេងៗដែលជនជាប់ចោទមិនបានធ្វើការតវ៉ា ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដោយអង្គជំនុំជម្រះត្រូវដកខ្លួនថយទៅពិចារណា ពិភាក្សាសម្រេចអំពីហេតុផលទាំងឡាយដែលបានលើកឡើងដោយភាគីនេះផង ហើយក៏ដល់ពេលដែលត្រូវសម្រាកផង ។ អ៊ីចឹង អង្គជំនុំជម្រះសូមប្រកាសសម្រាកកន្លះម៉ោង ។ សូមដកខ្លួនថយទៅពិចារណាផង ។

*[សវនាការសម្រាកនៅម៉ោង០៩:៥២:០៦នាទី ដល់ម៉ោង១០:៣៤:៣០នាទី]*

[១០:៣៤:៣១]

**លោកស្រី សែ កុលវុឌ្ឍី៖**

អញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការយើងតទៅទៀត ។ ជាដំបូងនេះអង្គជំនុំជម្រះសូមប្រកាសជម្រាបដល់សហព្រះរាជអាជ្ញានិងមេធាវីការពារក្តី ព្រមទាំងភាគីទាំងអស់ថា អង្គជំនុំជម្រះសម្រេចឲ្យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អាននូវអង្គហេតុដែលបានព្រមព្រៀងគ្នា និងអង្គហេតុដែលមិនមានការជំទាស់ ។ ចំណុចផ្សេងទៀត គឺទុកមួយអន្លើសិន ហើយតែសូមជម្រាបផងដែរថា ការប្រព្រឹត្តិទៅនៃការអានអំពីកិច្ចនេះ យើងនឹងប្រព្រឹត្តទៅនៅវេលារសៀល អ៊ីចឹងសូមលោកសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ត្រៀមនូវកិច្ចដែលនឹងត្រូវធ្វើនៅរសៀលនេះ ។

ជាកិច្ចបន្ត គឺអង្គជំនុំជម្រះសុំសួរទៅមេធាវីការពារក្តី លោក ការ សាវុត្ថ ដែលពីម្សិលមិញលោកបានធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងការចោទប្រកាន់ដោយសង្ខេបរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធជាមួយនឹងអំពីនីត្យានុកូលភាពនៃកិច្ចដំណើរការចោទប្រកាន់ទៅលើកូនក្តីរបស់លោក ហើយបញ្ហានេះវាមានភាពមិនច្បាស់លាស់ អំពីថាការដែលលោកលើកឡើងដូច្នេះ តើវាជាសំណើសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីដោះស្រាយលើបញ្ហានេះ មុននឹងដំណើរការដល់អង្គសេចក្តី ឬគ្រាន់តែជាការលើកឡើងឲ្យបានឮជាការបំពេញកិច្ចនៃដំណើរការតបទៅនឹងការចោទប្រកាន់តែប៉ុណ្ណោះ ។

ប្រសិនបើជាសំណើសុំជាក់លាក់នោះគឺ អង្គជំនុំជម្រះសុំឲ្យលោកមេធាវីធ្វើការចង្អុលបង្ហាញជាក់លាក់នូវចំណុចទាំងឡាយដែលមានការពាក់ព័ន្ធទៅនឹងសំណើសុំនេះ ។

សូមអញ្ជើញលោក ការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន អ្វីដែលខ្ញុំបាទបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានការពារ កាលពីម្សិលមិញនេះ ខ្ញុំបានបានចាប់ផ្តើមឡើងថា ខ្ញុំជាមេធាវីសូមលើកមតិមួយចំនួន សុំឲ្យតុលាការក៏ដូចជាអង្គសវនាការទាំងមូលធ្វើការពិចារណាតាមមតិដូចតទៅ៖

អ៊ីចឹង ខ្ញុំលើកឡើងនេះគ្រាន់តែជាមតិមួយ សូមឲ្យតុលាការយកទៅពិចារណា នេះជាទី១ ។ ទី២ ចំពោះសហព្រះរាជអាជ្ញាដែលបានសួរថា តើខ្ញុំហ្នឹងប្រឆាំងនឹងយុត្តាធិការទេ ? ថាខ្ញុំអត់បានប្រឆាំងនឹងយុត្តាធិការទេ ខ្ញុំដឹងច្បាស់ណាស់ថា បើប្រឆាំងនឹងយុត្តាធិការហ្នឹង មិនព្រមនឹងយុត្តាធិការហ្នឹង ខ្ញុំត្រូវលើកឡើងនិយាយតាំងពីនៅសវនាការបឋម ។ ខ្ញុំដឹង ក៏ប៉ុន្តែដែលខ្ញុំលើកឡើងនេះ ខ្ញុំមិនមែនប្រឆាំងនឹងយុត្តាធិការទេ គឺខ្ញុំលើកឡើងនេះចង់ឲ្យតុលាការពិចារណា ដើម្បីអនុវត្តទៅតាមវិធាន៩៨ អនុវិធាន៧

ដែលមានចែងច្បាស់លាស់ ថាបើសិនណាជា ឌុច នេះវាមិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏វាមិនមែនជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ត្រូវបំផុតនោះ អារិធាន៩៨ អនុវិធាន៧ហ្នឹង គេចែងច្បាស់លាស់ហើយ ខ្ញុំគ្រាន់តែចង់បានបញ្ជាក់តែប៉ុណ្ណឹងទេ ។

ហើយចំណុចខ្លះទៀតខ្ញុំលើកឡើងគ្រាន់តែឲ្យតុលាការពិចារណាទេ ។ ឧទាហរណ៍ ដូចជាខ្ញុំនិយាយថា ខាងសហព្រះរាជអាជ្ញាបានលើកឡើងថា ឌុច គាត់ជាឧក្រិដ្ឋកម្មសង្គ្រាម ពីព្រោះសម្លាប់ខាងវៀតណាម ខ្ញុំលើកឡើងថាសុំឲ្យតុលាការពិចារណាទៅ សង្គ្រាមបាញ់គ្នាទៅវិញទៅមក ចាប់គ្នាទៅវិញទៅមក ត្រង់វៀតណាមចាប់ខ្មែរយកទៅសម្លាប់ដូចគ្នា សុំឲ្យតុលាការពិចារណា តើវាឧក្រិដ្ឋកម្មសង្គ្រាមឬអត់? ដូច្នេះ សុំកុំឲ្យទម្លាក់ទាំងអស់ហ្នឹងមកលើកូនក្តីខ្ញុំតែម្នាក់ឯង ខ្ញុំតវ៉ាដើម្បីទាមទាររកយុត្តិធម៌ទេ ខ្ញុំមិនមែនដើម្បីបដិសេធមិនទទួលស្គាល់យុត្តាធិការទេ នេះជាចំណុចដែលខ្ញុំលើកឡើង ។

ហើយចំណុចខ្លះទៀត ដែលខ្ញុំលើកឡើង ឧទាហរណ៍ ខ្ញុំលើកឡើងថា អ្នេ ហាក់ដូចជាមិនមានមិនគោរពអធិបតេយ្យភាពរបស់ជាតិខ្មែរ ។ អានេះខ្ញុំលើកឡើងច្បាស់លាស់របស់ខ្ញុំ ពីព្រោះនៅក្នុងមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថា "ពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់" រួចតើឥឡូវស្មើភាពគ្នាហើយឬនៅ? បើ១៩៦គុក អ្នកខ្លះរួចខ្លួន អ្នកខ្លះជាប់គុក ។ ដូច្នេះកាលណាមិនគោរពអធិបតេយ្យភាពជាតិខ្មែរ មិនគោរពរដ្ឋធម្មនុញ្ញ គឺជាការបំពានលើអធិបតេយ្យភាពជាតិខ្មែរ ។ ដូច្នេះ ខ្ញុំបកស្រាយ ខ្ញុំនឹងពន្យល់តុលាការ មិនមែន ហើយសំណើររបស់ខ្ញុំ ក៏ខ្ញុំសុំស្នើដែរសុំស្នើឲ្យសហព្រះរាជអាជ្ញារៀបរាប់ឈ្មោះឲ្យអស់ ថាតើជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអ្នកដែលដឹកនាំ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យហ្នឹងមានប៉ុន្មាននាក់ ? យកមកនិយាយឲ្យអស់ឈ្មោះ ហើយអ្នកណាដែលស្លាប់ សុំឲ្យតុលាការចេញសាលក្រមរំលត់បណ្តឹងអាជ្ញា ។ ហើយចំពោះជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មមានប៉ុន្មាននាក់ លាតត្រដាងដាក់លើតុជជែកគ្នាក្នុងឋានៈជាអ្នកច្បាប់ តើអ្នកណាខុស អ្នកណាត្រូវ? មានឯកសារអីខ្លះមកសំអាង? ហើយចំពោះជនទាំងឡាយដែលបានស្លាប់បាត់បង់ជីវិតទៅ សុំឲ្យតុលាការចេញសាលក្រមដើម្បីរំលត់បណ្តឹងអាជ្ញា ។

ខ្ញុំទាមទារអីចឹង ។ ដូច្នេះខ្ញុំមិនបានប្រឆាំងនឹងយុត្តាធិការនេះទេ ។ សូមអរគុណ ។

[១០:៤១:១១]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត ពីម្សិលមិញ លោកមេធាវីការពារក្តីជនជាប់ចោទបានលើកឡើងនូវគំនិតប៉ុនប៉ងថា

នឹងលើកឡើងអំពីបញ្ហាដែលទាក់ទិននឹងការឃុំខ្លួនជាបណ្តោះអាសន្នចំពោះកូនក្តីរបស់ខ្លួនកន្លងមក អង្គជំនុំជម្រះសុំសួរទៅលោកមេធាវីការពារក្តីថា ដល់ពេលនេះ តើលោកនៅតែលើកឡើងអំពីបញ្ហានេះដែរឬទេ? ហើយគំនិតរបស់លោកដែលលើកឡើងហ្នឹងចង់ឲ្យអង្គជំនុំជម្រះធ្វើយ៉ាងដូចម្តេច អំពីបញ្ហានេះ? សូមអញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ ស្វ៊រ រ្វូះ**

សូមអរគុណលោកប្រធាន លោកចៅក្រម ។

មេធាវីការពារ បានជូនដំណឹងទៅអង្គជំនុំជម្រះកាលពីសវនាការពីដំបូងៗ ថាខ្លួននឹងលើកឡើងនូវបញ្ហាការឃុំខ្លួនបណ្តោះអាសន្ន ។ ខ្ញុំសុំអាចអនុញ្ញាតយើងហៅថា ការឃុំខ្លួនបណ្តោះអាសន្នឬទេ ? ការឃុំខ្លួនដែលបន្តដប់ឆ្នាំមកហើយនោះ គឺមិនហៅថា ជាការឃុំខ្លួនបណ្តោះអាសន្នតទៅទៀតទេ ។ ហើយតើនេះជាបញ្ហាដែលខ្ញុំចង់លើកឡើងនៅក្នុងពេលនេះ បើសិនជាខ្ញុំបានការអនុញ្ញាតនឹងធ្វើដូច្នោះ ។

ក្នុងខណៈពេលដែលយើងទទួលបានការណែនាំរំឭកនោះ*(គ្មានសំឡេង)*

សូមអរគុណលោកប្រធាន ដូចដែលយើងបានទទួលការណែនាំពីដំបូងហើយ កូនក្តីរបស់យើងខ្ញុំត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយពេលនោះគេបានចាប់ខ្លួនគាត់ដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ហើយគេបញ្ជូនគាត់ទៅឃុំខ្លួននៅក្នុងតុលាការយោធា ។ ហើយគាត់បាននៅចំពោះមុខតុលាការនោះគឺថា ជាច្រើនឆ្នាំរហូតដល់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៦ ហើយសហព្រះរាជអាជ្ញារបស់អ.វ.ត.ក ហើយបានចេញដីកានាំខ្លួនប្រឆាំងនឹងលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ហើយនៅថ្ងៃដដែលនោះឯង ត្រូវបានបញ្ជូនពីៗមន្ទីរឃុំខ្លួនរបស់តុលាការយោធាមកកាន់មន្ទីរឃុំឃាំងនៅទីនេះនៅអ.វ.ត.ក ហើយយើងភ្លាមៗនោះយើងបានស្នើថា សុំឲ្យដោះលែងគាត់ឲ្យនៅក្រៅឃុំ ហើយដោយហេតុថាគាត់បានចំណាយពេលច្រើននៅក្នុងការឃុំខ្លួន ចាប់តាំងពីពេលចាប់ខ្លួនពីដំបូងមក ។ ហើយយើងក៏ទទួលការណែនាំដែរថា អនុលោមតាមច្បាប់កម្ពុជា ប៉ុន្តែក៏អនុលោមទៅតាមច្បាប់អន្តរជាតិផងដែរ មិនអាចឃុំខ្លួនជនណាម្នាក់នៅក្នុងមន្ទីរឃុំក្នុងរយៈពេលយូរបែបនេះបានទេ ។

សហចៅក្រមស៊ើបអង្កេតបានបង្ហាញ បានចេញនូវដីកា ប្រសិនបើអនុញ្ញាតខ្ញុំនឹងធ្វើសេចក្តីសង្ខេបដែល ថាមានការបញ្ជាក់នៅក្នុងដីកានោះថា វាមានបញ្ហាមួយចំនួន ។ ប៉ុន្តែ នោះមិនមែនជាបញ្ហារបស់យើងទេគឺជាបញ្ហារបស់អាជ្ញាធរកម្ពុជា ពេលនោះយើងបានធ្វើបណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ។ ហើយនៅក្នុងការពិនិត្យឡើងវិញនោះ គឺសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសង្ខេបឡើងវិញ

ហើយបានបញ្ជាក់ថា ហើយតាមពិតវាមានបញ្ហាមួយចំនួន ប៉ុន្តែមិនមែនជាបញ្ហារបស់យើងនេះទេ ។ ហើយអង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច ដែលក្នុងសេចក្តីសម្រេចនោះដែលបានបញ្ជាក់ដែលខ្ញុំនឹងធ្វើសេចក្តីសង្ខេប ហើយយើងមិនមានបញ្ហាអ្វីនោះទេ ។ ហើយយើងនឹងដាក់បញ្ជូនបញ្ហានេះទៅអង្គជំនុំជម្រះសាលាដំបូង ហើយនៅពេលនេះយើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងហើយ ។

ដូច្នេះ តាមពិតយើងបានដឹងច្បាស់ណាស់ពីការលំបាកមួយចំនួន ដែលរាប់បញ្ចូលទាំងដើមបណ្តឹងរដ្ឋប្បវេណីជាដើមនោះ ថាតើយើងអាចនឹកឃើញពីចំណុចទាំងអស់នោះដូចម្តេចបាន នៅពេលដែលជនជាប់ចោទបានទទួលស្គាល់ នៅពេលដែលគាត់សម្តែងនូវវិប្បដិសារី ពីអារម្មណ៍របស់គាត់ដែល គាត់ស្នើសុំឲ្យមានការដោះគាត់ឲ្យនៅក្រៅឃុំនោះ ។

[១០:៤៧:៤០]

និយាយដោយសាមញ្ញ ដោយហេតុយើងមានការគោរពដោយអស់ពីដួងចិត្តចំពោះអង្គជំនុំជម្រះនេះជាពិសេសចំពោះ អ.វ.ត.ក យើងសុំស្នើក្នុងពេលនេះថា ដើម្បីបញ្ជាក់តែពីបញ្ហាអង្គច្បាប់មិនមែនអ្វីទេ នេះគឺជាលក្ខណៈច្បាប់ ។ ទោះបីជា ជាសេចក្តីសម្រេចដែលមានការលំបាក សេចក្តីសម្រេចនោះគឺថា ដែលថាវាមានបញ្ហាពិបាកក្នុងការយល់ពីទស្សនៈសាធារណៈក៏ដោយ ឬក៏ដោយជនរងគ្រោះក៏ដោយ គឺជាសេចក្តីសម្រេចមួយមុនដំបូងដែលអង្គជំនុំជម្រះគប្បីតែចេញបញ្ជាក់ឲ្យបានច្បាស់ជាសេចក្តីសម្រេច ដែលផ្អែកទៅលើអង្គច្បាប់ ហើយនិងកើតទៅជាច្បាប់ ។ ថាតើអ្វីដែលច្បាប់បានចែង?

ជាបឋមនោះ ច្បាប់របស់កម្ពុជាយើងពិនិត្យឃើញថា ហើយក៏បានមើលឃើញថា រដ្ឋធម្មនុញ្ញនៃកម្ពុជាក្នុងឆ្នាំ១៩៩៣ ហើយនិងក្រមព្រហ្មទណ្ឌនៃ *អ៊ុនតាក់* ពីឆ្នាំ១៩៩២ ហើយនឹងច្បាប់និយាយអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងឆ្នាំ១៩៩៦។ ហើយទាក់ទងទៅនឹងច្បាប់ទាំងអស់នេះហើយ ច្បាប់នោះចែងថា ជាពិសេសតាមស្មារតីនៃអង្គច្បាប់ ដែលចេញនៅខែសីហា ឆ្នាំ១៩៩៩ នៅមាត្រាទី១នោះ ច្បាប់នោះចែងថា ការឃុំខ្លួនជាបណ្តោះអាសន្ននូវបុគ្គលណាម្នាក់ នូវជនជាប់ចោទណាម្នាក់ពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម ឬក៏បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ មិនត្រូវមានរយៈពេលលើសពីបីឆ្នាំបានទេ ។ នេះមានន័យថា ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០២មក ឌុច គប្បីតែត្រូវបានដោះឲ្យមានសេរីភាព ឬក៏និយាយម៉្យាងទៀត ដោយហេតុថាតាំងពី ខែកុម្ភៈ ឆ្នាំ២០០២មក មិនមានមូលដ្ឋានច្បាប់ណាមួយ ខ្ញុំសូមបញ្ជាក់ឡើងវិញ មិនមានមូលដ្ឋានច្បាប់ណាមួយ ដែលគាំទ្រការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ទេ ។

ដូច្នេះ វាមានការចេញសេចក្តីសម្រេចសាឡើងវិញនៅក្នុងតុលាការឃោធា ឬក៏អង្គជំនុំជម្រះផ្សេងទៀតដើម្បីបន្តការឃុំខ្លួន ហើយខ្ញុំពិនិត្យឃើញថា គឺជាការពិភាក្សាដ៏ក្តៅគគុកនៅក្នុងអង្គបុរេជំនុំជម្រះ ហើយនិងលោកស្រី ជា លាង ហើយនិងមេធាវី ការ សាវុត្ថ ។ លោកស្រីសហព្រះរាជអាជ្ញាជាលាង ក៏បាននិយាយថា នឹងមិនត្រូវឲ្យនៅក្រៅឃុំបាននោះទេ ពីព្រោះវាប៉ះពាល់របៀបសន្តិសុខសាធារណៈ គឺថាដើម្បីកុំឲ្យប៉ះពាល់ទៅដល់សុវត្ថិភាពជនរងគ្រោះ ហើយខ្ញុំឯកភាពជាមួយលោកស្រីហើយ គឺថាលោកស្រីមានការភ័យខ្លាចក្នុងរយៈពេល១ឆ្នាំ ។ ប៉ុន្តែ យើងមានសេរីភាពក្នុងការភ័យខ្លាច២ឆ្នាំ យើងមានសិទ្ធិក្នុងការភ័យខ្លាចពីរឆ្នាំបីឆ្នាំ ពេលនោះ គឺថាយើងមិនអាចមានលទ្ធភាពនឹងទទួលការភ័យខ្លាចមិនឲ្យនៅក្រៅឃុំមិនបានទេ ។ រដ្ឋធម្មនុញ្ញកម្ពុជានោះគឺមានចែងថា មានតែបីឆ្នាំ បើបីឆ្នាំមួយថ្ងៃ គឺត្រូវតែនៅក្រៅឃុំ ។

[១០:៥២:៥៦]

គឺថាវាមានច្បាប់-- ច្បាប់គឺថាវាមានភាពរឹងមាំ ប៉ុន្តែច្បាប់គឺជាច្បាប់ ។ ខ្ញុំសូមបន្ថែមថា នៅក្នុងនីតិវិធីចំពោះមុខអង្គបុរេជំនុំជម្រះ លោកប្រធាន ទាក់ទងនឹងបញ្ហាឃុំខ្លួននេះ ខ្ញុំបានអញ្ជើញអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដើម្បីដាក់នូវសារណារបស់ភាគីដែលមិនមែនជាគូក្តីនោះ គឺមានបុគ្គលប្រាំមួយហើយយើងមានសារណាប្រាំមួយត្រូវបានដាក់ជូន ដែលយើងឃើញនៅក្នុងសំណុំរឿង ។ ប្រសិនបើខ្ញុំចាំច្បាស់ មិនភ្លេចនោះ គឺថានៅក្នុងចំណោមនោះ គឺថាមានអង្គការចំនួនបួនក្នុងប្រាំមួយនោះ គឺថាបានគាំទ្រគោលជំហររបស់មេធាវីការពារ ។

អនុលោមតាមច្បាប់ អនុលោមទៅតាមគោលការណ៍យុត្តិធម៌ហើយគោរពទៅតាមរូបភាព និងឧទាហរណ៍ដែលថា អង្គជំនុំជម្រះវិសាមញ្ញនេះ គឺថាត្រូវគោរពទៅតាមប្រព័ន្ធទាំងអស់ក្នុងពិភពលោកទូទាំងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជាផង ថាតើអាចអង្គការក្រៅរដ្ឋាភិបាលដែលគេចូលខ្លួនមកគាំទ្រយើងចំពោះមុខតុលាការជាតិនោះដូចម្តេចបាន ? ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញខ្លួនឯងមិនបានគោរពទៅតាមគោលការណ៍ ដែលនិយាយអំពីការឃុំខ្លួននោះ ។

ដូច្នេះ យើងសូមស្នើអង្គជំនុំជម្រះឲ្យធ្វើសេចក្តីសម្រេច យើងនឹងជួបការពិបាកមួយ ប៉ុន្តែវាលទ្ធភាពតែមួយដែលយើងត្រូវដាក់ជូនចំពោះមុខលោក លោកស្រីចៅក្រម គឺថាលើកបញ្ហាឃុំខ្លួនរបស់ឌុច នេះមកពិចារណា ពីព្រោះវាមានលក្ខណៈហួសឆ្ងាយពេកអំពីកម្រិតដែលច្បាប់កម្ពុជាបានអនុញ្ញាតហើយយើងក៏បានពិនិត្យឃើញថា វាហួសឆ្ងាយពីរយៈពេលកំណត់ដែលមានចែងនៅក្នុងលិខិតូបករណ៍

ច្បាប់អន្តរជាតិនោះដែរ ។ យើងបានយោងទៅមាត្រា១(៩) ហើយ នឹងមាត្រា១០(១៤)នៃអំពីកតិកាសញ្ញាស្តីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនោះ ហើយបានពិនិត្យឃើញថា អនុលោមតាមវិធានមាត្រាទាំងនេះ មានចែងថា គឺថាយើងមិនអាចធ្វើទៅបានទេ ក្នុងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នដែលវែងក្នុងរយៈពេលបែបនេះនោះ ។

សូមអនុញ្ញាតឲ្យខ្ញុំបញ្ជាក់ឲ្យបានច្បាស់ ដើម្បីប្រើនូវយុត្តិសាស្ត្រមួយចំនួន ដែលនិយាយអំពីមាត្រា៩ និងមាត្រា១៤ ដែលស្តីអំពីកតិកាសញ្ញាស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយនោះ ហើយខ្ញុំនឹងយោងទៅរកយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប និងមាត្រា៥នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបនោះ ចែងថា នៅក្នុងកាលៈទេសៈមួយចំនួនត្រូវបានពិនិត្យឃើញថា វាមានលក្ខណៈផ្ទុយបន្តិច ដូចដែលខ្ញុំបានបានរកឃើញពិរុទ្ធភាពដោយសារតែការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ននេះ ។ ហើយការឃុំខ្លួនបណ្តោះអាសន្នបែបនេះ ដែលខ្ញុំយោងទៅរកនោះ មិនមែនវាលក្ខណៈទូទៅដូចអ្វីដែល ឌុច បានទទួលរងនោះទេ គឺថា ដែលថាជាការឃុំខ្លួនបណ្តោះអាសន្ន គឺ១០ឆ្នាំនោះ ។ ហើយវាជាផលប្រយោជន៍ដែលសំខាន់បំផុតតាមទស្សនៈដែលខ្ញុំមើលឃើញ ដែលខ្ញុំសុំជូនតុលាការនូវយុត្តិសាស្ត្រមួយចំនួន អំពីគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គសហប្រជាជាតិ ជាពិសេសក្រុមការងារមួយដែលធ្វើការអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ដែលក្នុងបរិបទនេះនៅក្នុងឆ្នាំ២០០៧ ថ្ងៃ៣០ ខែ១១ នោះ គេចេញមតិយោបល់មួយនិយាយអំពីការឃុំខ្លួន ការរឹតត្បិតសេរីភាពអំពីមនុស្ស៨នាក់ដែលបានចាប់ខ្លួននៅ*ឡេប៉ាណុន* អនុលោមតាមអំពើដែលគេបានសម្លាប់អតីតប្រធានាធិបតីរបស់ប្រទេសនោះ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥នោះ ។

[១០:៥៨:៤១]

យើងនឹងពិនិត្យឃើញថា វាមានសារសំខាន់ក្នុងការយល់ដឹងដែលថា តុលាការពិសេសសម្រាប់ប្រទេស *ឡេប៉ាណុន* នោះ ក៏រួមបង្កើតដោយរដ្ឋាភិបាល *ឡេប៉ាណុន* និង *លីប៉ង់* ហើយនិងអង្គការសហប្រជាជាតិហើយខ្លួនបានចាប់ផ្តើមធ្វើការងាររបស់ខ្លួន ។ សាលាក្តីនោះបានប្រឈរមុខនឹងបញ្ហាដូចគ្នា ដូចដែលលោក លោកស្រីចៅក្រមមាននៅពេលនេះដែរ ។

គណៈកម្មាធិការស៊ើបសួរ គឺបានផ្តល់អនុសាសន៍ថាការឃុំខ្លួនបុគ្គលទាំង៨រូបនោះ នៅចំពោះមុខចៅក្រមស៊ើបអង្កេតប្រទេសលីប៉ង់ ហើយចៅក្រមស៊ើបអង្កេតលីប៉ង់ គាត់បានសម្រេចធ្វើការឃុំខ្លួនបុគ្គលទាំង៨រូបនោះ ។ ក្រុមការងារចំពោះការឃុំខ្លួនបណ្តោះអាសន្នរបស់អង្គសហប្រជាជាតិ ជាពិសេស

ក្រុមការងារនេះ គឺបានផ្តល់យល់ថា ហើយបានបង្ហាញថាការឃុំខ្លួននោះ គឺវាមិនអាចមានលទ្ធភាពធ្វើទៅបាននោះទេ ហើយការឃុំខ្លួននោះត្រូវបានកំណត់លក្ខណៈថា ជាការឃុំខ្លួនតាមទំនើងចិត្ត ។

នៅពេលតុលាការលីប៉ង់ចាប់ផ្តើមនីតិវិធី គឺបញ្ហានេះត្រូវបានយកមកដាក់ចំពោះមុខ ហើយតុលាការនោះគួរតែធ្វើការចេញសេចក្តីសម្រេចទៅលើបញ្ហាហ្នឹងទាក់ទងទៅនឹងបុគ្គល៤រូប ហើយបុគ្គល៤រូបទៀត បានត្រូវដោះលែងដោយចៅក្រម ។ ដូច្នេះ តើលោក លោកស្រីចៅក្រម នឹងធ្វើយ៉ាងដូចម្តេច ? នឹងសម្រេចយ៉ាងម្តេច ?

យើងខ្ញុំបានចែកសេចក្តីសម្រេចមួយដែលបានចេញនៅក្នុងរឿងក្តីរបស់យើង ដោយចៅក្រម

ស៊ើបអង្កេតយោធានៅថ្ងៃទី២១ ខែកក្កដាឆ្នាំ២០០៨ ។ យើងខ្ញុំបានស្នើសុំទៅលើបញ្ហានេះទាក់ទងទៅនឹងសំណុំរឿងរបស់ ឌុច ដែលគាត់ត្រូវគេនាំខ្លួននៅចំពោះតុលាការយោធា ។ ហើយចៅក្រមស៊ើបអង្កេតបានលើកឡើងថា ពិចារណាទៅលើការចោទប្រកាន់ទៅលើរឿងក្តីលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការយោធា ដោយសារតែនៅពេលនោះ គឺមិនទាន់មានច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក ដោយយើងពិចារណា-- ខ្ញុំសូមអភ័យទោស

**លោក រ៉ូបឺត ពើទីត៖**

(លោក រ៉ូបឺត ពើទីត គាត់បានធ្វើការអន្តរាគមន៍នៅក្នុងនេះ)។

[១១:០២:៤០]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំគិតថា ឯកសារនេះគួរតែបានចែកជូនអស់លោក លោកស្រីរួចទៅហើយ ខ្ញុំសូមអភ័យទោសលោក លោកស្រី មានឯកសារជាភាសាខ្មែរ និងជាភាសារបារាំង ។

ដោយពិចារណាទៅលើការបង្កើតនៃអង្គជំនុំជម្រះ អ.វ.ត.ក យុត្តាធិការរបស់ អ.វ.ត.ក គឺគ្របដណ្តប់ទៅលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រឆាំងមនុស្សជាតិដែលទាក់ទងទៅនឹងបទល្មើសថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ តុលាការយោធាគឺលែងមានយុត្តាធិការទៀតហើយលើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ។

ដោយពិចារណាថា ជនត្រូវចោទ លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានចោទប្រកាន់ ឬកំពុងចោទប្រកាន់ដោយ អ.វ.ត.ក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ យើងសម្រេចបញ្ចប់យុត្តាធិការតុលាការយោធាទាក់ទងទៅនឹងរឿងក្តីលេខ៣៩៧ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ ដែលជនត្រូវចោទ កាំង ហ្គេកអ៊ាវ

ហៅថា ឌុច ត្រូវបានសួរទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ។ ភ្នំពេញថ្ងៃទី ២១ ខែ៧ ឆ្នាំ២០០៨ ។ ចៅក្រមស៊ើបអង្កេត ។

[១១:០៤:៤២]

ក្រោយពីការចេញសេចក្តីសម្រេចមួយនេះ របស់ចៅក្រមតុលាការយោធា គឺតុលាការយោធាលែងមានយុត្តាធិការលើបុគ្គលរូបនោះ ដូច្នេះ លោក លោកស្រី ជាអ្នកបន្តទៅលើនីតិវិធីក្នុងការចោទប្រកាន់ ឌុច ។ ហើយចំណុចនេះ គឺបានបង្ហាញយ៉ាងច្បាស់ថា នៅក្នុងវាក្យខណ្ឌទីមួយនៃសេចក្តីសម្រេចនេះ ។ កាលពីមុន គឺរឿងក្តីនេះស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការយោធា ដោយសារតែយើងមិនមានច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក ។

ដូច្នេះ យើងឃើញមានការបន្តទៅលើដំណើរការនីតិវិធីនេះ ។ យើងមិនអាចនិយាយថា បញ្ហានេះមិនមែនជាបញ្ហាយើងទេ ។ ខ្ញុំថា ខ្ញុំដាក់បញ្ហានេះចំពោះមុខលោក លោកស្រីចៅក្រមហើយយើងមិនអាចជៀសវាងពីបញ្ហាមួយនេះឡើយ ។

ដូច្នេះ ថាតើយើងចាត់ការយ៉ាងម៉េចទៅលើបញ្ហានេះ? ជាបឋមយើងត្រូវតែគិតពិចារណាផ្អែកទៅលើយុត្តាធិការ ។ ហើយនៅក្នុងករណីនេះ ខ្ញុំមិនឃើញមានយុត្តិសាស្ត្រណាមួយដែលវាមានផ្ទុះបញ្ចាំងនៅក្នុង *បារ៉ាវីហ្សា* សូមអភ័យទោស លោក វូ បានលើកឡើង ។ ខ្ញុំសូមប្រកបថា *B-A-R-R-A-Y-A-G-W-I-V* *បារ៉ាយ៉ាហ្គីហ្សា កាំប៊ូស្គួ* ។ ដូច្នេះ ថាតើបញ្ហាអ្វីដែលមាននៅក្នុងរឿងក្តីនោះ? មេធាវីការពារក្តីបានលើកឡើងថា លោក *បារ៉ាយ៉ាហ្គីហ្សា* ឬ គេហៅថា គាត់ថាជាចារីមួយរូបនិងជាអ្នកទទួលខុសត្រូវមួយរូបចំពោះបទប្រល័យពូជសាសន៍ ។ សិទ្ធិរបស់គាត់ត្រូវបានគេរំលោភនៅពេលចាប់ខ្លួន ។ ហើយគាត់ត្រូវបានគេឃុំខ្លួន ដោយរំលោភទៅលើសិទ្ធិរបស់គាត់ ។

[១១:០៧:៤៤]

ខ្ញុំសូមត្រឡប់ទៅវាក្យខណ្ឌ១០៦ នៃសាលក្រមថ្ងៃទី៣ ខែ១១ ឆ្នាំ១៩៩៩ របស់តុលាការរ្វ៉ាន់ដានិងតុលាការអតីតប្រទេសយូហ្គោស្លាវី ដែលតុលាការឧទ្ធរណ៍បានសម្រេចថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់ចំពោះជនជាប់ចោទ គឺមានលក្ខណៈធ្ងន់ធ្ងរ ។ នេះបើយើងមិនគិតពីចំណុចដែលថាសិទ្ធិរបស់គាត់ត្រូវបានគេរំលោភនៅក្នុងករណីនិងកាលៈទេសៈមួយចំនួន ។

យើងឃើញមានកថាខណ្ឌមួយចំនួនដែលវាមិនពាក់ព័ន្ធនឹងសហព្រះរាជអាជ្ញានៅទីនេះទេ ប៉ុន្តែ *បារ៉ាយ៉ាហ្គីហ្សា* អង្គជំនុំជម្រះបានលើកឡើងនូវចំណុចនេះ ដោយលើកឡើងដូចខាងក្រោម៖

អង្គជំនុំជម្រះទទួលនូវការខកខានអនុវត្តរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងការធ្វេសប្រហែស ។ ហើយគឺករណីនេះគឺមិនដូចនៅក្នុងករណីរបស់យើងនៅក្នុងសាលាក្តីយើងឡើយ ដែលថាសហព្រះរាជអាជ្ញាគាត់មិនបានធ្វើការធ្វេសប្រហែសនោះទេ ។

នៅពេលដែលសម្រេចនោះ គឺសាលាឧទ្ធរណ៍របស់តុលាការវ៉ាន់ដា សន្និដ្ឋាននៅក្នុងកថាខណ្ឌចំនួនពីរដែលខ្ញុំសូមលើកឡើងថា “នៅក្នុងរឿងបច្ចុប្បន្នយើងទទួលស្គាល់ចំពោះការងារដែលលើកឡើងដោយចៅក្រម *ប្រាន់ដេ* របស់តុលាការកំពូលសហរដ្ឋអាមេរិក ។ យើងឃើញថា សេរីភាព សន្តិសុខតម្រូវឲ្យអ្នកតំណាងនៃប្រទេសនេះ ដោយត្រូវតែគោរពតាមក្រមការងារឲ្យបានត្រឹមត្រូវដែលថាដែលប្រទេសមួយជាប្រទេសគោរពច្បាប់ ហើយយើងត្រូវគិតអំពីបញ្ហាដែលថា អាទិភាពរបស់ប្រទេស គឺមានស្ថានភាពវឹកវរ ហើយរដ្ឋគឺមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់ ។ រដ្ឋគឺជាស្ថាប័នមួយដែលសំខាន់និងមានអំណាច ។ រដ្ឋគឺបង្រៀនមេរៀនដល់ប្រជាពលរដ្ឋ ។ ការប្រព្រឹត្តឧក្រិដ្ឋកម្មគឺមានលក្ខណៈមិនសមរម្យ ហើយរដ្ឋដែលរំលោភទៅលើច្បាប់ គឺជំរុញឲ្យមានការមើលងាយជាន់ឈ្លីទៅលើបញ្ហាច្បាប់ ។

[១១:១១:១៥]

ដូច្នេះ អង្គជំនុំជម្រះឲ្យជំរុញប្រជាជនធ្វើការបង្កើតច្បាប់ ហើយធ្វើការគោរពច្បាប់ ។ ចំពោះការគ្រប់គ្រងទៅលើបញ្ហាយុត្តិធម៌ដែលថា ចំណុចចុងក្រោយនឹងរកឃើញតាមរយៈនីតិវិធីក្នុងការលើកឡើងថា រដ្ឋអាច-- បទល្មើសដើម្បីធ្វើការធានាទៅដល់អ្នកពិរុទ្ធជននោះ គឺនឹងធ្វើឲ្យមានផលប៉ះពាល់មួយអវិជ្ជមាន ។ ដូចដែលលោកចៅក្រម *ចាច់ វ៉ាន់ឌី* បានលើកឡើងតុលាការត្រូវតែមានជំហរត្រឹមត្រូវទាក់ទងទៅនឹងទ្រឹស្តីនៃការដាក់ទោស ។ ហើយនៅពេលដែលយើងដកស្រង់ចៅក្រម *ប្រាន់ដេ* នៅក្នុងចំណុចទីមួយ នៅទីនេះគឺយើងបានយោងទៅលើតុលាការអន្តរជាតិប្រទេសវ៉ាន់ដា គឺជាតុលាការមួយដែលមានគោលបំណងចម្បងធានាការស្វែងរកយុត្តិធម៌ ។

តុលាការមិនគួរធ្វើការយល់ស្របទៅតាមការរំលោភសិទ្ធផ្សេងៗ ដូចដែលខ្ញុំបានលើកពីមុននៅក្នុងករណីនោះ ។ ដូច្នេះ គេអនុញ្ញាតឲ្យអ្នកម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលបានការជំនុំជម្រះមួយក្នុងលក្ខណៈមួយមានភាពយុត្តិធម៌ ហើយយើងក៏មិនធ្វើឲ្យមានការប៉ះពាល់ទៅដល់សុចរិតភាពរបស់តុលាការនោះផងដែរ ។ ហើយប្រសិនបើសាធារណជនគាត់មិនមានជំនឿលើតុលាការនោះ ដែលវារំលោភទៅលើសិទ្ធិរបស់បុគ្គលផ្សេងៗរួមទាំងជនជាប់ចោទលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗ ។ បញ្ហានេះ គឺជាផលលំបាកមួយអវិជ្ជមាន ហើយបញ្ហានេះ គឺវាជាការខុសក្នុងការអនុញ្ញាតឲ្យគេកាត់ទោសជនជាប់ចោទ ឬម្ចាស់

បណ្តឹងឧទ្ធរណ៍ក្នុងលក្ខណៈមួយរំលោភសិទ្ធិ ។ ទោះបីជាវាមានការលំបាកចំពោះបុគ្គលមួយចំនួនក្នុងការទទួលយកការយល់ឃើញនោះក៏ដោយ វាគឺជាតួនាទីក្នុងប្រព័ន្ធយុត្តិធម៌នៅក្នុងដំណើរការក្តីនេះដើម្បីថាបញ្ហាអយុត្តិធម៌ផ្សេងៗមិនអាចកើតមាននៅក្នុងតុលាការ ។

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! សេចក្តីសម្រេច ឬក៏សាលដីកាមួយនេះ គឺវាបង្កើតឡើងនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ ខ្ញុំអាចប្រមើលមើលថា តើស្ថានភាពស្មារតីយ៉ាងម៉េចដែលចៅក្រមគាត់បានចេញសេចក្តីសម្រេច ឬសាលដីកាបែបនេះ? គឺនៅក្នុងសវនានោះ គឺដឹកនាំដោយលោកចៅក្រម *ម៉ាគីអែល សាដូណាល់* ខ្ញុំអាចគិតឃើញថា អង្គជំនុំជម្រះគឺចូលស៊ីជម្រៅជាងនោះដោយសារដែលឲ្យអនុញ្ញាតនិងទាមទារឲ្យមានការចេញសេចក្តីសម្រេចមួយភ្លាមៗ ហើយហាមឃាត់ព្រះរាជអាជ្ញាក្នុងការបន្តនីតិវិធី ។ ខ្ញុំសូមផ្តានាថា យើងមិនទាន់បានលើកឡើងចំណុចនេះនៅឡើយទេ ។ ហើយខ្ញុំសូមលើកឡើងឲ្យអស់នៅចំណុចនេះ ហើយខ្ញុំសូមបន្ថែមថា នៅក្នុងពេលដែលគេសម្រេចទៅលើបញ្ហាហ្នឹងព្រះរាជអាជ្ញាឈ្មោះ *កាឡា រ៉នហ្សេ* ដែលគាត់ត្រូវបានតែងតាំងជារដ្ឋអាជ្ញាអន្តរជាតិ គាត់បានអនុវត្តនីតិវិធីសើរើចំពោះសាលក្រមនោះ ។ ហើយនៅក្នុងសេចក្តីថ្លែងមួយសំខាន់ក្នុងពេលសវនាការដែលគាត់បានលើកឡើងជូនចៅក្រមសាលាឧទ្ធរណ៍ គាត់បានលើកឡើងថា ដើម្បីគោរពទៅលើនីតិវិធីយើងត្រូវតែបញ្ឈប់ដំណើរការ ។

ដូច្នេះ ចំណុចនេះវាគឺជាការពិតដែលថាតុលាការកំពូលគាត់បានធ្វើការសើរើទៅលើរឿងក្តីនោះ ។ ហើយសេចក្តីសម្រេចទីពីរដែលបានចេញក៏មានលក្ខណៈសំខាន់និងចាប់អារម្មណ៍ដែរ ។ តុលាការកំពូលបានលើកឡើងថា ពិតជាមានការរំលោភសិទ្ធិទៅលើជនជាប់ចោទមែន ។ វាជាការពិត ប៉ុន្តែ យើងមិនអាចសុំឲ្យមានការបញ្ចប់ដំណើរការនីតិវិធីនោះទេ ។ ប៉ុន្តែ យើងលើកឡើងថា បន្ទាប់ពីនីតិវិធី ប្រសិនបើមានការរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទយើងនឹងធ្វើការបន្ថយទៅលើការដាក់ទោស ។ នេះគឺជាអ្វីដែលគេបានលើកឡើងនៅក្នុងហ្នឹង ។

[១១:១៧:០១]

លោក *បារ៉ាយ៉ាហ្គីហ្សា* ត្រូវបានរកគេរកពិរុទ្ធភាព ហើយគាត់ត្រូវបានគេកាត់ឲ្យជាប់ទោស ។ ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ហើយគេមានការបន្ថយទោសរបស់គាត់មកត្រឹម៣៥ឆ្នាំ ដោយតុលាការបានពិចារណាទៅលើការរំលោភសិទ្ធិរបស់គាត់ ។

ដូច្នេះ អ្វីដែលយើងស្នើសុំលោក លោកស្រីចៅក្រមនាថ្ងៃនោះ ជាបឋមដើម្បីបញ្ចប់ឲ្យបានឆាប់

នូវការឃុំខ្លួនរបស់ ឌុច ដែលក្នុងរយៈពេលនៃការជំនុំជម្រះ ។ ហើយខ្ញុំសូមបញ្ជាក់ថា គឺក្នុងរយៈពេលនៃការជំនុំជម្រះ ។ ដូច្នេះហើយបន្តពីអ្វីដែលលោក ការ សាវុត្ថ បាននិយាយពីម្សិលមិញនោះ យើងនឹងបញ្ជាក់អំពីតុល្យាភាពនៃដំណើរការនីតិវិធី រវាងអ្វីដែលសហព្រះរាជអាជ្ញាបានបដិសេធមិនធ្វើការចោទប្រកាន់ចំពោះអ្នកទាំងអស់ដែលខ្លួនមិនបានធ្វើការចោទប្រកាន់ចំពោះបទល្មើសធ្ងន់ធ្ងរនោះ ។ ប៉ុន្តែ ឌុច ម្នាងទៀតនៅចោទប្រកាន់ ប៉ុន្តែឈ្មោះរបស់អ្នកទាំងនោះ គឺបានបញ្ជាក់នៅក្នុងសារព័ត៌មាន ប៉ុន្តែមិនត្រូវបានចោទប្រកាន់នោះទេ ។

[១១:១៨:៤៣]

ដូច្នេះហើយ គឺថាមិនមែនជាចំណុចមួយនៅក្រៅបញ្ហានោះទេ ប៉ុន្តែអង្គជំនុំជម្រះៗអាចនឹងសម្រេចថាក្នុងរយៈពេលជំនុំជម្រះ តើការចោទប្រកាន់អ្វីៗទាំងអស់ដែលជាបទឧក្រិដ្ឋដែលមិនអាចគិតមើលបាននោះ គឺថាគប្បីតែរង់ចាំ ។ យើងគប្បីទុកឲ្យ ឌុច នៅក្រៅឃុំក្នុងរយៈពេលជំនុំជម្រះនេះ ។ មេធាវីមិនជំទាស់មិនតទល់ ហើយខ្លួនក៏មិនជំទាស់នូវលក្ខខណ្ឌមួយចំនួនដែលដាក់ទៅលើការឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ននោះទេ ។

[១១:១៩:២៧]

បើសិនជាមានការសម្រេចក្នុងករណីថា ប្រសិនជាគាត់ត្រូវនៅក្នុងផ្ទះដែលមានសុវត្ថិភាពមួយ។ បើសិនករណីនោះមានមែន ករណីនោះមាននៅក្នុងតុលាការផ្សេងទៀតដែលគេបានធ្វើ។ ពេលនោះលោកប្រធាន លោក លោកស្រីចៅក្រមបានជ្រាបហើយសូមអនុញ្ញាតបញ្ជាក់ជូននូវទស្សនៈទូទៅ ជាសេចក្ដីសង្កេតមួយ ។ ឌុច គឺជាសហអ្នកជាប់ឃុំជាមួយជនដទៃទៀត ដែលនឹងត្រូវបញ្ជាក់នៅក្នុងដំណើរការនៃនីតិវិធី ។ តើលោក លោកស្រីចៅក្រមមិនគិតថា គឺថាអាចនឹងបំពេញចិត្តទៅកាន់អ្នកផ្សេងទៀតដែលថា អ្នកនោះមិនត្រូវបានឃុំខ្លួននោះទេនោះ។ ដូច្នេះ យើងពិនិត្យមើលអង្គហេតុមួយដែលថាអាចនឹងពិចារណាមើលបាន ។ យើងនឹងពិនិត្យមើលការអនុវត្តច្បាប់ ប៉ុន្តែសុំអនុញ្ញាតអ្វីដែល ឌុច បានលើកឡើងនោះ ឬក៏យើងអនុញ្ញាតឲ្យ ឌុច មានសេរីភាពក្នុងការនិយាយក្នុងដំណើរការរយៈពេលដំណើរការនៃការជំនុំជម្រះ ឲ្យគាត់នៅក្រៅឃុំ ប៉ុន្តែដោយដាក់លក្ខខណ្ឌមួយចំនួនដែលអង្គជំនុំជម្រះអាចនឹងកំណត់ ។ ពេលនោះហើយទើបយុត្តិធម៌អាចកើតមានឡើងបាន ហើយអាចនឹងពិនិត្យចំណុចនោះ ។

ប្រសិនបើ មេធាវីការពារបានស្នើសុំឲ្យ លោក លោកស្រីចៅក្រមនៅក្នុងពេលនេះសម្រេចនូវចំណុចពីរយ៉ាង ។ ចំណុចទីមួយ គឺថាក្នុងករណីនៃការកាត់ទោស ដាក់កម្រិតទោសនោះ គឺថារយៈពេល

ដែលបានប្រើនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងខែឧសភា ឆ្នាំ១៩៩៩នោះ ចាប់ពីពេលនោះមក គប្បីតែរាប់បញ្ចូល ហើយនិងកាត់ចេញពី ការសម្រេចដាក់ទោសជាសរុប ។ ហើយចំណុចមួយទៀត គាត់មានសិទ្ធិក្នុងការស្នើសុំឲ្យការកាត់រយៈពេលទោសផងដែរ ចំពោះការបំពានលើសិទ្ធិរបស់គាត់កន្លងមកនោះ។

ហើយត្រឡប់ទៅចំណុចមួយ ដែលយើងបានចំណុចទៅលើសេចក្តីសម្រេចទីពីររបស់ រឿងក្តី *បារ៉ាយ៉ាហ្គីហ្សា* នេះជាចំណុចមួយ ខ្ញុំពិនិត្យឃើញថា ដោយមានភាពទាំងស្រុងនៃលទ្ធភាពដែលមានដែលបានជម្រាបជូនលោក លោកស្រី ចៅក្រមទីនេះ ដើម្បីត្រូវសម្រេចដោះស្រាយដូចម្តេចចំពោះបញ្ហាលំបាកនេះ ។

ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជាពាក្យចុងក្រោយទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានអ្វីអនុវត្តប្រឆាំងនឹងសិទ្ធិរបស់អស់លោក លោកស្រីនោះទេ ។ អ្វីៗទាំងអស់គឺធ្វើឡើងក្នុងមូលដ្ឋានច្បាប់ ហើយខ្ញុំទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ហើយ លោក លោកស្រីមានសិទ្ធិក្នុងការគាំទ្រគោលជំហរនេះ ។

ខ្ញុំពិចារណាឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីអាចអន្តរាគមន៍នៅក្នុងសវនាការនិយាយអំពីការឃុំខ្លួន ប្រសិនបើខ្លួនអាចមានលទ្ធភាពផ្តល់ភស្តុតាង ហើយបញ្ជាក់ថា បើការឲ្យនៅក្រៅឃុំប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ បើការធ្វើដូច្នោះមិនធ្វើឲ្យគាត់ព្រួយបារម្ភទេ ខ្ញុំមិនពិនិត្យឃើញថាក្នុងខណៈពេលនោះវាជាបញ្ហានោះទេ ។ ដោយថាការឲ្យ ឌុច នៅក្រៅឃុំ ហើយស្ថិតនៅក្នុងផ្ទះសុវត្ថិភាពមួយនោះ ។ ហើយការធ្វើបែបនោះ គឺវាមិនប៉ះពាល់អ្វីដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ដោយសារថាយើងនៅទីនេះ យើងស្វែងរកនូវច្បាប់ដែលថាបុគ្គលម្នាក់ៗ ដែលថាអាចនឹងត្រូវតែស្ថិតនៅក្រោមការអនុវត្តច្បាប់ស្មើៗគ្នា គឺច្បាប់កម្ពុជាដែលចែងបញ្ជាក់ថាបុគ្គលគ្រប់រូបមិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នលើសពីបីឆ្នាំបានទេ ។ ច្បាប់អន្តរជាតិក៏បានហាមឃាត់ការឃុំខ្លួនលើសពីចំណុចនេះដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញា តើសហព្រះរាជអាជ្ញាចង់លើកឡើងតបទៅនឹងអ្វីដែលបានលើកឡើង ដោយមេធាវីការពារជនជាប់ចោទពាក់ព័ន្ធជាមួយនឹងការបង្ហាញអម្បាញ់មិញនេះ អំពីហេតុផលទាំងឡាយជុំវិញបញ្ហាការឃុំខ្លួនជនជាប់ចោទកន្លងមកនិងហេតុផលផ្សេងទៀត ដែលមានស្ថានភាពជាបន្តបន្ទាប់ដែលលោកហ្វ្រង់ស្វ័រ រូ បានលើកឡើង ។ បើមានសូមអញ្ជើញ ។

[១១:២៦:៤២]

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល! កាលដែលលោកមេធាវីរបស់ជនជាប់ចោទបានស្នើឲ្យដោះលែងកូនក្តីរបស់ខ្លួននៅក្រៅឃុំបណ្តោះអាសន្ននេះ យើងជាសហព្រះរាជអាជ្ញាក៏ឃើញនៅក្នុងមាត្រា៨២ ក៏បាននិយាយអំពីសិទ្ធិរបស់គាត់ក្នុងការស្នើសុំនេះ ។ គ្រាន់តែសហព្រះរាជអាជ្ញាសូមបញ្ជាក់ថា មិនមែនជារឿងដែលថ្មីនោះទេ ។ ការសុំនៅក្រៅឃុំបណ្តោះអាសន្ននេះ គឺត្រូវបានមេធាវីជនជាប់ចោទស្នើសុំតាំងពីនៅដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ ។ ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា ការស្នើសុំនេះក៏ត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធនូវការស្នើសុំរបស់មេធាវីជនជាប់ចោទដែរ ។ ជាមួយគ្នានឹងដែរ ក៏មានការប្តឹងឧទ្ធរណ៍មកអង្គបុរេជំនុំជម្រះ និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយអង្គបុរេជំនុំជម្រះនោះក៏បានសម្រេចក្នុងការតម្កល់ការឃុំខ្លួនបណ្តោះអាសន្នជាបន្តទៀត ។ នេះជាប្រវត្តិអ្វីដែលទាក់ទងនឹងការស្នើសុំឡើងរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទ ។ ដូច្នេះ សហព្រះរាជអាជ្ញានៅតែស្នើសុំទៅអង្គបុរេជំនុំជម្រះក្នុងការបន្តការឃុំខ្លួន ជនជាប់ចោទរូបនេះជាបន្តទៀតដោយមានមូលហេតុមួយចំនួនដូចខាងក្រោម៖

[១១:២៨:៣៦]

ទីមួយ៖ ដោយសហព្រះរាជអាជ្ញាយល់ថាវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងរហូតមកដល់ពេលនេះ គឺនៅតែជាការចាំបាច់ ព្រោះថាវិធាននេះបានចែងថា “ប្រសិនបើមានការជឿជាក់ថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសនោះ” ម្យ៉ាងទៀត នៅពេលនេះជនជាប់ចោទខ្លួនឯងបានទទួលស្គាល់នូវបទឧក្រិដ្ឋនានាដែលបានកើតឡើងនៅមន្ទីរស-២១ ក្នុងនាមគាត់ជាប្រធានអតីតមន្ទីរស-២១ នោះឯង។ ដូច្នេះ គាត់ទទួលស្គាល់ក្នុងការងារដែលគាត់ទទួលខុសត្រូវនៅទីនោះ ។

ទីពីរ៖ សហព្រះរាជអាជ្ញាយល់ថា ការទាក់ទងនឹងការលើកឡើងជនជាប់ចោទដែលមានការឃុំខ្លួនក្នុងតុលាការយោធាកន្លងមកតាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ នោះ យើងសួរវិញថា តើនេះត្រូវតែយើងជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលខុសត្រូវឬ? សហព្រះរាជអាជ្ញាសូមជម្រាបថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ គឺជាស្ថាប័នមួយដែលឯករាជ្យដាច់ចេញពីតុលាការយោធា។ ហើយអង្គជំនុំជម្រះនេះមិនធ្លាប់បានដំណើរការជាផ្លូវការណាមួយរបស់ខ្លួន ដែលទាក់ទង ឬក៏មានការព្រមព្រៀងជាមួយនឹងតុលាការយោធាដែលជាតុលាការក្នុងស្រុកនោះដែរ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើង ក៏មិនដែលស្នើឲ្យតុលាការយោធាធ្វើការឃុំខ្លួនទាល់តែសោះ ។ ដូច្នេះ អង្គជំនុំ

ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាស្ថាប័ន ដែលមានលក្ខណៈកូនកាត់ជាអន្តរជាតិ ។ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ជាស្ថាប័នមួយឯករាជ្យដាច់ចេញពីតុលាការជាតិ ដែលហៅថា “តុលាការយោធា” ដែលធ្លាប់បានឃុំខ្លួនជនជាប់ចោទរូបនេះកន្លងមក ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងមានឯករាជ្យភាពរបស់ខ្លួនចេញពីឯកភាពរបស់តុលាការយោធាដែលជាតុលាការក្នុងស្រុក ។ ដោយសារថា អង្គជំនុំជម្រះវិសាមញ្ញក្នុងកម្ពុជាជាតុលាការអន្តរតួបនីកម្មពិសេសមួយ ។ ហើយខ្ញុំនឹងលើកឡើងអំពីលក្ខណៈពិសេសរបស់តុលាការអង្គជំនុំជម្រះវិសាមញ្ញយើងនេះ គឺថាតុលាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងនេះ គឺថាបានបង្កើតឡើងដោយមានការយល់ព្រមឯកភាព រវាងរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិ ដោយបង្កើតច្បាប់មួយពិសេស ហើយមានការទទួលខុសត្រូវនូវអ្វីដែលតុលាការនេះនឹងចាប់ផ្តើមដំណើរការ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនចងកាតព្វកិច្ច វិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍របស់លើតុលាការក្នុងស្រុកទេ ហើយការឃុំខ្លួននេះដែលមេធាវីលើកឡើងគឺវាមានការពាក់ព័ន្ធពាន់នឹងតុលាការក្នុងស្រុក ។ ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា ប្រសិនបើមេធាវីការពារក្តីនៅតុលាការយោធានោះ យល់ថាការឃុំខ្លួនរបស់កូនក្តីខ្លួនមិនត្រឹមត្រូវ អ្នកដែលមានសមត្ថកិច្ច គឺជាសាលាឧទ្ធរណ៍របស់តុលាការកម្ពុជា មិនមែនតុលាការអង្គជំនុំជម្រះវិសាមញ្ញរបស់យើងទេ ។

ដូច្នេះខ្ញុំជាសហព្រះរាជអាជ្ញាយល់ឃើញថា លោក ការ សាវុត្ថ ក៏ជាមេធាវីតាំងពីដើមទី ដែលការពារឲ្យជនជាប់ចោទរូបនេះ ។ គាត់ត្រូវតែមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទៅតុលាការជាតិ ។ ប៉ុន្តែការបោះបង់សិទ្ធិរបស់គាត់ នេះគឺជារឿងមេធាវីខ្លួនឯង ។

អង្គជំនុំជម្រះវិសាមញ្ញនេះ ខ្ញុំគិតថា មិនមានការព្រមព្រៀងជាមួយតុលាការយោធានោះទេ ។ ហើយតុលាការយោធាក៏បានយកច្បាប់នៃការបង្កើតឲ្យមានអង្គជំនុំជម្រះនេះ មកចោទប្រកាន់ជនត្រូវចោទប្រសិនបើគិតថាខុសនោះ គឺវាជាការខុសឆ្គងរបស់តុលាការយោធាទេ ។ ប៉ុន្តែ ខ្ញុំគិតថាអ្វីក៏ដោយយើងត្រូវតែគិតពីការដំណើរការមួយដ៏ត្រឹមត្រូវក្នុងអង្គជំនុំជម្រះដែរ ។ រាប់តាំងពីដំណើរការនៃការិយាល័យរបស់សហព្រះរាជអាជ្ញា ក៏ដូចជាដំណើរការនៃការដំណើរការរបស់សហចៅក្រមស៊ើបអង្កេតនោះការិយាល័យទាំងពីរនេះ ខ្ញុំគិតថាវាមានការរៀងខ្លួន ឯករាជ្យរៀងខ្លួន ហើយការិយាល័យទាំងនេះ ដែលមានលក្ខណៈជាសហ ។ បើគិតទៅយើងទាំងសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិក៏ដូចជាសហព្រះរាជអាជ្ញាអន្តរជាតិ ហើយចៅក្រមស៊ើបអង្កេតអន្តរជាតិនោះដែរ ។ ដូច្នេះ លក្ខណៈ

ពិសេសរបស់យើងនេះ គឺវាមានលក្ខណៈមួយដូចតុលាការជាតិ ។ សូម្បីតែយើងពិនិត្យទៅលើការតែងតាំងរបស់ចៅក្រមជំនុំជម្រះ យើងមានទាំងពីចៅក្រមជាតិ និងចៅក្រមអន្តរជាតិនោះ យើងគិតថាអ្វីៗក៏មិនមានការទាក់ទងទៅនឹងតុលាការជាតិដែរ ។

[១១:៣៤:១១]

អង្គជំនុំជម្រះតុលាការកម្ពុជា មិនអាចដាក់ឲ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់តុលាការយោធានោះទេ ។ ដូច្នេះ ការរំលោភណាមួយដែលធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ជនជាប់ចោទមែននោះ មិនមែនជាកំហុសរបស់អង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជាដែរ ។ ដូច្នេះ ការឃុំខ្លួន ឌុច នៅតុលាការយោធាមកម្ល៉េះ បែរជាការឃុំខ្លួននេះមកឲ្យអង្គជំនុំជម្រះទទួលខុសត្រូវនោះ ខ្ញុំគិតថាមិនមែនជាការត្រឹមត្រូវឡើយ ។

ចំណុចទីបី៖ ដែលខ្ញុំមានការអះអាងក្នុងការស្នើសុំឲ្យមានការឃុំខ្លួនជាបន្តទៀតនោះដែរ គឺអ្វីដែលអង្គបុរេជំនុំជម្រះសម្រេចកន្លងមកឃើញថា បានសម្រេចក្នុងការតម្កល់ដីការបស់សហចៅក្រមស៊ើបអង្កេត ហើយបន្តការឃុំខ្លួនជនជាប់ចោទជាបន្តទៀតនោះ ។ យើងសង្កេតឃើញថាតាំងពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះរហូតមកដល់ពេលនេះ យើងពុំឃើញមានអ្វីដែលប្រែប្រួលក្រៅពីសេចក្តីរបស់អង្គបុរេបានសម្រេចកន្លងមកនោះទេ ។ ដូច្នេះ ទោះបីមាត្រា៨២.៣ ដែលអនុញ្ញាតឲ្យមេធាវីស្នើសុំឡើង នោះជាសិទ្ធិរបស់គាត់អាចជាលាយលក្ខណ៍អក្សរ អាចជាផ្ទាល់មាត់ក៏បានដែរ ។ ប៉ុន្តែ ត្រូវគិតថាអ្វីដែលវាប្រែប្រួលក្នុងដំណាក់កាលក្នុងការបដិសេធរបស់អង្គបុរេជំនុំជម្រះមកដល់ពេលនេះ តើវាមានអ្វីថ្មីដែលជាការកត់សម្គាល់មួយគួរតែដោះលែងឲ្យគាត់នៅក្រៅឃុំបណ្តោះអាសន្ន?

ចំណុចទីបួន៖ សហព្រះរាជអាជ្ញានៅតែយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននៅពេលនេះវាមានសារសំខាន់ដើម្បីធានាផ្លូវច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា៣៥(ឃ) នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានសរសេរយ៉ាងច្បាស់ អំពីការកាត់ទោសចំពោះមុខជនជាប់ចោទត្រូវនៅតែចំពោះមុខអង្គសវនាការ ។ ដូច្នេះ ការយល់ឃើញនិងការបន្តការឃុំខ្លួន ដូចដែលមានចែងនៅពេលនេះ ដើម្បីជៀសវាងការកាត់ទោសកំបាំងមុខចំពោះជនជាប់ចោទ ។ ដើម្បីធានាបាន យើងគិតថាសុំឲ្យអង្គជំនុំជម្រះនេះមេត្តាបន្តការឃុំខ្លួននិងដើម្បីធានាការកាត់ក្តីចំពោះមុខជនជាប់ចោទ ។

[១១:៣៦:៥៥]

ទីប្រាំ៖ ដើម្បីធានានូវសុវត្ថិភាព សន្តិសុខផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ឌុច ព្រោះមកទល់នឹង

ពេលនេះសាធារណជនដែលជាក្រុមគ្រួសាររបស់ជនរងគ្រោះ ក៏ដូចជា ជនរងគ្រោះខ្លួនឯងផ្ទាល់ គាត់មានការស្គាល់ទៅលើជនជាប់ចោទឈ្មោះ ឌុច នេះច្បាស់ណាស់ ។ ដូច្នេះ ប្រសិនបើអង្គជំនុំជម្រះដោះលែងឲ្យគាត់នៅក្រៅឃុំ វាជាការមួយដែលគិតថា វាផ្សងព្រេងក្នុងការដែលជនរងគ្រោះ ដែលជាក្រុមគ្រួសារនៃជនរងគ្រោះ គាត់មានកំហឹងនៃការឈឺចាប់ ដែលក្រុមគ្រួសាររបស់គេបានជួបប្រទះនៅក្នុងទារុណកម្មផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ដែលធ្វើឲ្យគាត់នឹងផ្ទុះកំហឹងហ្នឹង ហើយនឹងមានការសងសឹកទៅលើគាត់ជាមិនខាន ។ អានេះជាផ្នែកមួយសន្តិសុខរបស់គាត់ផ្ទាល់តែម្តង ។ ហើយខ្ញុំគិតថា ម៉្យាងទៀត ប្រសិនបើមានបញ្ហានឹងការសងសឹកនិងការគំនុំគុំកួនទៅលើជនជាប់ចោទនោះ វាជាលក្ខណៈមួយ ហៅថាលក្ខណៈសន្តិសុខសាធារណៈហ្នឹងក៏វាមិនល្អដែរ ។ វាប៉ះពាល់ផ្នែកសន្តិសុខសាធារណៈ ហើយបើសិនមានការវាយប្រហារទៅលើជនជាប់ចោទនោះ ។

បញ្ហាមួយទៀត ពេលនេះខ្ញុំនឹងមានបំណងឆ្លើយតបទៅលើដីកាសម្រេចដែលមេធាវីបានលើកឡើងអម្បាញ់មិញនេះ ដែលយកដីកាសម្រេចរបស់តុលាការយោធាមួយសម្រេចពីការឃុំខ្លួន ។ ខ្ញុំសង្កេតជាទូទៅ ខ្ញុំឃើញនៅលើដីកានេះគឺមានចែងច្បាស់ថា អង្គជំនុំជម្រះ--*(សុំទោស)* តុលាការយោធា ហ្នឹងគាត់មិនទទួលយកនូវអ្វីដែលតុលាការនោះនឹងដំណើរការ ។ ដូច្នេះ គាត់ប្រើពាក្យថា ក្រោយពេលដែលអង្គជំនុំជម្រះតុលាការកម្ពុជាត្រូវបានបង្កើតយុត្តាធិការរបស់ខ្លួន។ ដូច្នេះក្រោយពេល អ៊ីចឹងបានន័យថាតុលាការយោធាមិនទទួលខុសត្រូវនូវអ្វីដែលតុលាការនេះដំណើរការ ។ ដូច្នេះ យើងជាសហព្រះរាជអាជ្ញានៅទីនេះ យើងចាប់ដំណើរការនៅឆ្នាំ២០០៦ ដូច្នេះ នូវអ្វីដែលកន្លងមកក៏យើងមិនទទួលស្គាល់ដូចគ្នា ។ ហើយគាត់ក៏បានទទួលស្គាល់ថា គាត់មិនទទួលស្គាល់នូវអ្វីដែលអង្គជំនុំជម្រះនេះនឹងបង្កើតឡើងដែរ ។

ខ្ញុំឃើញថា នៅលើចំណុចនេះ គឺមានលក្ខណៈមួយដែលច្បាស់លាស់ ហើយនៅក្នុងសេចក្តីសម្រេចនេះក៏ឃើញមានការចុះហត្ថលេខាមួយដែលចុះ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ ។ ដូច្នេះ ការសម្រេចដីកាក្នុងការឃុំខ្លួន ការមិនទទួលអំពីយុត្តាធិការ មិនទទួលយកសមត្ថកិច្ចរបស់អង្គជំនុំជម្រះនោះគិតថា វាជាលក្ខណៈមួយដែលត្រឹមត្រូវ ហើយខាងសហព្រះរាជអាជ្ញាក៏យល់ស្របនៅលើឯកសារដែលបានសរសេរយ៉ាងច្បាស់លាស់នៅតុលាការយោធានេះដែរ ។

ដោយសារមូលហេតុដែលសំអាងប៉ុន្មានចំណុចខាងលើនេះហើយ សហព្រះរាជអាជ្ញានៅតែស្នើសុំទៅអង្គជំនុំជម្រះថា សុំមេត្តាបន្តការឃុំខ្លួនជនជាប់ចោទរូបនេះជាបន្តទៀត ។

ហើយចំណុចចុងក្រោយដែលលោកមេធាវីលើកឡើងអំពី ការកាត់ទោស ការដកទោសនោះជាសិទ្ធិសម្រេចរបស់អង្គជំនុំជម្រះទេ ។ សូមអរគុណ ។

[១១:៤០:៣៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ដើមបណ្តឹងរដ្ឋប្បវេណី គឺថា ខ្ញុំសូមរំឭកថា មេធាវីការពារបានស្នើសុំឲ្យខ្លួនបានលើកឡើងនៅក្នុងចំណុចពិសេសទីពីរដែលចែងថា នៅក្នុងពេលអង្គជំនុំជម្រះអាចបង្គាប់ឲ្យជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្ន ឬក៏នៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬក៏បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទតាមវិធានផ្ទៃក្នុងនេះ ។ អ៊ីចឹងហើយអង្គជំនុំជម្រះអាចធ្វើសេចក្តីសម្រេចបន្ទាប់ពីបានធ្វើសវនាការសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា និងមេធាវីការពារ ។ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានចំណុចនោះទេ ។ យើងបានពិនិត្យឃើញវិធាន៨២ កថាខណ្ឌទី៣ ប៉ុន្តែនេះជាបញ្ហាដ៏ចម្បងបំផុតរបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំស្នើថា លោកប្រធានដើម្បីប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផ្តល់ពីរ-បីនាទីដើម្បីឲ្យមេធាវីរបស់ដើមបណ្តឹងមានមតិនោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុម-- អញ្ជើញ ។

សុំៗមេធាវីសម្រាកបន្តិច ។ សុំមានការពិភាក្សា ។

*[មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសម្រាកដើម្បីធ្វើការពិភាក្សាគ្នារយៈពេលពីរនាទី]*

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានបំណងចង់និយាយបញ្ហាអីទៅ?

[១១:៤៤:១៥]

**លោក អាឡាំង វ៉ែនណឺ៖**

លោក លោកស្រីចៅក្រម យើងខ្ញុំចង់ថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះប៉ុន្មាននាទី ដើម្បីនិយាយអំពីនីត្យានុកូលភាព ហើយយើងខ្ញុំសូមធ្វើការស្នើសុំរយៈពេលប៉ុន្មាននាទីដើម្បីនិយាយអំពីបញ្ហានីត្យានុ-កូលភាព ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ គឺមេធាវីមានការប៉ុនប៉ងលើកឡើងអំពី និត្យានុកូលភាពដែលមិនមានចំណុចជាក់លាក់អំពីបញ្ហានេះ ។ ហើយបញ្ហានីត្យានុកូលភាពដែលលើកឡើងដោយមេធាវីការពារក្តីហ្នឹងបានកន្លងផុតទៅហើយ ។ ដោយឡែក បញ្ហាការជជែកចុងក្រោយនេះ គឺទាក់ទិនជាមួយនឹងសំណើសុំរបស់មេធាវីការពារក្តីអន្តរជាតិ ដែលបានលើកឡើងអំពីសំណូមពរសុំពិនិត្យពិចារណាសម្រេចឲ្យកូនក្តីរបស់គាត់បាននៅក្រៅឃុំជាបណ្តោះអាសន្ន ឬក៏ក្រៅឃុំបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌដាក់នៅអគារមួយដែលមានសុវត្ថិភាព ។ ហើយបញ្ហានេះវាពាក់ព័ន្ធទៅនឹងការអនុវត្តនូវវិធាន៨២ ។ នៅក្នុងវិធាន៨២.២ និងវិធាន៨២.៣ នេះ នៅក្នុងកិច្ចពិភាក្សាសម្រេចអំពីបញ្ហានេះ គឺអង្គជំនុំជម្រះស្តាប់តែជនជាប់ចោទ មេធាវីជនជាប់ចោទ និងសហព្រះរាជអាជ្ញាប៉ុណ្ណោះ ដោយមិនមានការបង្ហាញអំពីសិទ្ធិនៃមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអន្តរាគមន៍ពាក់ព័ន្ធទៅនឹងបញ្ហានេះទេ ។ ដូច្នេះ អង្គជំនុំជម្រះអនុវត្តយ៉ាងតឹងរ៉ឹងនូវវិធាន៨២.២ និងវិធាន៨២.៣ ផងដែរ ។ ហើយដោយសារបញ្ហានេះជាបញ្ហាដែលត្រូវជជែកពិភាក្សាសម្រេចយ៉ាងល្អិតល្អន់នោះ គឺ--

មានបញ្ហាអីទេ?

[១១:៤៨:៣០]

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

*(គ្មានការបកប្រែ)* ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

លោកប្រធាន លោក លោកស្រីចៅក្រុមជាទីគោរព ! តើយើងអាចស្នើសុំឲ្យធ្វើការពិចារណាសេចក្តីសម្រេចរបស់លោកចៅក្រុមសាជាថ្មី ។ ហើយយើងរំឭកទៅលើសេចក្តីសម្រេចនៅ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ របស់អង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចនោះ គឺចែងអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបញ្ហាចោទ ដែលថាដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួម តែមិនត្រឹមលក្ខណៈរូបវន្តប៉ុណ្ណោះទេ ចូលរួមដោយផ្ទាល់តែប៉ុណ្ណោះទេ គឺគាត់អាចចូលរួមនៅក្នុងការបណ្តឹងឧទ្ធរណ៍ទៅលើការឃុំខ្លួនបណ្តោះអាសន្នផងដែរ ។ ហើយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបានចែងអំពីការពន្យារទៅលើការពង្រីកទៅសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ខ្ញុំសូមរំឭកថា ជាការពិតណាស់តុលាការនេះគួរតែអនុវត្តឲ្យបានស្របគ្នា ទោះបីជាសិទ្ធិនេះ

សេចក្តីសម្រេចនេះទាក់ទងទៅនឹងសិទ្ធិសារវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ដែលបានចេញដោយអង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តី នួន ជា ។

ខ្ញុំសូមអនុញ្ញាតឲ្យលោក លោកស្រីចៅក្រមជ្រាបថា ហេតុអ្វីបានជាអង្គបុរេជំនុំជម្រះគាត់សម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងផលប្រយោជន៍របស់គាត់ ដែលពាក់ព័ន្ធ ថាប្រសិនបើជនជាប់ចោទ គាត់ធ្វើការប្តឹងប្រឆាំងនឹងការឃុំខ្លួន ឬក៏សុំឲ្យមានការដោះលែងឲ្យមានសេរីភាពនោះ អង្គបុរេជំនុំជម្រះបានលើកឡើងថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសសិទ្ធិក្នុងការទាមទារសំណងគឺនឹងអាចប៉ះពាល់ ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីគួរតែអនុវត្តសិទ្ធិរបស់ខ្លួន ។ នេះជាឧទាហរណ៍មួយនៅក្នុងអំឡុងពេលអង្គបុរេជំនុំជម្រះបើកសវនាការ ។ ហើយដែលគួរតែយើងដាក់សេចក្តីសន្និដ្ឋានដើម្បីធ្វើការសង្កេតនៅក្នុងសវនាការ ។

យើងនៅទីនេះ ប្រសិនបើយើងប្រៀបធៀបដំណាក់កាលមុនអង្គសេចក្តី យើងស្នើសុំធ្វើការសន្និដ្ឋានចំពោះការស្នើសុំរបស់មេធាវីក្នុងការដោះលែងជនជាប់ចោទ ហើយគឺយើងអាចមើលឃើញថាស្ថានភាពនេះគឺដូចគ្នានៅពេលដែលមេធាវីការពារក្តីរបស់ជនត្រូវចោទ គាត់បានប្តឹងទៅលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។ ហើយវាដូចនឹងករណីដែលប្តឹងពន្យារ ប្តឹងឧទ្ធរណ៍ចំពោះការពន្យារការឃុំខ្លួននៅក្នុងរឿងក្តីទីពីរផងដែរ ។

ដូច្នេះ អង្គសាលាដំបូងគួរតែពិចារណាទៅលើបញ្ហានេះ ទាក់ទងទៅនឹងវិធាន៨២ ដោយការពិចារណាទៅលើបញ្ហាដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីរបស់ពួកគេ ដោយមិនបានចែងនៅក្នុងវិធាន ៨២.២ និង៣ នោះទេ ។ ដូច្នេះ យើងត្រូវមើលអំពីសិទ្ធិ និងចំណុចត្រឹមត្រូវនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺយើងមិនមើលទៅលើចំណុចផ្សេងៗនោះទេ ។

ចំណុចទីពីរ៖ ដើមបណ្តឹងរដ្ឋប្បវេណី គឺមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់មេធាវីការពារក្តី ។ ហើយជាការពិតណាស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងន័យនេះ ជាក្តីព្រួយបារម្ភ និងការថ្លែងប្រាស្រ័យរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរតែយកមកពិចារណា ។ ហើយនេះសិទ្ធិសារវន្តដ៏សំខាន់មួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺសិទ្ធិក្នុងការថ្លែងប្រាស្រ័យ ។ ដូច្នេះ ហើយបញ្ហានេះ គឺវាពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់តែម្តង ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាសេចក្តីសម្រេចរបស់ខ្លួនចាប់ពីថ្ងៃនេះទៅថាដើមបណ្តឹងរដ្ឋប្បវេណី គឺអាចមានជំហរ ហើយសូមឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើ

ការពិចារណា និងធ្វើការឡើងវិញ ដើម្បីឲ្យមានភាពស៊ីគ្នានៅក្នុងយុទ្ធសាស្ត្ររបស់តុលាការនេះ ។ ហើយឲ្យធ្វើយ៉ាងណា ឲ្យសេចក្ដីសម្រេចនោះគឺ ឲ្យមានលក្ខណៈស្របទៅនឹងសេចក្ដីសម្រេចថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ។ ដូច្នេះហើយ យើងត្រូវពិចារណាទៅលើបញ្ហាដែលពាក់ព័ន្ធនេះ ហើយអង្គជំនុំជម្រះសាលាដំបូង គឺមិនត្រូវធ្វើការចាប់យកជំហរណាមួយដែលវាផ្ទុយទៅនឹងករណីដែលថា វាមិនមានចែងនៅក្នុងវិធាន៨២.២ និង ចុច៣ នោះទេ ។ ដូច្នេះនេះជាទឡ្ហីករណ៍មួយ ដែលជាទឡ្ហីករណ៍ផ្លូវការចំពោះចំណុចនេះ ។

**អ្នកបកប្រែ៖**

សូមអភ័យទោសអ្នកបកប្រែស្ដាប់អត់ឮ ។

**ប្រធានអង្គជំនុំ៖**

ស្ដាប់បានហើយ? ហើយឲ្យវ៉ាយរ៉ាប់ហ្នឹង គឺប្រហែលជាមួយថ្ងៃទៀតក៏ប្រហែលអត់ចប់ដែរ ។ អ៊ីចឹង គឺសូមណូមពរនេះអង្គជម្រះនឹងយកទៅពិចារណាក្នុងការសម្រេច ។

មានអ្វីផ្សេងទៀតទេ?

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនដឹងថា តើមីក្រូហ្វូនកាត់ផ្ដាច់នៅពេលណា? ថាតើមានលទ្ធភាពអាចបកប្រែបានដែរឬអត់ ? ខ្ញុំមិនបានឃើញថា ដូច្នេះ ខ្ញុំសូមអនុញ្ញាតការណែនាំពីលោកប្រធានក្នុងករណីនេះ ។

**ប្រធានអង្គជំនុំ៖**

គឺថា អ្វីដែលលោកស្រីបានលើកឡើង អង្គជំនុំជម្រះនឹងយកទៅពិចារណាថ្លឹងថ្លែងនៅក្នុងអំឡុងពេលសម្រាកហូបអាហារថ្ងៃត្រង់នេះ ហើយនៅពេលចូលមកវិញ យើងនឹងប្រកាសសម្រេចអំពីបញ្ហាសិទ្ធិរបស់-- ការចូលរួមក្នុងការថ្លែងនូវមតិយោបល់របស់ភាគីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធជាមួយបញ្ហាការប្ដឹងសុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ននេះ ដោយប្រៀបធៀបទៅនឹងវិធានដែលមានចែងនៅក្នុងមាត្រាវិធាន៨២ និងសាលដីការបស់អង្គបុរេដែលលោកស្រីបានលើកឡើងជាមូលដ្ឋានអម្បាញ់មិញនេះ ។

ច្បាស់ទេ? ច្បាស់លាស់ទេ?

[១១:៥៦:២៨]

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

លោកប្រធាន ចំណុចទីមួយ ខ្ញុំសុំអនុញ្ញាតសូមការបញ្ជាក់ថា តើផ្នែកណាមួយដែលគប្បីបកប្រែមុនក្រោយនៅពេលណា ដែលមានការកាត់ផ្តាច់មីក្រូហ្វូននេះ? ហើយបន្ទាប់មកចំណុចទីពីរ ខ្ញុំសូមអនុញ្ញាត សុំការណែនាំប្រសិនលោកប្រធានយកពិចារណាចំណុចមួយដែលថា ទាក់ទងទៅសំណើរបស់មេធាវីការពារនោះ ។ ចំណុចទីមួយ លោកប្រធានអង្គជំនុំជម្រះគប្បីពិចារណា សំណើសុំពិចារណាឡើងវិញ ដូចដែលបានធ្វើនៅក្នុងអង្គបុរេជំនុំជម្រះជាយុទ្ធសាស្រ្តមួយមកនោះ ។

**លោកស្រី ម៉ាទីន ហ្សាកហ្វើន៖**

ខ្ញុំសូមធ្វើមតិមួយចំនួន ខ្ញុំតំណាងឲ្យក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី បានលើកឡើងទៅមាត្រា៨២ វិធាន៨២ បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការសម្រេចលើសំណើរនេះ គឺដោយមិនស្តាប់មតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ធ្វើដូច្នេះគឺជាខុសទេ? ពីព្រោះលោក ឌុច គឺថាគាត់ស្នើសុំនៅក្រៅឃុំ គឺជាកត្តាសំខាន់ណាស់នៅក្នុងករណីនេះ ។ នៅក្នុងវិធាន៨២ យើងបានលើកយកមកប្រើជាលើកដំបូងចំពោះមុខអង្គជំនុំជម្រះនេះ ។ ពីព្រោះថា មានបណ្តឹងឧទ្ធរណ៍បានធ្វើឡើងចំពោះមុនអង្គបុរេរួចហើយផងដែរ។ លោក លោកស្រីចៅក្រមអាចធ្វើសវនាការភាគីណាមួយក៏បានតាមឆន្ទានុសិទ្ធិ ។ ហើយខ្ញុំគិតថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិរបស់ខ្លួនដែរ ខ្ញុំនឹកឃើញថា ដែលថា លោក ឌុច បានសម្តែងវិប្បដិសារី ហើយនិងសម្តែងការសោកស្តាយ ហើយសូមឲ្យមានការអភ័យទោស ។ ក្រៅពីនោះគឺថាគាត់បានស្នើសុំឲ្យនៅក្រៅបណ្តោះអាសន្ន ដោយផ្អែកឡើងលើទឡ្ហីករណ៍មួយចំនួន ហើយនិងការអះអាងមួយចំនួន ហើយស្នើសុំផ្អែកទៅតាមច្បាប់ទៅលើទឡ្ហីករណ៍ដែលខ្លួនបានលើកនោះ ។

គាត់បាននិយាយអំពីភាពយុត្តិធម៌ ហើយខ្ញុំគិតថា គឺថាមានទទួលស្គាល់ជាអប្បបរមាស្តីពីការទទួលស្គាល់សិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងសវនាការ ។ ក្នុងករណីនេះកាតព្វកិច្ចរបស់លោក ឌុច នោះគឺថា ជាបញ្ហាមួយថា តើគាត់អាចនិយាយដូចម្តេចបាន? បើថាគាត់មានការវិប្បដិសារីហើយនិងសោកស្តាយ ហើយក្រោយមកថ្ងៃទីពីរ គាត់បែរជាស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នទៅវិញ?

ខ្ញុំពិនិត្យឃើញថា ព្រឹកនេះគឺថា យើងបានអាចនឹងអានអង្គហេតុមួយម្តងៗ ដែលលោក ឌុច បានវត្តមានផងដែរ ។ ហ្នឹងពិនិត្យមើលថា តើភាពធ្ងន់ធ្ងរយ៉ាងដូចម្តេចដែលលើកឡើងនៅក្នុងអង្គហេតុថ្ងៃនេះ? ប៉ុន្តែ ក្នុងចំណុចនេះគឺថា ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបាត់បង់សមាជិកក្រុមគ្រួសាររបស់ខ្លួន ហើយយើងត្រូវចាំក្នុងចិត្តថា ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា១០០ ឬក៏លើសពីហ្នឹង ដែលខ្ញុំតំណាង

ឲ្យនោះ គឺជាមនុស្សដែលបានស្ថិតនៅក្នុងការលំបាក ហើយប្រឈមនឹងបទពិសោធន៍ដ៏លំបាក បន្ទាប់ពីមានការចប់ផុតរលត់នៃរបបកម្ពុជាប្រជាធិបតេយ្យនោះហើយក្ដី ។

**ប្រធានអង្គជំនុំ៖**

និយាយត្រឹមតែប្រាំមីនុតប៉ុណ្ណោះ ។

អញ្ជើញ ។

**លោក ព្យែរ អូលីវីយេ ស័រ៖**

ខ្ញុំលើកបីចំណុចក្នុងរយៈពីរនាទី ។ ក្នុងពេលសវនាការមុនអង្គសេចក្ដី អ្វីដែលខ្ញុំបានដឹង ដើមបណ្ដឹងរដ្ឋប្បវេណី គឺមិនមានការចូលរួមនឹងក្នុងការដាក់ទោស ។ ប៉ុន្តែ វាជាភាពចាំបាច់ ហើយវាសំខាន់ណាស់ក្នុងការឆ្លើយតបចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្ដី ដែលវាពាក់ព័ន្ធទៅនឹងបញ្ហានៃការឃុំខ្លួនបណ្ដោះអាសន្ន ។ ហើយវាទាក់ទងទៅនឹងច្បាប់នៅក្នុងប្រព័ន្ធ ស៊ីវិលឡ ដែលយើងមាននៅក្នុងតុលាការចម្រុះនេះ ។

ចំណុចទីពីរ គឺជនរងគ្រោះ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានចូលរួមនៅក្នុងនេះ ហើយនៅក្នុងរឿងក្ដីនៅចំពោះមុខលោក លោកស្រីចៅក្រម ។ ដូច្នេះ ថាតើយើងអាចយ៉ាងម៉េច? មានលទ្ធភាពយ៉ាងម៉េចថា គាត់មានសិទ្ធិតិចតួចនៅក្នុងសវនាការសាធារណៈ មានសិទ្ធិតិចតួចតែប៉ុណ្ណោះនៅពេលដែលយើងគិតអំពីដំណើរការស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត ។ ដូច្នេះ ហើយយើងត្រូវគិតចំណុចនេះ ។

ហើយចំណុចទីបី យើងមានវិធាន៨២ ហើយក៏យើងមានវិធាន៧៣ ដែលវាមានលក្ខណៈដូចគ្នាដែលអនុវត្តចំពោះដំណាក់កាលស៊ើបអង្កេត ។ ហើយនៅក្នុងនោះយើង លោក លោកស្រីចៅក្រមមានការកម្រិតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយអនុវត្តមាត្រា៧៣ និងវិធាន៧២ វិធាន៧៣ និងវិធាន៨២ ។ ដូច្នេះហើយ គវិធានទាំងពីរនេះគួរតែយើងយកមកពិចារណាជាមួយគ្នា ដោយយើងពិចារណាអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណើរនីតិវិធី និងនៅក្នុងពេលជំនុំជម្រះ ។ ដូច្នេះហើយយើងគួរតែ-- យើងអាចក្នុងថ្លែងប្រាស្រ័យជូនលោកចៅក្រមចំពោះបញ្ហានេះ ។ ហើយយើងគួរតែលើកអំពីបញ្ហាសេរីភាពរបស់ ឌុច ថាតើគាត់គួរតែត្រូវបានគេឃុំខ្លួនដែរឬទេ? ដូច្នេះវាជាបញ្ហាសំខាន់របស់យើងខ្ញុំ ។

[១២:០៣:១១]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញ យើងបានប្រាប់ហើយថា យើងអង្គជម្រះធ្វើការកត់សម្គាល់នូវបញ្ហានេះ ហើយដោយហេតុផលនៃការលើកឡើងប្រៀបធៀបរវាងបទវិធានដែលមានចែងនៅក្នុងវិធាន៨២ ចំណុចអនុវិធានទី២ និងទី៣ ហើយក៏បានលើកអះអាងពាក់ព័ន្ធជាសាលដីកា ដែលចេញដោយអង្គបុរេជំនុំជម្រះនោះ យើងអង្គជម្រះនឹងកត់ត្រាយកអ្វីដែលបានលើកឡើងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ ទៅពិចារណានៅក្នុងអំឡុងពេលនៃអាហារថ្ងៃត្រង់នេះ ហើយនិងសម្រេចនៅពេលដែលត្រឡប់មកចូលដំណើរសវនាការនៅរសៀលនេះវិញ ។

ដោយសារពេលវេលាដល់ពេលអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសូមប្រកាសសម្រាក ដើម្បីអាហារថ្ងៃត្រង់ត្រឹមពេលនេះ ហើយរហូតដល់ម៉ោងមួយ និងសាមសិប នាទីរសៀល សូមអញ្ជើញចូលវិញ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅកាន់បន្ទប់រង់ចាំ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកសាលសវនាការវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់ ។

*(សវនាការសម្រាកពីម៉ោង១២:០៥នាទី ដល់ម៉ោង១៣:៥២នាទី)*

[១៣:៥២:០០]

**លោកស្រី សែ កុលវុឌ្ឍី៖**

អញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការលើរសៀលនេះតទៅទៀត ។

ជាកិច្ច ដំបូងនេះ សូមជម្រាបសួរទៅលោកមេធាវីការពារជនជាប់ចោទ តើលោកមេធាវី ឬក៏ជនជាប់ចោទមានអ្វីឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែរឬទេ? ពាក់ព័ន្ធនឹង ដែលបានឆ្លើយតបពាក់ព័ន្ធនឹងការស្នើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងកាលពីព្រឹកមិញ ។ បើមានសូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប៉ុស្តិ៍ខ្មែរ តើលោក លោកស្រីស្តាប់ឮប៉ុស្តិ៍ខ្មែរ ?

មេធាវីការពារក្តីមិនមានអ្វីឆ្លើយតបនោះទេ បន្ទាប់ពីសហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋាន គឺមេធាវីនៅតែរក្សាជំហរដដែល ហើយយើងខ្ញុំមិនសូមមានលក្ខណៈជឿជាក់ទៅលើសេចក្តីសន្និដ្ឋានដែលដាក់ជូនដោយសហព្រះរាជអាជ្ញានោះទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជម្រះសូមជម្រាបទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពីព្រឹកមិញ ដែលបានលើកឡើងអំពីសំណើសុំបញ្ចេញមតិយោបល់ ឬក៏ការកត់សម្គាល់តបទៅនឹងការដែលលើកឡើងរបស់មេធាវីការពារក្តី ដែលបានសុំឲ្យជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្ននៅក្នុងអំឡុងពេលសវនាការ ។

អង្គជម្រះសូមជម្រាបថា អង្គជម្រះនឹងលើកបញ្ហានេះទៅពិនិត្យពិចារណានៅក្នុងថ្ងៃស្អែក និងខានស្អែក ដើម្បីរិះរកនូវបទប្បញ្ញត្តិ ឬក៏វិធានណាដែលសមស្រប ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវសិទ្ធិបញ្ចេញមតិសេចក្តីថ្លែងជាសចក្តីសន្និដ្ឋាន ឬកត់សម្គាល់របស់មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ ហើយការឆ្លើយតបហ្នឹង យើងនឹងជម្រាបជូនជាលើកដំបូងគេបង្អស់នៅកម្មវិធីដែលដំណើរការនៅថ្ងៃច័ន្ទ ទី០៦ ខែមេសា ឆ្នាំ២០០៩ ។

ជាកិច្ចបន្តសូម-- សូមអញ្ជើញ ។

[១៣:៥៦:៣២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព ប្រសិនបើអង្គជំនុំជម្រះនឹងធ្វើការសម្រេចទៅលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំសូមធ្វើដាក់ជូនទៅលើការយល់ឃើញរបស់ខ្ញុំ ។ ដើមបណ្តឹងរដ្ឋប្បវេណីគឺសូមឲ្យធ្វើការកែប្រែទៅលើសេចក្តីសម្រេច ។ ដូច្នេះ ការពារក្តីមានចំណុចត្រូវលើកឡើងចំពោះការកែប្រែទៅលើសេចក្តីសម្រេចនេះ ហើយខ្ញុំសូមបង្ហាញជំហររបស់មេធាវីក្នុងរយៈពេលប៉ុន្មាននាទី ដើម្បីឆ្លើយតបទៅលើការស្នើសុំឲ្យកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី អង្គជំនុំជម្រះអនុញ្ញាត ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោក លោកស្រីចៅក្រម។ មេធាវីការពារក្តីកត់សម្គាល់អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចង្អុលបង្ហាញ ដោយអនុលោមតាមវិធាន៨២ ។ នៅក្នុងនោះបញ្ជាក់ថា

ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋាន ចំពោះសំណើសុំដោះលែងឲ្យមានសេរីភាពជូនអង្គជំនុំជម្រះ ហើយយើងមិនត្រូវបកស្រាយច្បាប់ទេ ប៉ុន្តែ យើងចង់កែប្រែទៅលើច្បាប់ ។

ខ្ញុំជឿថា លោក លោកស្រីចៅក្រមមានអំណាចក្នុងការបកស្រាយច្បាប់ ហើយខ្ញុំតតាំងរយៈច្រើនឆ្នាំហើយ ដើម្បីផ្តល់លទ្ធភាពឲ្យលោកចៅក្រមក្នុងការបកស្រាយច្បាប់ ។ ប៉ុន្តែ នៅទីនេះ គឺវាមានលក្ខណៈខុសគ្នា ។ យើងមិនសុំឲ្យលោក លោកស្រីចៅក្រមធ្វើការបកស្រាយច្បាប់ទេ យើងឲ្យលោកលោកស្រីធ្វើការកែប្រែ ដោយផ្អែកទៅលើមូលដ្ឋានដែលថាវាមានកំហុស ។

ដូច្នេះ ខ្ញុំសូមជម្រាបថា មានតែចៅក្រមក្នុងកិច្ចប្រជុំពេញអង្គទេ ដែលមានសមត្ថកិច្ចក្នុងការធ្វើវិសោធនកម្មលើវិធានមួយនេះ ។ អង្គជំនុំជម្រះមិនមានសមត្ថកិច្ច ឬយុត្តាធិការក្នុងការវិសោធនកម្មវិធានទេ ។ ដូច្នេះ ខ្ញុំមិនយល់ឃើញថា យើងដាក់សំណើហ្នឹងតាមរបៀបណានោះទេ ។ ហើយចំពោះខ្លឹមសារនូវអ្វីដែលខ្ញុំលើកឡើង ខ្ញុំអាចគិតឃើញថា ប្រសិនបើកិច្ចប្រជុំពេញអង្គនៅក្នុងឧត្តមគតិ ឬការយល់ឃើញរបស់ចៅក្រមបានរសរសេរច្បាប់ដូច្នេះហើយ ដោយសារតែកិច្ចប្រជុំពេញអង្គជឿជាក់ថាសវនាការដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួន គឺមិនមានអ្វីជាប់ទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

[១៣:៥៩:៥២]

ដូច្នេះ គឺវាទាក់ទងទៅនឹងកិច្ចពិភាក្សាដែលយើងមានរួចហើយនៅក្នុងច្បាប់ ដែលមានចែងច្បាស់លាស់ចំពោះភាគីនៅក្នុងដំណើរការព្រហ្មទណ្ឌ ។ ដើមបណ្តឹងរដ្ឋប្បវេណីគឺទទួលស្វាគមន៍ ។ យើងស្វាគមន៍គាត់ឲ្យលើកឡើងអំពីការឈឺចាប់របស់គាត់ ជាការពិត ។ ប៉ុន្តែ ចំណុចណាក៏ដោយដែលវាពាក់ព័ន្ធទៅនឹងការសុំឲ្យដោះលែងមានសេរីភាព ការពាក់ព័ន្ធនឹងការដាក់ទោស គឺជាបញ្ហាចោទ ដែលវាពាក់ព័ន្ធទៅនឹងផលប្រយោជន៍សាធារណៈ ។ បានន័យថា គឺស្ថិតក្នុងការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញា ហើយនឹងស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការសង្កេតបានតែប៉ុណ្ណោះនៅក្នុងករណីឃុំខ្លួន និងការដោះលែងបណ្តោះអាសន្ន ប្រសិនបើបញ្ហានោះវាមានផលប៉ះពាល់លើផលប្រយោជន៍របស់ពួកគេ ។ ខ្ញុំនិយាយអំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំចង់រំឭកអស់លោក លោកស្រីចៅក្រមថា យើងនិយាយអំពីបញ្ហាសំណងនៅទីនេះ ចំពោះជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ អ៊ីចឹង ភាគីគាត់បានពន្យល់យើងកាលពីថ្ងៃមុន ហើយអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់ពន្យល់ គឺយើងមិនសូវមានលក្ខណៈ

គួរឲ្យជឿជាក់នោះទេ ។ ប៉ុន្តែ ការឃុំខ្លួន គឺយើងត្រូវតែដឹងថា វាជាផ្នែកមួយនៃការដាក់ទោស ។ ដូច្នេះ នៅទីនេះយើងមិនស្ថិតនៅក្រោមវង្វង់នៃសិទ្ធិសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

នៅពេលដែលចៅក្រម នៅកិច្ចប្រជុំពេញអង្គបានបង្កើតច្បាប់ គឺគោលគំនិតគេបានបញ្ជាក់ដូច្នេះ ។ ដូច្នេះ វិធាននៅក្នុងនោះ ដែលអង្គបុរេជំនុំជម្រះព្យាយាមរកលទ្ធភាពបើកសិទ្ធិនៅក្នុងនេះ ដូចដែលនៅ តុលាការព្រហ្មទណ្ឌផងដែរ គឺគេព្យាយាមក្នុងការធ្វើការផ្តល់សិទ្ធិទៅដល់ជនរងគ្រោះ ហើយធ្វើការបង្កើតច្បាប់ ហើយព្យាយាមបង្កើតចំណុចរបត់មួយ ថាតើភាគីណា គាត់មានកាតព្វកិច្ចនិងសិទ្ធិធ្វើអ្វីខ្លះនៅក្នុងដំណើរការនីតិវិធីនេះ?

ខ្ញុំជឿថាតុលាការព្រហ្មទណ្ឌអន្តរជាតិ បន្ទាប់ពីនៅក្នុងរឿងក្តី *លូបាងហ្គា* គឺបាន គាត់បានបើកឲ្យមានការចូលរួមពីជនរងគ្រោះនៅក្នុងដំណើរការក្តី ហើយសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌមានលក្ខណៈចម្លែកក្រោយមក ។ ដោយសារតែវាមិនមានលក្ខណៈជាក់ស្តែង ហើយខ្ញុំជឿថា អ្វីដែលលោក លោកស្រីចៅក្រមគិតទុកនៅក្នុងពេលដែលបង្កើតវិធានផ្ទៃក្នុង ។ នៅសវនាការទីមួយ យើងមានដើមបណ្តឹងរដ្ឋប្បវេណី៩៤ ហើយរឿងក្តីក្រោយទៀតយើងមានដើបណ្តឹងរដ្ឋប្បវេណីរហូតដល់រាប់រយ។ ថាតើយើងគួរតែស្តាប់គាត់និយាយគ្រប់ប្រធានបទទាំងអស់ចំពោះអ្វីដែលគាត់ចង់លើកឡើង? អ៊ីចឹងគឺគាត់នឹងលើកឡើងចំពោះបញ្ហាផ្សេងៗគ្រប់បែបយ៉ាង ។

ដូច្នេះយើងនឹងរារាំងបញ្ហានៃការរកយុត្តិធម៌ ។ ដូច្នេះ ហើយយើងគួរតែគោរពទៅលើ-- ហើយយើងគួរតែគិតអំពីចំណុចរបត់នេះ ។ ហើយខ្ញុំសូមដាក់ជូនថា យើងនឹងស្តាប់សេចក្តីថ្លែងរបស់លោកដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែសូមធ្វើការអនុញ្ញាតសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីកុំចង់លើកឡើងនូវអ្វីដែលវាមិនពាក់ព័ន្ធនឹងផលប្រយោជន៍របស់លោក លោកស្រី ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជម្រះមិនអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានមតិយោបល់អ្វីផ្សេងទៀតទេ ។ យើងចាប់បន្តកិច្ចនីតិវិធីបន្តទៅទៀត ។

សូមអញ្ជើញសហព្រះរាជអាជ្ញាឡើងធ្វើការអាននូវអង្គហេតុដែលបានព្រមព្រៀងរវាងសហព្រះរាជអាជ្ញាជាមួយនឹងមេធាវីការពារជនជាប់ចោទ ព្រមទាំងអង្គហេតុដែលមិនមានការតវ៉ាផង ។

សូមអញ្ជើញ ។

[១៤:០៥:២៤]

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងព្យាយាមអានឲ្យបានច្បាស់ ហើយសង្ខេបតាមដែលខ្ញុំអាចធ្វើទៅបាន ។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ ខ្ញុំចងចាំថានៅក្នុងតុលាការនេះ យើងមានប្រតិចារឹក ហើយអាចនឹងប្រើជាកំណត់ត្រាឯកសារ ។

ខ្ញុំព្យាយាម ហើយនិងដាក់បញ្ចូលនូវព័ត៌មានឲ្យបានច្រើនបំផុតដែលអាចធ្វើទៅបាន ដែលថាការកត់ត្រាហ្នឹងនឹងកត់បានព័ត៌មានត្រឹមត្រូវទាំងអស់ ។ ដូច្នេះ សូមអញ្ជើញ លោកស្រីចៅក្រម-- ខ្ញុំនឹងអានជាភាសាអង់គ្លេសជូន ហើយនិងមានការបកប្រែ ហើយក៏មានការឯកភាព ទៅលើអត្ថបទបារាំង ហើយអ្នកបកប្រែក៏មានអត្ថបទជាភាសាបិទនៅក្នុងដៃនោះដែរ ។

ដើម្បីបំភ្លឺដូចយើងបានបញ្ជាក់ពីខាងដើមនោះ នៅថ្ងៃទី៣១ នៅខែមករា នៃឆ្នាំនេះ យើងបានបញ្ជូនទៅផ្នែកការពារក្តី គឺថានៅក្នុងដីកាដំណោះស្រាយ នឹងបំបែកនូវអង្គហេតុដើម្បីឲ្យគេផ្តល់ការបញ្ជាក់ការឯកភាព ។ ឯកសារនេះក៏បានត្រូវបានដាក់ជូននូវឯកសាររបស់យើង ត្រូវបានដាក់ចូលទៅក្នុងកំណត់ត្រាសំណុំរឿងនៅថ្ងៃទី១១ កុម្ភៈ ឆ្នាំ២០០៩ ។ តាមសេចក្តីដកស្រង់នៅក្នុង *អ៊ីប្រាំ លើដប់មួយ លើពីរ* (E5/11/2) គឺថាពីរប្រាំពីរ *អ៊ីអរអិន* ០០២ ៨២១១៥ ០០២៨២១៥ នេះជាឯកសារ ដែលត្រូវបានផ្ញើជូនទៅផ្នែកការពារមេធាវីការពារ ហើយដាក់ចូលក្នុងសំណុំរឿង ។

យើងមិនបានទទួលអ្វីជាការដាក់ជូនឯកសារជាផ្លូវទាក់ទងទៅនឹងការឆ្លើយតបនោះទេ ប៉ុន្តែ នឹងចាត់ទុកជាអត្ថបទដែលចូលក្នុងសំណុំរឿង ហើយជាឯកសារ(ឮមិនច្បាស់) នៅក្នុងសំណុំរឿងរបស់យើង ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតដើម្បីអាននូវអង្គហេតុដែលបានយល់ព្រម ហើយនិងអង្គហេតុដែលមិនមានការតវ៉ា ម្យ៉ាងទៀតគឺថាអ្វីៗដែលមេធាវីការពារបានឯកភាព ឬក៏មិនបានតវ៉ានៅក្នុងការជំនុំជម្រះនេះ យើងខ្ញុំសូមអនុញ្ញាត ខ្ញុំសូមយោងទៅរកចំណុចទី១ គឺថាផ្នែកទី១ ដែលត្រូវបានបោះពុម្ព ចុះចូលនៅក្នុងដីកាដំណោះស្រាយ ដើម្បីបង្កើតរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ។ល។ និង ។ល ។ នូវអង្គហេតុ នីមួយៗ ខ្ញុំនឹងយោងទៅកថាខណ្ឌ លេខកថាខណ្ឌនៃឯកសារដែលបានផ្ញើជូនទៅខាងមេធាវីការពារ ។ នេះជាចំនួនដែលមាននៅលើវង់ក្រចកនៅក្នុងអង្គហេតុនីមួយៗបានលើកឡើងនោះ ។

[១៤:០៨:៤៧]

ដូចដែលខ្ញុំជម្រាបនោះ គឺបានផ្ទុះបញ្ចាំងចំណុចនីមួយៗនៅក្នុងឯកសារ ដែលដាក់ជូននៅថ្ងៃទី១

ខែកុម្ភៈ ឆ្នាំ២០០៩ ។ ហើយខ្ញុំនឹងនិយាយមួយផ្នែកម្តងៗ ដើម្បីឲ្យបានច្បាស់លាស់ទាក់ទងនឹងបញ្ហាអង្គហេតុនេះ ។

ជាថ្មីម្តងទៀត ដោយមានការអនុញ្ញាតពីលោក លោកស្រីចៅក្រម អង្គហេតុដូចខាងក្រោមនេះត្រូវបានឯកភាពយល់ព្រម ។

នៅក្នុងកថាខណ្ឌទី៣៖ នៅក្នុងអំឡុងពេលភាគច្រើននៃដំណើរការមន្ទីរនេះត្រូវបានដឹកនាំដោយមនុស្សម្នាក់ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានឯកភាព ។

កថាខណ្ឌទី៥៖ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦៨ ឌុច ត្រូវបានជាប់ទោស ហើយជាប់ពន្ធនាគារដោយមានទំនាក់ទំនងជាមួយបរទេស ហើយត្រូវបានដោះវិញ បន្ទាប់ពីរដ្ឋប្រហារ ៨មីនា ។

ទី៧៖ ចាប់ពីថ្ងៃ ១៩៧៥ ដល់១៩៧៩ ឌុច កាន់កាប់តួនាទីរបស់ខ្លួននៅ ស-២១ ហើយនេះជាផ្នែកមួយនៃ-- ឌុច ត្រូវបានរកឃើញថារស់នៅតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង នេះជាផ្នែកមួយទៀត ខ្ញុំសូមឲ្យមេធាវីបញ្ជាក់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស័រ រ៉ូ៖**

អរគុណលោកប្រធាន ខ្ញុំបញ្ជាក់ក្នុងនាមមេធាវីការពារ ការយល់ព្រមទៅលើអង្គហេតុ ទាំងអស់ដែលបានលើកឡើងនោះ អម្បាញ់មិញនេះ ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាបន្ត ។

**លោក រ៉ូបឺត ពេទីត៖**

ឥឡូវនេះ នៅក្នុងផ្នែកមួយទៀត និយាយពីការបង្កើតនូវរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ។ អង្គហេតុដូចខាងក្រោមនេះត្រូវបានឯកភាព៖

នៅក្នុងកថាខណ្ឌទី១០ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ--រំដោះជាតិកម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា បានចូលដល់ទីក្រុងភ្នំពេញ និងបានដណ្តើមកាន់កាប់អំណាចទាំងស្រុងដែលហៅកាត់ថា “រ.ជ.ប.ខ” បានចូលភ្នំពេញ ហើយកាន់អំណាច។ បញ្ហាបច្ចេកទេស ដូច្នេះហើយ យើងសូមឲ្យប្រដាប់គាត់ស្តាប់មួយទៀត ដែលគាត់ស្តាប់ឮបាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា សូមអញ្ជើញបន្ត ។

**លោក រ៉ូប៊ឺត ពើទីត៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងចាប់ផ្តើមកថាខណ្ឌ ។

នៅក្នុងផ្នែកនិយាយអំពីការបង្កើត ហើយនិងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ៖

កថាខណ្ឌ១០៖ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា បានចូលដល់ទីក្រុងភ្នំពេញ និងបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ។ បានយល់ព្រម ។

កថាខណ្ឌ១១៖ ជាមួយនឹងការបញ្ចប់សង្គ្រាមស៊ីវិលប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ លន់ នល់ បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តគោលនយោបាយឆ្ពោះទៅរក នៅក្នុងសេចក្តីដកស្រង់ ដំណាក់កាលបន្ទាប់នៃការកសាងបដិវត្តន៍សង្គមនិយម ។ អាហ្នឹងបានយល់ព្រម ។

ក្នុងអំឡុង៣ឆ្នាំ៨ខែ ២០ថ្ងៃ បក្សកុម្មុយនីស្តបានប្រើអំណាចយ៉ាងមានប្រសិទ្ធភាពទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានដាក់ចេញនូវគោលនយោបាយបំបែកទាំងស្រុងនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់របបសាធារណរដ្ឋខ្មែរ និងបង្កើតនូវអំណាចរដ្ឋបដិវត្តន៍ថ្មី ។ យល់ព្រម ។

គ) ការលុបបំបាត់មន្ត្រី និងអ្នកគាំទ្ររបបចាស់ ។ យល់ព្រម ។

គោលនយោបាយជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមានគោលដៅប្រែក្លាយប្រជាជនថ្មីឲ្យទៅជាកសិករ ។ យល់ព្រម ។

កថាខណ្ឌ១៥៖ ប្រជាជនថ្មីទាំងនេះភាគច្រើនជាអ្នករស់នៅទីក្រុង ព្រមទាំងកសិករដែលរស់នៅក្រោមរបបលន់នល់ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ខុសពីប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន ដែលភាគជាច្រើនជាកសិករស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងនៃរបបសាធារណរដ្ឋខ្មែរ ។ យល់ព្រម ។

កថាខណ្ឌ១៦៖ ការសម្លាប់ក្រៅច្បាប់ ដែលមានចរិតលក្ខណៈនយោបាយកើតឡើងតាំងពីដំបូងដោយអង្គភាពយោធា បន្ទាប់មកការសម្លាប់ទាំងនេះបានបន្តអនុវត្តតាមមន្ទីរសន្តិសុខនានាទូទាំងប្រទេស ។ យល់ព្រម ។

កថាខណ្ឌ១៧៖ នាខែកុម្ភៈ ក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំមហាសន្និបាតជាតិ

រណៈសិរ្សរួបរួមជាតិកម្ពុជា ហើយពេលនោះបានប្រកាសជាឱឡារិកតាមប្រព័ន្ធផ្សព្វផ្សាយថា ពួកមហាក្បត់ទាំង៧នៃសាធារណរដ្ឋខ្មែរនឹងត្រូវប្រហារជីវិតភ្លាមៗ ក្រោយថ្ងៃរំដោះពីបទក្បត់ជាតិ ។ យល់ព្រម ។

[១៤:១៤:៥៥]

ចាប់តាំងពីថ្ងៃរំដោះក្រុងភ្នំពេញរហូតដល់របបនេះដួលរលំ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ទោសសម្លាប់ជាច្រើននូវជនជាប់ចោទ ទាំងខុស ទាំងត្រូវ ។ យល់ព្រម ។

ទាកទងទៅនឹងការបង្កើត ហើយនិងចុងបញ្ចប់ (១៤) ការជម្លៀសដោយបង្ខំនូវអ្នកភ្នំពេញ ហើយនិងប្រជាជន ពលរដ្ឋបញ្ជូនទៅជនបទ ហើយបង្កើតសហករណ៍ ហើយធ្វើឲ្យប្រជាជនធ្វើការនៅក្រោមលក្ខខណ្ឌការងារដ៏លំបាក ដើម្បីបង្កើតនូវរបប--

កថាខណ្ឌ១៨៖ នៅក្នុងខែមីនា មហាសន្និបាតក៏បានប្រកាសជំហររបស់ខ្លួនចំពោះថ្នាក់ទាបនៃសាធារណរដ្ឋខ្មែរថា ពួកគេនឹងត្រូវបានកងកម្លាំងបដិវត្តន៍ស្វាគមន៍ ប្រសិនបើពួកគេឈប់ប្រើពួកក្បត់ទាំង៧ ។

កថាខណ្ឌ១៩៖ ប្រកាសដូច្នេះ មានន័យថា មន្ត្រីណាដែលមិនទាន់ចូលខាងបក្សកុម្មុយនីស្តកម្ពុជានឹងត្រូវបានសម្លាប់ដូចអ្នកទាំងនោះដែរ ។

នៅក្នុងមាត្រា៩ នៃរដ្ឋធម្មនុញ្ញបក្សកុម្មុយនីស្តកម្ពុជា ២៤ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានមធ្យោបាយមិនសមស្របសម្រាប់ឈ្លើសឹក ឬជនស៊ីវិល យន្តការច្បាប់ណាមួយសម្រាប់ការតវ៉ាចាប់ខ្លួន ក្នុងការឃុំខ្លួន និងការដាក់ទោសនោះទេ ។

កថាខណ្ឌ២៥៖ រចនាសម្ព័ន្ធច្បាប់សង្គមត្រូវបានជំនួសដោយមន្ទីរអប់រំកែប្រែ កន្លែងសួរចម្លើយនិងមន្ទីរសន្តិសុខសម្រាប់ឃុំខ្លួនប្រហារជីវិតអតីតមន្ត្រី ឬអ្នកគាំទ្ររបបសាធារណរដ្ឋ ហើយនិងអ្នកដែលប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងបក្សកម្ពុជា ។ ខ្ញុំនឹងសូមស្នើឲ្យចំណុចទាំងអស់ដែលខ្លួនឯកភាពហើយនិងមិនតវ៉ានៅក្នុងអង្គហេតុដែលបានលើកឡើងនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារ ។

**លោក ហ្វ្រង់ស័រ រ៉ូ៖**

មេធាវីការពារសូមបញ្ជាក់ថា ទាក់ទងទៅនឹងការ-- អ្វីដែលបានអាននេះ ទាក់ទងបរិបទនយោ-

បាយ និងបរិបទប្រវត្តិសាស្ត្រនោះ ហើយដូចដែលយើងបាននិយាយ គឺថាយើងបានឯកភាពលើកថាខណ្ឌមួយចំនួន ហើយកថាខណ្ឌមួយចំនួន ហើយយើងមិនតវ៉ាដូចដែលបានបញ្ជាក់ខាងដើមឡើយ ។ ប៉ុន្តែ ដើម្បីឲ្យយល់-- អង្គជំនុំជម្រះបានយល់ច្បាស់ហើយ គប្បីតែបញ្ជាក់នៅក្នុងឯកសារដែលយើងបានដាក់ជូនទៅអង្គជំនុំជម្រះម្សិលមិញនោះ ជួនកាលកន្លែងខ្លះ គឺថាមានដាក់អក្សរទ្រេតដែលយើងយើងមិននិយាយបញ្ជាក់នោះទេ ហើយយើងសូមផ្តោតទៅលើចំណុចនោះ ។ យោបល់ទាំងនោះ គឺត្រូវបានដាក់បញ្ចូលផងដែរ សូមអរគុណ ។

[១៤:១៨:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអរគុណលោកប្រធាន ផ្នែកមួយទៀតគឺទាក់ទងទៅនឹងការបង្កើត ស-២១ អង្គហេតុដូចខាងក្រោមនេះត្រូវបានឯកភាព ។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ឌុច បានចូល-- កោះហៅ ឌុច និង អ៊ិនលន ហៅ ណាត ទៅប្រជុំនៅស្ថានីយ៍រថភ្លើងភ្នំពេញ ក្នុងគោលបំណងបង្កើត រៀបចំផែនការបង្កើតមន្ទីរ ស-២១ ។

**លោក ហ្វ្រង់ស័រ រូ៖**

សូមឲ្យលោកអានយឺតបន្តិច ដើម្បីឲ្យអ្នកអានតាមទាន់ សូមអភ័យទោស ។

**លោក រ៉ូប៊ឺ ពេទីត៖**

ដូចបានជម្រាបលោកចៅក្រមហើយ គឺថាអ្នកបកប្រែមានអត្ថបទទាំង៣ភាសាហើយ ដូច្នេះខ្ញុំព្យាយាមសង្ឃឹមថាឲ្យចប់មុនម៉ោង៤ ដោយហេតុថាគេមានអត្ថបទ ។

យល់ព្រម, កថាខណ្ឌ៣០៖ សុន សេន បានតែតាំងណាតជាប្រធាន ស-២១ និងជាលេខាគណៈកម្មាធិការរបស់មន្ទីរនេះ ហើយ ឌុច ជាអ្នកអនុប្រធានក្រុមទទួលបន្ទុកក្រុមសួរចម្លើយ ។ យល់ព្រម ។

កថាខណ្ឌ៣១៖ ក្រោយពីកិច្ចប្រជុំនោះមក ឌុច បាននាំអតីតបុគ្គលិក ម-១៣មួយចំនួនមកទីក្រុងភ្នំពេញ ដើម្បីចូលរួមជាមួយកម្លាំងកងពលធំ ៧០៣ ។ យល់ព្រម ។

កថាខណ្ឌ៣២៖ ស-២១ បានចាប់ផ្តើមប្រតិបត្តិការពេញលេញក្នុងខែតុលា ឆ្នាំ១៩៧៥ ។

កថាខណ្ឌ៣៤៖ នៅខែមីនា ឆ្នាំ១៩៧៦ ណាត ត្រូវបានផ្លាស់ទៅសេនាធិការ ហើយតួនាទីជា

ប្រធាន និងជាលេខាមន្ទីរ ស-២១ របស់ណាត ត្រូវធ្លាក់ទៅលើ ឌុច ។ យល់ព្រម ។

[១៤:២០:០៣]

កថាខណ្ឌ៣៦៖ ឌុច បានរក្សាទុកនោះនៅថា-- បានបញ្ជាក់ថា ឃឹម វ៉ាត ហៅ ហ៊ រ ជាអតីតកម្មាភិបាលកងពលធំលេខ៧០៣ នៅទទួលបន្ទុកកិច្ចប្រចាំនៅដដែល ។ យល់ព្រម ។

កថាខណ្ឌ៣៧៖ សមាជិកទី៣ នៃគណៈកម្មាធិការនៃមន្ទីរស-២១ និងជាប្រធានស-២៤ មានឈ្មោះថា នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ។ យល់ព្រម ។

[១៤:២០:៣៣]

កថាខណ្ឌ៣៨៖ ក្រោមការដឹកនាំរបស់ ឌុច មន្ទីរស-២១ ត្រូវបានចែកចេញជាអង្គភាពជាច្រើនដែលមានតួនាទីរៀងៗខ្លួន ។ យល់ព្រម ។

កថាខណ្ឌសាម-- អង្គភាពការពារមាន ហ៊ រ និងអនុរបស់ខ្លួនឈ្មោះ ផល ជាអ្នកគ្រប់គ្រង ។

កថាខណ្ឌ៣៣(គ) សួស ធី មានតួនាទីទទួលបន្ទុកផ្នែកឯកសារហើយរាយការណ៍ជូន ឌុច តាមរយៈ ហ៊ រ ។ យល់ព្រម ។

[១៤:២១:០៨]

កថាខណ្ឌ៣៨(ង) មន្ទីរផ្នែកមួយចំនួនមានផ្នែកមួយមានផ្នែក ថតរូប ពេទ្យ ដាំស្ល និងព័ស្តុភារ។

*[មិនឮសំឡេងពីម៉ោង១៤.២១.១៩ ដល់ម៉ោង១៤.២៤.០៥]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ខាតវ៉ាយថ៍ ។

**លោកស្រី ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក *ពើទីត* បញ្ហាមួយចំនួន គឺថាលោកបានអានអត្ថបទដែលមិនបានគូសលុបនូវឯកសារនេះ ហើយខ្ញុំគិតថាដើម្បីសុំឲ្យប្រើរហស្សនាមដែលបានប្រើរួចហើយនោះ តែលោកបានប្រើជាពាក្យកាត់នៃឈ្មោះនោះវិញ ពីព្រោះថា អត្តសញ្ញាណនៃបុគ្គលមួយចំនួន គឺត្រូវបានដាក់ចូលទៅក្នុងអង្គហេតុដែលបានឯកភាពក្នុងដំណាក់កាលនេះ ។ ថាតើខាងលោកមេធាវី រូ គាត់ឯកភាពទេ? អ៊ីចឹង គាត់ឆ្លើយថា "បាន" ។

**លោក រ៉ូប៊ឺត ពើទីត៖**

បាទ ហើយខ្ញុំនឹងធ្វើដូច្នោះទៅតាមការហ្នឹង ។ សូមអភ័យទោស ខ្ញុំនឹងប្រើនូវពាក្យអក្សរកាត់នៃ

ឈ្មោះនោះគឺថាដែលខ្ញុំមិនថា សាក្សីនោះគឺថាដែលការពារនោះមិនត្រូវបានឡើងនោះទេ ។ អ៊ីចឹង ហើយខ្ញុំប្រើជា *អ៊ុនទីហ្សេល* ជាពាក្យកាត់ជំនួសវិញ ។ យល់ព្រម ។

កថាខណ្ឌ៣៨(ង)៖ វាមានផ្នែកមួយចំនួនទៀតរួមមានផ្នែកថតរូប, ពេទ្យ, ដាំស្ល និងភ័ស្តុភារ ។ យល់ព្រម ។

កថាខណ្ឌ៣៩៖ ឌុច គ្រប់គ្រងមន្ទីរស-២១ តាមឋានានុក្រមនិងបានបង្កើតប្រព័ន្ធរាយការណ៍គ្រប់ថ្នាក់ដើម្បីធានាថារាល់បញ្ជារបស់គាត់ត្រូវបានអនុវត្តភ្លាមៗនឹងជាក់លាក់ ។ យល់ព្រម ។

[១៤:២៥:៥៥]

កថាខណ្ឌ៤៣៖ ពីដំបូងស-២១ ស្ថិតនៅក្នុងភ្នំពេញ នៅសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ។ ចំណែកឯមន្ទីរឃុំឃាំងនិងសួរចម្លើយស្ថិតនៅក្នុងផ្ទះមួយប្លុកត្រង់កាច់ជ្រុងផ្លូវ១៦៣និង៣៦០ ។ យល់ព្រម ។

កថាខណ្ឌ៤៤៖ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ស-២១ បានរើទៅអគ្គស្នងការនគរបាលជាតិតាមបណ្តោយផ្លូវ៥១ ផ្លូវប៉ាស្ទ័រជិតផ្សារធំថ្មី ។ យល់ព្រម ។

--៤៥៖ នៅក្នុងខែមករា ឆ្នាំ១៩៧៦ មន្ទីរ ស-២១ បានរើត្រឡប់ទៅទីតាំងចាស់វិញ ។ យល់ព្រម ។

កថាខណ្ឌ៤៦៖ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ តាមបញ្ជារបស់ ឌុច អ្នកទោសត្រូវបានប្តូរទៅវិទ្យា-ល័យពញាយ៉ាត ដែលមានទីតាំងនៅចម្លោះផ្លូវលេខ១១៣, ១៣១ ,៣២០ និង៣៥០ នៅត្រង់បរិវេណសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ មន្ទីរស-២១ បានស្ថិតនៅទីតាំងនេះរហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ យល់ព្រម ។

អគារកណ្តាល អាគារ “ង” សម្រាប់ទទួលកត់ឈ្មោះនិងថតរូបអ្នកទោស និងបន្ទប់មួយទៀតសម្រាប់គូរនិងឆ្លាក់រូបអ្នកដឹកនាំដែលបានធ្វើឲ្យរបបនេះរុងរឿង ។ យល់ព្រម ។

កថាខណ្ឌ៤៨៖ អគារបួនផ្សេងទៀត នៅស-២១ មានអាគារ “ក”, “ខ”, “គ” និង “ឃ" ប្រើសម្លាប់ឃុំឃាំង ។ យល់ព្រម ។

[១៤:២៧:៤៨]

កថាខណ្ឌ៤៨(ក) ៖ អគារ “ក”, “ខ”, “គ” និង“ឃ” សម្រាប់ដាក់អ្នកទោសទូទៅនៅបន្ទប់ឃុំឃាំងតូចៗដាច់ដោយឡែកធ្វើពីឈើ ឬឥដ្ឋនៅក្នុងបន្ទប់រួមគ្នា និងបន្ទប់ដាច់គ្នា ។ យល់ព្រម ។

កថាខណ្ឌ៤៨(ឃ)៖ អគារ “ក” និងផ្ទះមួយប្លុកនៅខាងត្បូងអតីតវិទ្យាល័យពញាយ៉ាត ជាគុកពិសេសសម្រាប់ដាក់អ្នកទោសសំខាន់ៗ ។ យល់ព្រម ។

កថាខណ្ឌ៤៩៖ អតីតវិទ្យាល័យពញាយ៉ាត និងគុកពិសេសជាកន្លែងយាមកាមតឹងតែងនិងសម្ងាត់បំផុតនៅស-២១ ។ អគារទាំងនោះហ៊ុមព័ទ្ធរបងនិងមានការពារទាំងខាងក្នុងនិងខាងក្រៅដោយអ្នកយាមដែលកាន់កាំភ្លើង ។ យល់ព្រម ។

កថាខណ្ឌ៥១៖ ពីដំបូងអ្នកទោសត្រូវបានសម្លាប់នៅក្នុងឬជុំវិញបរិវេណស-២១ ។ យល់ព្រម ។

[១៤:២៨:៤៨]

កថាខណ្ឌ៥២៖ ដោយមិនបានដឹងពីថ្ងៃខែច្បាស់លាស់នៅចម្លោះឆ្នាំ១៩៧៦ ឬក៏ពាក់កណ្តាលឆ្នាំ១៩៧៧ ម្យ៉ាងទៀតដើម្បីបញ្ចៀសជំងឺឆ្លង ឌុច បានជ្រើសរើសយកកន្លែងជើងឯកធ្វើជាកន្លែងសម្រាប់សម្លាប់អ្នកទោស ។ ជើងឯកស្ថិតប្រមាណ១៥គីឡូម៉ែត្រភាគនិរតីនៃក្រុងភ្នំពេញក្នុងខេត្តកណ្តាល ។ យល់ព្រម ។

កថាខណ្ឌ៥៣៖វាលពិឃាដជើងឯកមានផ្ទះឈើមួយខ្នងសម្រាប់ដាក់អ្នកទោសមុនពេលសម្លាប់និងរណ្តៅ ។ នៅមាត់រណ្តៅនោះជាកន្លែងសម្លាប់វាយសម្លាប់អ្នកទោសដើម្បីសម្លាប់មនុស្ស ។ យល់ព្រម ។

កថាខណ្ឌ៥៤៖ទោះបីជាជើងឯកបានក្លាយទៅជាកន្លែងសម្លាប់អ្នកទោសក៏ដោយ ក៏នៅមានអ្នកទោសខ្លះត្រូវបានសម្លាប់ និងកប់នៅក្នុងបរិវេណស-២១ និងក្បែរបរិវេណនោះ ។ យល់ព្រម ។

កថាខណ្ឌ៥៥៖ មន្ទីរ ស-២៤ ជាផ្នែកមួយនៃ ស-២១ ។ យល់ព្រម ។

កថាខណ្ឌ៥៦៖ ស-២៤ មានភារកិច្ចកែប្រែនិងកសាងយុទ្ធជន ព្រមទាំងធ្វើស្រែដើម្បីផ្គត់ផ្គង់ស-២១ និងសាខារបស់ខ្លួន ។ យល់ព្រម ។

កថាខណ្ឌ៤៨៖ តួនាទីចម្បងរបស់ ស-២១ គឺការអនុវត្តដកស្រង់មាគ៌ានយោបាយបក្សចំពោះខ្មាំង ។ ភ្ជាប់វិញ ដែលតាមរយៈមាគ៌ានេះ “អ្នកទោសត្រូវតែកម្ទេចចោលជាដាច់ខាត” ។ អង្គហេតុដូចតទៅនេះ គឺមិនមានការតវ៉ាទាក់ទងនឹងផ្នែកនេះ ខ្ញុំនិយាយអំពីការបង្កើតហើយនិងរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ ។

កថាខណ្ឌ៣៣៖ គឺថាជាការជម្លៀសដោយបង្ខំនូវប្រជាជនហើយនិងទៅកាន់មូលដ្ឋានខ្មែរក្រហមនៅជនបទ ។

កថាខណ្ឌ-- ការបង្កើតសហករណ៍ក្រោមការគ្រប់គ្រងរបស់-- គោលបំណងដើម្បីបង្កើនផលិតផល ហើយនៅពេលនោះប្រជាជនប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការដ៏លំបាកដើម្បីបង្កើនស្បៀងអាហារ ។

កថាខណ្ឌ១៨ មហាសន្និបាតក៏បានប្រកាស អំពីជំហររបស់ខ្លួនចំពោះមន្ត្រីថ្នាក់ទាបនៃរបបសាធារណរដ្ឋខ្មែរ ថាពួកគេនឹងត្រូវបាន--

*សូមអភ័យទោស ចំពោះតុលាការខ្ញុំបានអានផ្នែកមួយដែលបានខ្ញុំអានរួចហើយ ខ្ញុំសូមអភ័យទោសចំពោះការភ័ន្តច្រឡំ ។*

អង្គហេតុដូចខាងក្រោមនេះ មិនត្រូវបានតវ៉ា ។

និយាយពីការបង្កើត ស-២១ ។ កថាខណ្ឌ៤០៖ ឌុច គេខ្លាច ឌុច គ្រប់ៗគ្នានៅ ស-២១ ។

កថាខណ្ឌ៥០៖ អគារជាច្រើនក៏ជាផ្នែកនៃស-២១ ដែរ ។ តួយ៉ាងផ្ទះសម្រាប់សួរចម្លើយ កន្លែងប្រហារជីវិត រណ្ដៅសាកសពរួម រោងបាយ កន្លែងដាក់ឱសថ ផ្ទះបុគ្គលិក ការិយាល័យផ្សេងៗរបស់ឌុច និងផ្ទះសម្រាប់ទទួលអ្នកទោស ។ អគារទាំងអស់នោះ គឺស្ថិតនៅក្នុងៗបរិវេណទីមួយក៏ត្រូវបានការពារដោយអ្នកយាមនោះដែរ ។

៤៧៖ ស-២៤ស្ថិតនៅក្រៅក្រុងភ្នំពេញជិតជើងឯកក្នុងតំបន់វត្តក្ដុល ស្រុកដង្កោ ខេត្តកណ្ដាល ។ ទោះបីរចនាសម្ព័ន្ធនិងសកម្មភាពរបស់ស-២១ លាតសន្ធឹកពីគុកព្រៃស ដល់ភូមិចេកក៏ដោយ ក៏តំបន់មន្ទីរស-២១ ទាំងមូលទំនងក៏មានទំហំធំជាងនេះ ។

នេះជាអង្គហេតុដែលឯកភាព ឬក៏អង្គហេតុមិនបានៗតវ៉ា ។ ខ្ញុំសុំស្នើឱ្យមេធាវីការពារបញ្ជាក់ការយល់ព្រម ឬមិនព្រម ។

[១៤:៣៣:០៣]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ។ មេធាវីការពារសូមបញ្ជាក់ថា ខ្លួនឯកភាពទៅនឹងអង្គហេតុនូវកថាខណ្ឌទាំងឡាយដែលបានអានដោយសហព្រះរាជអាជ្ញា។ ប៉ុន្តែ ទាក់ទងទៅនឹងការបង្កើតនិងរចនាសម្ព័ន្ធ ស-២១ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ពេទីត សូមអញ្ជើញបន្ត ។

[១៤:៣៣:៣១]

**លោក រ៉ូប៊ឺត ពេទីត៖**

អរគុណលោកប្រធាន ។ ក្រោមចំណងជើងថា "ការអនុវត្តគោលនយោបាយកម្ទេចខ្មាំង" គឺអង្គហេតុដូចខាងក្រោមបានយល់ស្រប ។

កថាខណ្ឌ៥៨៖ តួនាទីចម្បងរបស់មន្ទីរស-២១ គឺពាក្យថា "កម្ទេច" ត្រូវបានប្រើនិងយល់ថា ជាទូទៅថាការសម្លាប់ ។ យល់ព្រម ។

ក្នុងការអនុវត្តជាក់ស្តែង គឺអនុគណៈកម្មាធិការនៃគណៈកម្មាធិការកណ្តាល ឬហៅថាគណៈកម្មាធិការអចិន្ត្រៃយ៍ជាអ្នកដើរតួនាទីជាអង្គភាពប្រកបដោយសិទ្ធិអំណាចធំបំផុតនិងខ្ពស់បំផុតរបស់រដ្ឋ។ យល់ព្រម ។

កថាខណ្ឌ៦៥៖ សេចក្តីសម្រេចមួយនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ បានតែងតាំង ប៉ុល ពត ជាមេបញ្ជាការជាន់ខ្ពស់កងទ័ព និង សុន សេន ជានាយសេធិការ និងខាងផ្នែកសន្តិសុខ ។ យល់ព្រម ។

[១៤:៣៤:២៨]

វាក្យខណ្ឌ៦៨៖ ឌុច មានទំនាក់ទំនងជាចម្បងជាមួយ សុន សេន និង នួន ជា ។ អ្នកទាំងពីធ្វើការក្នុងនាមគណៈកម្មាធិការអចិន្ត្រៃយ៍ ។ យល់ព្រម ។

កថាខណ្ឌ៧១៖ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៦ មន្ទីរស-២១ បានជាប់ពាក់ព័ន្ធជាសំខាន់ក្នុងការឃុំឃាំង ការកសាងខ្លួន ការធ្វើទារុណកម្មនិងការសម្លាប់ជនទាំងឡាយដែលមានជាប់ពាក់ព័ន្ធនឹងរបស់សាធារណរដ្ឋខ្មែរ ដែលបានដួលរលំ ។ យល់ស្រប ។

កថាខណ្ឌ៧២៖ មកទល់ត្រឹមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបញ្ចប់មួយផ្នែកធំជាមួយនឹងកម្មសិទ្ធិឯកជន ជាមួយមន្ត្រីរបបចាស់ ជាមួយសាសនា ជាមួយគ្រូបង្រៀន និងជាមួយអ្វីដែលពួកគេយល់ថាជាវណ្ណៈជិះជាន់ ។ យល់ស្រប ។

កថាខណ្ឌ៧៣៖ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាក់អំពីថ្នាក់ដែលមានអំណាចក្នុងការបញ្ជាឲ្យមានការសម្លាប់ ។ ហេតុដូច្នេះហើយ បានជាមានសមាជិកក្នុងជួរបដិវត្តន៍ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ កាន់តែច្រើនឡើងៗ ។ យល់ព្រម ។

កថាខណ្ឌ៧៤៖ ឯកសារមួយចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានលើក ឡើងពីបញ្ហាផ្សេងៗមួយចំនួនដែលក្នុងនោះមានសេចក្តីសម្រេចមួយសរសេរថា "

ឲ្យមានក្របខ័ណ្ឌ មួយក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង" និង "ដើម្បីពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង" "សិទ្ធិសម្រេចកម្ទេចខ្មាំងក្នុងជួរនិងក្រៅជួរ" បានប្រគល់ឲ្យជូនដូចខាងក្រោម៖

"បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច នៅជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច"។ យល់ព្រម ។

កថាខណ្ឌ៧៥៖ ឯកសារចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិមបានបញ្ជាក់ពីរបត់មួយ ពីព្រោះវាបញ្ជាក់ពីការចាប់ផ្តើមនៃការសម្រិតសម្រាំងផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ការពារមុនមន្ត្រីរាជការនៃរបបចាស់ត្រូវបានកម្ទេចចោល ប៉ុន្តែ នាពេលក្រោយមកការសម្លាប់បានធ្វើឡើងនៅក្នុងជួរបក្សនិងកងទ័ព ។ យល់ព្រម ។

[១៤:៣៧:០៩]

កថាខណ្ឌ៧៧៖ ក្នុងតួនាទីរបស់ ឌុច ជាប្រធានមន្ទីរ ស-២១ គឺផ្តោតសំខាន់លើការកម្ទេច អ្នកដែលគេសន្មតថា ជាជនក្បត់ក្នុងជួរបដិវត្តន៍ ។ យល់ព្រម ។

កថាខណ្ឌ៧៨៖ ពីដំបូង ស-២១ មានសមត្ថកិច្ចត្រឹមតែចំពោះអ្នកទោសដែលសំខាន់ និងអ្នកទោសដែលរស់នៅភ្នំពេញ និងសមាជិកនៃគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ ។ ដូច្នេះ ពីដំបូង យុវជនថ្នាក់ទាបមិនត្រូវបាន បញ្ជូនមក ស-២១ នោះទេ លើកលែងតែនៅពេលណាដែលពួកគេត្រូវបានចាប់ខ្លួននៅភ្នំពេញតែប៉ុណ្ណោះ ។ ជាទូទៅខ្មាំងដែលមានឋានៈខ្ពស់ សមាជិកជាន់ខ្ពស់របស់បក្សរបស់រដ្ឋ របស់កងទ័ព ឬរបស់សន្តិបាលដែលត្រូវបានអ្នកទោសឆ្លើយដាក់តាមរយៈចម្លើយសារភាពត្រូវបានបញ្ជូនមកមន្ទីរស-២១ ។ យល់ព្រម ។

កថាខណ្ឌ៧៩៖ នៅពេលដែលថ្នាក់ដឹកនាំណាម្នាក់ត្រូវបានចាប់ខ្លួន សមាជិក ឬក៏អ្នកនៅក្រោមបង្គាប់ត្រូវបាន ចាប់ខ្លួនមកមន្ទីរស-២១ ។ យល់ព្រម ។

កថាខណ្ឌ៨០៖ គោលនយោបាយកម្ទេចខ្មាំងនោះ គឺកម្ទេចទាំងក្រុមគ្រួសារ រួមទាំងកូនៗរបស់ពួកគេផងដែរ ។ យល់ព្រម ។

កថាខណ្ឌ៨២៖ គិតមកដល់ត្រឹមខែមករា ឆ្នាំ១៩៧៩ មន្ទីរស-២១ មានអ្នកទោសមកពីស្ទើរតែគ្រប់ភូមិភាគ ក្រសួង និងអង្គភាពយោធាទូទាំងប្រទេស ។ យល់ព្រម ។

កថាខណ្ឌ៨៣៖ តួនាទីមន្ទីរស-២១ បានឈានដល់ការកម្ទេចអ្នកដែលស្ថិតនៅក្នុងជួរបដិវត្តន៍

ទាំងឡាយណាដែលទទួលរងនូវការចោទប្រកាន់ថា ទទួលឥទ្ធិពល ឬស្ថិតនៅក្រោមការបញ្ជារបស់វៀតណាម ព្រោះតែកន្លងមក ឬក្នុងពេលដំណាលគ្នាពួកគេធ្លាប់មានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តវៀតណាម ។ យល់ព្រម ។

[១៤:៣៩:១៧]

កថាខណ្ឌ៨៤៖ ក្នុងខណៈពេលដែលជម្លោះប្រដាប់អាវុធជាមួយវៀតណាមមានភាពកាន់តែតានតឹងឡើង ការចាប់ខ្លួន និងការបញ្ជូនខ្លួនពលរដ្ឋស៊ីវិល និងកងទ័ពវៀតណាមមួយចំនួននៅមន្ទីរស-២១ ក៏បានកើនឡើងខ្លាំងដែរ ។ យល់ព្រម ។

អង្គហេតុដូចខាងក្រោមនៅក្នុងចំណងជើង"គោលនយោបាយកម្ទេចខ្មាំងមិនត្រូវបានជំទាស់" ។

កថាខណ្ឌ៦២៖ បក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យជាចម្បងតាមរយៈអង្គការរដ្ឋកម្ពុជាប្រជាធិបតេយ្យ អង្គការរដ្ឋបាលរបស់បក្ស និងកងទ័ពបដិវត្តន៍កម្ពុជា ។

កថាខណ្ឌ៦៣៖ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ និងលក្ខន្តិកៈបក្សបានផ្តល់អំណាចយ៉ាងធំទៅឲ្យគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដោយរួមមានលទ្ធភាពក្នុងការកំណត់គោលនយោបាយបក្ស និងអំណាចបញ្ជាទៅថ្នាក់ភូមិភាគ និងតំបន់ ។

កថាខណ្ឌ៧០៖ ទោះបីគោលនយោបាយកម្ទេចខ្មាំង ទំនងជាត្រូវបានអនុវត្តនៅពេលមុន និងក្នុងអំឡុងពេលនៃយុត្តាធិការអ.វ.ត.ក ក៏ដោយ និងនិយមន័យនៃអ្នកដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាខ្មាំងនោះ មានការប្រែប្រួល និងពង្រីកទៅតាមការអនុវត្តនៃស្ថានភាពក្នុងស្រុក និងជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និងវៀតណាម ។

អង្គហេតុដែលបានលើកឡើងខាងលើ គឺជាអង្គហេតុដែលបានយល់ព្រម និងមិនបានជំទាស់ ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យមេធាវីការពារក្តីធ្វើការបញ្ជាក់ទៅលើអង្គហេតុទាំងអស់នោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវី ។

**លោក ហ្វ្រង់ ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ មេធាវីការពារក្តីបញ្ជាក់អំពីការយល់ព្រម និងការមិនជំទាស់ទាក់ទងទៅនឹងកថាខណ្ឌទាំងឡាយដែលបានអានដោយខាងសហព្រះរាជអាជ្ញា ។

[១៤:៤១:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញា អញ្ជើញអានបន្តទៀត ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន។ ក្រោមចំណងជើងការផ្សព្វផ្សាយមាគ៌ានយោបាយបក្សនៅមន្ទីរស-២១ អង្គហេតុដូចខាងក្រោមបានយល់ស្រប ។

កថាខណ្ឌ៨៥(ក)៖ ឌុច ព្រមទាំងកម្មាភិបាលនៅមន្ទីរ ស-២១ បានចូលរួមវគ្គអប់រំនយោបាយអំពីគោលនយោបាយទូទៅ និងរៀបចំផែនការបង្កបង្កើនផលដែលត្រូវបានរៀបចំឡើងដោយសេនាធិការរបស់មជ្ឈិម ។ យល់ព្រម ។

កថាខណ្ឌ៨៥(ខ)៖ ឌុច និងពួកកម្មាភិបាលដទៃទៀតធ្លាប់បានចូលរួមវគ្គរៀនសូត្រដែលបានរៀបចំឡើងដោយ សុន សេន ដើម្បីពិភាក្សាអំពីភាពចាំបាច់ក្នុងការបោសសម្អាត និងកម្ទេចខ្មាំងដែរ ។ យល់ព្រម ។

កថាខណ្ឌ៨៥(គ)៖ គោលនយោបាយក្នុងការសម្លាប់អ្នកទោសក្រៅច្បាប់ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅមន្ទីរស-២១ ក្នុងឱកាសនៃកិច្ចប្រជុំអង្គប្រចាំឆ្នាំ និងក្នុងឱកាសកិច្ចប្រជុំតូចៗផ្សេងៗទៀតដែលរៀបចំឡើងដោយអនុអង្គភាពនានា ។

កថាខណ្ឌ៨៧៖ ឌុច និងសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬសមាជិករបស់សហព័ន្ធយុវជនកុម្មុយនីស្តដែលធ្វើការនៅមន្ទីរស-២១ បានដឹងអំពីតួនាទីរបស់ការិយាល័យរបស់ពួកគេក្នុងការអនុវត្តគោលនយោបាយ ទាំងនេះតាមរយៈទស្សនាវដ្ដីពីររបស់បក្ស គឺទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ ។ យល់ព្រម ។

កថាខណ្ឌ៨៨៖ ការចោទប្រកាន់ពីបទក្បត់ជាតិ ដែលអ្នកទោសសារភាពក្រោមការបង្ខិតបង្ខំត្រូវបានលាតត្រដាងនៅក្នុងការបោះពុម្ពផ្សាយ-- ទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ និងនៅក្នុងលក្ខណៈសម្រាប់និយាយដៀមដាមសម្រាប់ឃោសនាផ្លូវការដទៃទៀតរបស់កម្ពុជាប្រជាធិបតេយ្យ។ យល់ព្រម។

[១៤:៤៣:១៣]

កថាខណ្ឌ៨៩៖ ឈ្មោះមនុស្សក្បត់ជាតិដែលគេបានចោទប្រកាន់ថា មានជាអាទិ៍ ចាន់ ចក្រី , ម៉ែន សាន ហៅ យ៉ា, សួស នៅ ហៅ ឈូក និង កុយ ធួន ដែលត្រូវបានលើកឡើងនិយាយជាច្រើនលើកជាច្រើនសា ។ យល់ព្រម ។

កថាខណ្ឌ៩០៖ ដើម្បីការពារសកម្មភាពរបស់របបនេះក្នុងអំឡុងពេលនៃការប្រជុំដែលរៀបចំឡើងនៅក្រោមន្ទីរ ស-២១ ចម្លើយសារភាពខ្មែរអាត់សំឡេង ឬជាអត្ថបទលាយលក្ខណ៍អក្សរទាំងនោះត្រូវបានគេចាក់ តាមម៉ាញ៉េ ឬអានឲ្យអ្នកចូលរួមប្រជុំស្តាប់ ។ យល់ព្រម ។

កថាខណ្ឌ៩១៖ ឌុច ចាប់តាំងពីបានធ្វើជាប្រធានមន្ទីរស-២១ មករាល់សេចក្តីណែនាំនានាដែលធ្វើឡើងចំពោះមន្ទីរស-២១ ឬចេញមកពីមន្ទីរស-២១ ហើយទាក់ទងទៅនឹងការងារសន្តិសុខត្រូវបានឆ្លងកាត់គាត់សិន ទាំងអស់នេះគឺជាអង្គហេតុដែលបានយល់ព្រម ។

ដូច្នេះ ខ្ញុំស្នើសុំឲ្យខាងមេធាវីការពារក្តី ធ្វើការបញ្ជាក់ទៅលើអង្គហេតុដែលយល់ព្រមទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ ស្វ័ររូ៖**

អរគុណលោកប្រធាន ។ មេធាវីការពារក្តីសុំធ្វើការបញ្ជាក់អំពីការព្រមព្រៀងទៅលើអង្គហេតុទាំងអស់នេះ ។ ប៉ុន្តែ ចំណុចបំភ្លឺមួយនៅក្នុងវាក្យខណ្ឌ៨៥(គ) ឯកសារដំបូងដែលយើងទទួលបាន គឺវាខុសគ្នា បន្តិចនឹងអ្វីដែលលោកបានលើកឡើង ហើយខ្ញុំគិតថាវាអត់អ្វីដែលវាលំបាកនឹងខុសគ្នាខ្លាំងទេ ។ ហើយឯកសារដំបូងយើងបានយល់ស្របគ្នាទៅលើអង្គហេតុនេះ ទាក់ទងទៅនឹងគោលនយោបាយក្នុងការសម្លាប់អ្នកទោសខាងក្រៅ ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅមន្ទីរស-២១ ដោយបានលើកឡើងថាគោលនយោបាយក្នុងការសម្លាប់អ្នកទោសក្រៅច្បាប់ គឺអនុវត្តឡើងដោយ ឌុច ហើយចំពោះបញ្ហាផ្សេងៗនោះ គឺយើងយល់ព្រមហើយ ប៉ុន្តែវាមានលក្ខណៈខុសបន្តិច ។ ដូច្នេះ ខ្ញុំសូមបំភ្លឺទៅលើចំណុចហ្នឹងបន្តិច ។

[១៤:៤៦:៤៧]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ យើងឯកភាពទៅតាមអ្វីដែលបានអានដោយលោកសហព្រះរាជអាជ្ញានៅត្រង់ចំណុច ៨៥(ក) ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា សូមអានបន្តទៀត ។

**លោក រ៉ូបឺត ពើទីត៖**

ខ្ញុំមានឯកសារដូចគ្នាទាំងអស់ ដែលដូចនឹងឯកសារខ្ញុំផ្ញើជូនទៅខាងមេធាវីការពារក្តី ។ ដូច្នេះ ហើយ គឺអ្វីដែលខ្ញុំអាន គឺដូចនឹងឯកសារនោះទាំងអស់ ប្រហែលជាការបកប្រែខុសបន្តិចបន្តួច ឬយ៉ាង ម៉េច ខ្ញុំអត់ដឹងទេ អត់ដឹងទៅលើបញ្ហាហ្នឹង ។ អង្គហេតុទាំងអស់នេះ ទាក់ទងទៅនឹងចំណងជើងការ ប្រើប្រាស់ចម្លើយសារភាពដែលទទួលបាននៅមន្ទីរស-២១ ។ បានយល់ព្រម ។

កថាខណ្ឌ៩៣៖ មន្ទីរស-២១ មិនមានតួនាទីក្នុងការកំណត់ថាតើអ្នកទោសពិតជាជនក្បត់មែន ឬមិនមែននោះទេ ព្រោះការចាប់ខ្លួននឹងបញ្ជូនមកកាន់មន្ទីរស-២១ គឺមានន័យថា គ្រប់គ្រាន់ថាពួកគេ មានពិរុទ្ធភាពរួចទៅហើយ ។ យល់ព្រម ។

កថាខណ្ឌ៩៤៖ បន្ថែមទៅលើការសម្លាប់អ្នកទោសដែលត្រូវបានចោទជាមុនថា ជាជនក្បត់ ។ មន្ទីរស-២១ មានតួនាទីយ៉ាងសំខាន់ក្នុងការយកចម្លើយសារភាពពីអ្នកទោសដើម្បីរែកមុខបណ្តាញក្បត់ ផ្សេងទៀត ។ យល់ព្រម ។

កថាខណ្ឌ៩៥៖ ចម្លើយសារភាពមន្ទីរ ស-២១ ភាគច្រើនមានទម្រង់ជាប្រវត្តិនយោបាយដែល សរសេរដោយអ្នកទោសខ្លួនឯង ដោយទទួលរងនូវការបង្ខិតបង្ខំ ចម្លើយសារភាពនេះក្លាយទៅជាការ បរិហារអំពីខ្លួនឯង និងការចោទប្រកាន់ដទៃទៀត អ្នកដទៃថាក្បត់ ព្រោះបានបម្រើឲ្យចារកម្មបរទេស ដែលជាសត្រូវរបស់បដិវត្តន៍កម្ពុជា ដូចជាពួក *ស៊ី.អាយ.អេ* (C.I.A), *កា.ហ្សេ.បេ* (K.G.B) និងភ្នាក់ងារបក្សកុម្មុយនីស្តវៀតណាម ។ យល់ព្រម ។

កថាខណ្ឌ៩៦៖ ចម្លើយសារភាពមន្ទីរស-២១ មួយចំនួន មានត្រឹមតែធ្វើការពិពណ៌នាលម្អិតអំពី សកម្មភាពក្បត់ការដែលបានចោទប្រកាន់ប៉ុណ្ណោះទេ ថែមទាំងបរិយាយយ៉ាងលម្អិតអំពីរចនាសម្ព័ន្ធ និង ប្រតិបត្តិការរបស់អង្គការបក្សគ្រប់ជាន់ថ្នាក់ និងគ្រប់អង្គភាពរដ្ឋបាលទាំងអស់ ។ យល់ព្រម ។

[១៤:៤៩:០២]

កថាខណ្ឌ៩៧៖ ប្រតិបត្តិការរបស់មន្ទីរស-២១គឺ"វាវិសមត្ថភាពជាមួយនឹងអាទិភាពនៃតុលាការ ហ្នឹង ការធានាផ្នែកនីតិវិធី" ។ យល់ព្រម ។

កថាខណ្ឌ៩៨(ក)៖ ដោយមិនខ្វល់ខ្វាយថាតើចម្លើយសារភាពពិត ឬមិនពិតយ៉ាងណានោះទេ គេនៅតែប្រើចម្លើយសារភាពទាំងអស់នោះជាលេស ក្នុងការសម្លាប់ ក្នុងការសម្រេចចាប់ខ្លួនអ្នកទាំង ឡាយណាដែលបានត្រូវបរិហារថា ជាភ្នាក់ងាររបស់ខ្មាំង ហើយជាញឹកញាប់នាំឲ្យមានការចាប់ខ្លួនជា

ច្រើនដែលបានភ្ជាប់ថា ជាជនក្បត់ ។ យល់ព្រម ។

កថាខណ្ឌ៩៨(ខ)៖ ជាទូទៅកាលដែលឈ្មោះរបស់មនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពមួយដង មិនមែនជាការគ្រប់គ្រាន់ដើម្បីឲ្យមានការចាប់ខ្លួននោះទេ ត្រូវតែច្រើនដង ។ យល់ព្រម ។

កថាខណ្ឌ១០០៖ ឌុច បានអានវិភាគធ្វើចំណារ និងសង្ខេបយ៉ាងល្អិតល្អន់លើចម្លើយសារភាពភាគច្រើនដើម្បីសម្រាប់ថ្នាក់លើរបស់ខ្លួន ។ យល់ព្រម ។ ទាំងអស់នេះ គឺជាអង្គហេតុដែលបានយល់ព្រមក្រោមចំណងជើងថា "ការប្រើប្រាស់ចម្លើយសារភាពដែលទទួលបាននៅមន្ទីរស-២១" ខ្ញុំសូមឲ្យមេធាវីការពារក្តី ធ្វើការបញ្ជាក់ទៅលើអង្គហេតុទាំងអស់នេះ ។

[១៤:៥០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោក រូ បានលើកឡើង ។ មេធាវីការពារក្តីបញ្ជាក់ថា យើងខ្ញុំយល់ស្របទៅនឹងកថាខណ្ឌដែលបានអានដោយសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញា អញ្ជើញអានបន្តទៀត បាទ ។

**លោក រ៉ូប៊ឺត ពើទីត៖**

សូមអរគុណ លោកប្រធាន ។ និយាយអំពីសមាសភាពរបស់ប្រជាជនដែលឃុំឃាំង ។ កថាខណ្ឌ១០៣ អ្នកទោសមន្ទីរស-២១ ភាគច្រើនជាជនជាតិខ្មែរ ។ យល់ព្រម ។

កថាខណ្ឌ១០៤(ង)៖ សាច់ញាតិរបស់កម្មាភិបាលក៏ត្រូវបានចាប់ខ្លួននិងឃុំឃាំងនៅមន្ទីរស-២១ផងដែរ ។ យល់ព្រម ។

កថាខណ្ឌ១០៤(ឆ)៖ បុគ្គលិកស-២១ ក៏ត្រូវបានចាប់ខ្លួនមកកាន់ទួលស្លែងដែរ ។ យល់ព្រម។

១០៥៖ អតីតទាហាននិងមន្ត្រីរដ្ឋការនៅរបបសាធារណរដ្ឋខ្មែរត្រូវបានគេឃុំខ្លួនជាអ្នកទោសនៅមន្ទីរស-២១ ។ យល់ព្រម ។ ជនជាតិភាគតិចកម្ពុជាមួយចំនួន រួមមានចាមក៏បានចាប់ឃុំជាប់ឃុំនៅ

មន្ទីរ ស-២១ ដែរ ។ យល់ព្រម ។

កថាខណ្ឌ១០៨៖ ចំនួនជនបរទេសដែលជាប់ឃុំឃាំងច្រើនជាងគេ គឺជនជាតិវៀតណាមដែលរួមមានជនស៊ីវិលនិងកងទ័ពវៀតណាមរាប់រយនាក់ ។ ឯកភាព ។ យល់ព្រម ។

[១៤:៥១:៥៨]

កថាខណ្ឌ១០៩៖ អ្នកទោសនៅស-២៤ (ព្រៃស) រួមទាំងបុរសស្ត្រីនិងកុមារ ។ យល់ព្រម ។ អ្នកទាំងអស់នោះត្រូវចាត់ទុកជាជនសង្ស័យនិងទីពីរអ្នកក្រោមបង្គាប់កម្មាភិបាល ដែលត្រូវបានចាប់ខ្លួន ។ មន្ទីរស-២៤ ក៏ទទួលផងដែរ នូវយុទ្ធជនមកពីបណ្តាអង្គភាពនានា បុគ្គលិកមកបណ្តាក្រសួងផ្សេងៗ សមាជិកក្រុមគ្រួសាររបស់គេនៅភ្នំពេញ ។

កថាខណ្ឌ១១០៖ នៅពេលណាមួយក៏ដោយ ក៏មានមនុស្សពីរ ឬបីរយនាក់ធ្វើការនៅស-២៤ ។ យល់ព្រម ។ អង្គហេតុដូចតទៅ និយាយពីសមាសភាពនៃជនជាប់ឃុំដែលមិនមានតវ៉ា ។

១០៤(ក)៖ អ្នកទោស៥០០០នាក់ មកពីស្ថាប័ននិងក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ ។ ចំណុច “ខ” ៖ ៤៥០០នាក់ មកពីអង្គភាពកងទ័ពកម្ពុជាប្រជាធិបតេយ្យ ។ “គ”៖ អ្នកទោសទាំងនេះចេញមកពីគ្រប់មន្ទីរនិងអង្គភាពទាំងអស់នៅក្នុងប្រទេសនិងចេញមកពីភូមិភាគ ដែលមានស្រាប់ទាំងអស់រួមទាំងតំបន់ស្វយ័ត ។

កថាខណ្ឌ១០៤(ឆ)៖ អតីតបុគ្គលិកស-២១ ប្រហែលក៏បានក្លាយខ្លួនជាអ្នកទោសនៅទួលស្លែងផងដែរ ។ ជនបរទេសមួយចំនួនក៏ត្រូវបានឃុំឃាំងនៅស-២១ ផងដែរ ដូចជាជនជាតិវៀតណាម ថៃ ឡាវ ឥណ្ឌា និង “ពួកបស្ចិមប្រទេស” ។

កថាខណ្ឌ១០៨(ក)៖ យ៉ាងហោចណាស់ជនជាតិវៀតណាម៤០០នាក់ ដែលក្នុងនោះមាន១៥០នាក់ ត្រូវបានគេចុះក្នុងកំណត់ហេតុថាជាឈ្លើយសឹក ហើយយ៉ាងហោចណាស់១០០នាក់ផ្សេងទៀតជាជនស៊ីវិល ។

កថាខណ្ឌ១០៨(ខ)៖ ការចាប់ខ្លួនដែលមានកត់ត្រាទុកក្នុងកំណត់ហេតុជាលើកដំបូងនៅស-២១ ជាជនជាតិវៀតណាម គឺធ្វើឡើងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។

ចំនួនអ្នកទោសវៀតណាមនៅស-២១ បានកើនឡើង នៅពេលដែលជម្លោះជាមួយវៀតណាមកាន់តែកើនឡើង ។ នេះជាអង្គហេតុដែលមានការយល់ និងមិនតវ៉ាទាក់ទងទៅនឹងសមាសភាពនៃអ្នកដែលជាប់ឃុំឃាំងនៅស-២១ ។

[១៤:៥៤:៣៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

គ្រាន់តែបញ្ជាក់ការ-- សុំឲ្យបំភ្លឺ ដើម្បីឲ្យអស់លោកអ្នកដែលមិនបានពិនិត្យឃើញឯកសារនោះ ខ្ញុំយោងទៅកថាខណ្ឌ១០៤ គប្បីអានថាទាំងមូល ។ ផ្នែកដំបូងនេះ គឺថាជាផ្នែកក្រុមភាគច្រើន ខ្ញុំយោងទៅអ្នកឃុំខ្លួនស-២១ នោះគឺថាមានកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ហើយយើងមានចំណុច "ង", "ក", "ខ", "គ" ហើយមិនតវ៉ាទេ ។

ហើយយើងបានបន្ថែម-- គឺមានច្រើនជាង៥០០០នាក់នៃជនមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរនោះ ។ នៅក្នុងស-២១ ដូច្នេះយើងមានអ្នកទោសមកពីមន្ទីរទាំងឡាយហើយនិងអង្គភាពស្វយ័តនៅក្នុងប្រទេសដែរ ។ ដូច្នេះខ្ញុំចង់សូមបំភ្លឺអ្វីដែលយើងឯកភាព ហើយអ្វីដែលយើងមិនតវ៉ានោះ ។ ហើយខ្ញុំឯកភាពជាមួយនឹងអ្វី ដែលលោកព្រះរាជអាជ្ញាបានអានមកត្រឹមនេះ ។

[១៤:៥៦:១៣]

**លោក រ៉ូប៊ឺត ពើទីត៖**

នៅក្នុងកថាខណ្ឌ-- វគ្គដែលនិយាយអំពីការចាប់ខ្លួននិងការបញ្ជូនទៅស-២១ អង្គហេតុដូចខាងក្រោមនោះ ត្រូវបានឯកភាព ។

កថាខណ្ឌ១១១៖ ចំពោះការចាប់ខ្លួនសមាជិកគណៈកម្មាធិការមជ្ឈិមសេចក្តីសម្រេចត្រូវធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស ។ យល់ព្រម ។

កថាខណ្ឌ១១២៖ ចំពោះអ្នកដទៃទៀត ឌុច បាននិយាយថា គឺ នួន ជា ជាអ្នកថ្នាក់លើរបស់គាត់ កោះហៅប្រធានអង្គភាពពាក់ព័ន្ធមកពិភាក្សាដើម្បីសម្រេចរួម ។ យល់ព្រម ។

កថាខណ្ឌ១១៣៖ ចំពោះមនុស្សដែលមកពីតំបន់ដទៃទៀត ដែលត្រូវបញ្ជូនមកស-២១ ការសម្រេចចាប់ខ្លួនតែងតែធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ដោយធ្វើការទាក់ទងជាមួយភូមិភាគតំបន់ ឬស្រុកនានាពាក់ព័ន្ធ ដើម្បីដកជនដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ។ យល់ព្រម ។

កថាខណ្ឌ១១៥(ក)៖ នៅក្នុងឱកាសទាំងនេះ ឌុច ជាអ្នកផ្តល់នូវបញ្ជីឈ្មោះមនុស្សទាំងឡាយដែលត្រូវចាប់ខ្លួន ដែលមានបញ្ជាក់ពីទីកន្លែង ដែលត្រូវចាប់ខ្លួននិងចំនួនកងកម្លាំងដែលចាំបាច់សម្រាប់

ប្រតិបត្តិការចាប់ខ្លួន និងបញ្ជូនទៅស-២១ ។ យល់ព្រម ។

កថាខណ្ឌ១១៧៖ ឌុច ត្រូវបានគេប្រាប់ឲ្យដឹងពីការមកដល់ (សូមអត់ទោស) ខ្ញុំចាប់ផ្តើមឡើងវិញ ។ យល់ព្រម ។

កថាខណ្ឌ១១៧៖ ឌុច ត្រូវបានគេប្រាប់ឲ្យដឹងពីមកដល់ ឈ្លើយសឹករបស់វៀតណាមតាមរយៈការទទួលបញ្ជីពីឈ្មោះ នួន ជា ឬមិត្ត លីន ដែលជាក្រោមបង្គាប់របស់ខ្លួន នួន ជា និងជាអតីតកងការពាររបស់ ប៉ុល ពត ។ យល់ព្រម ។ ទាក់ទងអំពីការចាប់ខ្លួននិងការបញ្ជូនទៅស-២១ គឺអង្គហេតុដូចក្រោមនេះមិនត្រូវបានតវ៉ា ។

កថាខណ្ឌ១១៦៖ ឈ្លើយសឹកវៀតណាមត្រូវបានគេចាប់ខ្លួនភាគច្រើននៅក្នុងតំបន់ ដែលមានជម្លោះ ដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយវៀតណាម ឬដែលនៅជិតនោះ ។ ហើយបានដឹកជញ្ជូនមកកាន់ ស-២១ ដោយអង្គភាពដែលជាអ្នកចាប់ខ្លួនពួកគេនោះ ។ មិនតវ៉ា ។

នេះជាអង្គហេតុដែលនិយាយអំពីការចាប់ខ្លួននិងការបញ្ជូនទៅស-២១ ដែលត្រូវបានយល់ព្រម និងមិនជំទាស់ ហើយសូមការបញ្ជាក់ពីមេធាវីការពារ ។

[១៥:៥៨:៥៨]

**លោក ហ្រ្វង់ស្វ័រ រូ៖**

មេធាវីការពារសូមបញ្ជាក់ថា ជនជាប់ចោទបានពិនិត្យមើលទាក់ទងទៅនឹងកថាខណ្ឌដែលបានលើកឡើង ដោយព្រះរាជអាជ្ញានោះគឺបានឯកភាព ។

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអរគុណលោកប្រធាន ។ ចំណុចមួយទៀត ក៏តួនាទីរបស់ ឌុច ក្នុងការចាប់ខ្លួនអង្គហេតុដូចខាងក្រោមនេះ ក៏ត្រូវបានយល់ព្រម១២០ ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ឌុច បានចូលរួមកិច្ចប្រជុំជាមួយកងពលធំ២៩០ និង ១៧០ ដែលគោលបំណងនៃការប្រជុំនោះ គឺដើម្បីរៀបចំគំរោងចាប់ខ្លួនមនុស្ស ។ សុន សេន និង សៀត ឆែ ហៅ ទុំ, ហៅបង៨១ ក៏មានវត្តមាននៅក្នុងកិច្ចប្រជុំនោះដែរ ។ ការប្រជុំនេះត្រូវបានរៀបចំឡើង ដោយសារថាចំនួននៃការចាប់ខ្លួននៅក្នុងអង្គភាពតែមួយមានលក្ខណៈជាពិសេស ។

១២២៖ ការសម្រេចពីខ្លួនចាប់ខ្លួនត្រូវបានរក្សាជាការសម្ងាត់ ដើម្បីធានាមិនឲ្យមានការក្រោកឈរប្រឆាំង ។ ជាពិសេសនៅពេលដែលការចាប់ខ្លួនមនុស្សជាច្រើន ត្រូវធ្វើក្នុងកន្លែងតែមួយ ។ ឧបាយ

កលត្រូវបានគេប្រើប្រាស់ផងដែរ ដើម្បីរក្សាកុំឲ្យមានការដឹងខ្លួនជាមុន ។ ក្នុងករណីទាក់ទងទៅនឹងការចាប់ខ្លួនមនុស្សចំនួន ។ ដូច្នេះ ឌុច បានប្រគល់តួនាទីទៅឲ្យ ហោក (H) ជាអ្នកពិភាក្សាជាមួយអ្នកទទួលខុសត្រូវរបស់អង្គភាពនោះដើម្បីឲ្យមានភាពស្ងប់ស្ងាត់ ដើម្បីរក្សាការសម្រួលដល់ការចាប់ខ្លួន ។

១២៣៖ សេចក្តីសម្រេចឲ្យមានការចាប់ខ្លួនគឺផ្អែកទៅលើចម្លើយសារភាព ស-២១ ដែលឆ្លើយដាក់ថាជាជនក្បត់ ។

១២៧៖ ឌុច ក៏មានវត្តមាននៅកន្លែងចាប់ខ្លួនយូរៗម្តងដែរ ។ ឧទាហរណ៍៖ កុយ ធួន ត្រូវបានគេចាប់ខ្លួននៅផ្ទះរបស់ ឌុច ។

ទាំងអស់នេះ គឺជាកថាខណ្ឌ ក្រោយចំណងជើងថា "ឌុចហើយនិងការចាប់ខ្លួន" ហើយសូមឲ្យមេធាវីសម្តែងការបញ្ជាក់និងការយល់ព្រម ឬមិនយល់ព្រម ។

[១៥:០១:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

យើងសូមបញ្ជាក់ថា លោកចៅក្រមពីការឯកភាពរបស់យើងដែលទាក់ទងទៅជនជាប់ចោទដែលថា កថាខណ្ឌដែលបានអានដោយសហព្រះរាជអាជ្ញានោះ គឺជនជាប់ចោទបានឯកភាព ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា អញ្ជើញអានបន្តទៀត ។

**លោក រ៉ូប៊ឺត ពើទីត៖**

សូមអរគុណប្រធាន ត្រង់ចំណងជើងថា "ការចាប់ខ្លួនបុគ្គលិកស-២១" អង្គហេតុដូចខាងក្រោមត្រូវបានយល់ព្រម ។

កថាខណ្ឌ១២៩៖ បុគ្គលិកស-២១ ក៏ត្រូវបានចាប់ខ្លួនផងដែរ ហើយក៏ត្រូវបានបញ្ជូនទៅស-២៤ ហើយត្រឡប់មកវិញ ។ ឌុច គឺជាបុគ្គលតែម្នាក់ដែលអាចធ្វើការរាយការណ៍ទៅថ្នាក់លើ ហើយនិងសម្រេចធ្វើការចាប់ខ្លួនដែលបញ្ជូនមកវិញដោយរយៈលោក ហោក (H) ។ ទាំងអស់នេះជាអង្គហេតុដែលបានឯកភាពដែលបានទាក់ទងទៅនឹង-- សុំឲ្យមេធាវីខាងការពារដើម្បីបញ្ជាក់ការយល់ព្រម ឬមិនយល់ព្រម ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងបញ្ជាក់ការឯកភាពពីការឯកភាពរបស់ជនជាប់ចោទ ទាក់ទងទៅនឹងការចាប់ខ្លួនបុគ្គលិករបស់ស-២១ ។

**ប្រធានអង្គជំនុំ៖**

សូមលោក-- សហព្រះរាជអាជ្ញា អញ្ជើញបន្តទៀត បាទ ។

[១៥:០២:៥២]

**លោក រ៉ូប៊ឺត ពេទីត៖**

ក្រោយចំណងជើងថា "ស្ថានភាពនៃការឃុំខ្លួននៅទួលស្លែង" អង្គហេតុដូចខាងក្រោមត្រូវបានយល់ព្រម ។

កថាខណ្ឌ១៣៨៖ អ្នកទោសបានចូលមកស-២១ ស្ទើរតែរៀងរាល់ថ្ងៃ ។ យល់ព្រម ។

កថាខណ្ឌ១៤០៖ អ្នកទោសទាំងនោះត្រូវបានចុះឈ្មោះក្នុងបញ្ជី ហើយបញ្ជីនោះត្រូវបានរៀបចំឡើងដោយកម្មាភិបាល ស-២១ ឈ្មោះ X ។

កថាខណ្ឌ១៤១៖ អ្នកទោសត្រូវបានតម្រូវឲ្យប្រាប់ពីប្រវត្តិរូប និងបន្ទាប់មកគេសង្ខេបចម្លើយទាំងនោះ ។ យល់ព្រម ។

កថាខណ្ឌ១៤២៖ អ្នកទោសមកដល់ថ្មីត្រូវបានគេថតរូប ដោយជាទូទៅមានពាក់លេខ និងពេលខ្លះមានឈ្មោះនិងកាលបរិច្ឆេទនៃការចាប់ខ្លួន ។ រូបថតទាំងនេះត្រូវបានថតតាមការណែនាំរបស់ សុនសេន ដើម្បីជាជំនួយក្នុងការចាប់ខ្លួនម្តងទៀត កាលណាមានអ្នកណាម្នាក់រួចគេចខ្លួន ។ យល់ព្រម ។

១៤៣៖អ្នកទោសទាំងនោះមិនត្រូវបានគេប្រាប់ពីមូលហេតុនៃការចាប់ខ្លួននិងការឃុំខ្លួនឡើយ ។ ។ យល់ព្រម ។

កថាខណ្ឌ១៤៤៖ អ្នកទោសនៅស-២១ត្រូវគេបង្ខាំងស្ទើរតែ២៤ម៉ោងក្នុងមួយថ្ងៃ ។ យល់ព្រម។

កថាខណ្ឌ១៤៥៖ មន្ទីរឃុំខ្លួនស-២១ មានទាំងបន្ទប់ឃុំខ្លួនតូចៗដាច់ដោយឡែក និងបន្ទប់ធំឃុំរួម ។ នៅក្នុងបន្ទប់ឃុំខ្លួនរួម អ្នកទោសត្រូវបានគេដាក់ច្រវាក់ជើងបន្តគ្នា ។ យល់ព្រម ។

[១៥:០៤:៤១]

កថាខណ្ឌ១៤៦៖ អ្នកទោសដែលត្រូវបានជាប់ខ្នោះមិនអាចក្រោកឈរបានទេ ។ យល់ព្រម ។

កថាខណ្ឌ១៤៧៖ ជាទូទៅអ្នកទោសស្ត្រីមិនត្រូវបានដាក់ខ្នោះទេ ប្រសិនបើពួកគេមិនបង្កបញ្ហា។ យល់ព្រម ។

កថាខណ្ឌ១៤៨៖ អ្នកទោសទាំងអស់ស្ថិតនៅក្រោមការឃាមកាមរបស់ឆ្មាំ ដែលមានអាវុធជាប្រចាំ ។ ឆ្មាំគុកខាងក្នុង និងខាងក្រៅនៃមន្ទីរឃុំឃាំង បានទទួលការណែនាំយ៉ាងតឹងរ៉ឹង ដើម្បីទប់ស្កាត់មិនឲ្យអ្នកទោសប៉ុនប៉ងរត់គេចខ្លួន ។ យល់ព្រម ។

កថាខណ្ឌ១៥២៖ អ្នកទោសមិនបានអនុញ្ញាតឲ្យហាត់ប្រាណ ឬចាកចេញពីបន្ទប់ឃុំខ្លួនឡើយ ។ យល់ព្រម ។

កថាខណ្ឌ១៥៩៖ អ្នកទោសបានទទួលបបរអាហារបន្តិចបន្តួច ស្ទើរតែដាច់ពោះស្លាប់ ។

ជាលទ្ធផល អ្នកទោសជាច្រើនមានភាពស្គមស្គាំង ឬក៏បាក់កម្លាំងយ៉ាងខ្លាំង ហើយធ្វើឲ្យអ្នកខ្លះស្លាប់ទៀតផង ។ យល់ព្រម ។

កថាខណ្ឌ១៦០៖ ការបង្អត់អាហារអ្នកទោស គឺជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

កថាខណ្ឌ១៦១៖ ឆ្មាំគុក និងអ្នកទោសសំខាន់ៗ បានទទួលរបបអាហារប្រសើរជាងអ្នកទោសធម្មតា ។ យល់ព្រម ។

កថាខណ្ឌ១៦២៖ អ្នកទោសជាច្រើនបានធ្លាក់ខ្លួនឈឺ និងមានរបួស ។ យល់ព្រម ។

កថាខណ្ឌ១៦៦៖ ឱសថព្យាបាលដែលស្តុកទុកនៅមន្ទីរស-២១ មានតិចតួចមែនទែន ។ ពេលណាមានក៏ឱសថទាំងនោះ ត្រូវបានផលិតនៅកម្ពុជា ដោយកម្មករដែលគ្មានជំនាញ ។ យល់ព្រម ។

កថាខណ្ឌ១៦៧៖ ពេទ្យមន្ទីរស-២១ យល់ថា គោលបំណងជាសំខាន់នៃការព្យាបាលអ្នកជំងឺគឺទុកឲ្យអ្នកជំងឺនោះ គឺគ្រាន់តែទុកឲ្យពួកគេនៅរស់ដើម្បីបញ្ចប់ការសួរចម្លើយប៉ុណ្ណោះ ។ យល់ព្រម ។

[១៥:០៧:០៣]

កថាខណ្ឌ១៦៨៖ បុគ្គលិកលនៅស-២១ បានធ្វើវិសោធន៍វេជ្ជសាស្ត្រទៅលើអ្នកទោស ។

យល់ព្រម ។

កថាខណ្ឌ១៦៨(ក)៖ ការស្រាវជ្រាវថ្នាំ គឺត្រូវធ្វើឡើងតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និយាយឲ្យចំគឺ នួន ជា បានបញ្ជាទៅលើ ឌុច ។ យល់ព្រម ។

កថាខណ្ឌ១៦៨(ខ)៖ ការយកមនុស្សរស់ទៅវះកាត់ ។ យល់ព្រម ។

កថាខណ្ឌ១៦៨(គ)៖ ការបូមឈាមពីអ្នកទោស ។ យល់ព្រម ។

កថាខណ្ឌ១៦៨(ឃ)៖ ការយកថ្នាំពេទ្យថ្មីៗទៅពិសោធន៍ជាមួយអ្នកទោស ។ យល់ព្រម ។

កថាខណ្ឌ១៦៩៖ ស្ថានភាពរស់នៅ នៅស-២១ បានធ្វើឲ្យអន់ថយយ៉ាងខ្លាំងដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់អ្នកទោសភាគច្រើន និងបណ្តាលឲ្យពួកគេជាច្រើនស្លាប់ ។ យល់ព្រម ។

កថាខណ្ឌ១៧១៖ មានអ្នកទោសខ្លះបានប៉ុនប៉ងសម្លាប់ខ្លួន ។

អង្គហេតុដូចខាងក្រោមនេះ នៅក្រោមស្ថានភាពឃុំខ្លួននៅទួលស្លែង គឺជាអង្គហេតុមិនមានការតវ៉ា ។

កថាខណ្ឌ១៣៩៖ អ្នកទោសជាទូទៅត្រូវបានគេចងមុខនិងដាក់ខ្នោះដៃ ពេលនាំចូលមកក្នុង ស-២១ ។

កថាខណ្ឌ១៥០៖ --

**លោក ហ្វ្រង់ ស្វ័រ រូ៖**

ហើយមានបញ្ហានៃការបកប្រែមួយ គឺត្រូវបកប្រែ គឺកថាខណ្ឌដូចត្រូវ-- គឺជាៗកម្មវត្ថុនៃការឯកភាព ប៉ុន្តែវានិយាយថា មិនតវ៉ា ។ អាហ្នឹងជាចំណុចតូចមួយនៃការបកប្រែទេ ។ ខ្ញុំគឺថាយើងអាចអានបន្តទៀត ។ សូមអរគុណ ។

[១៥:០៩:១៤]

**ប្រធានអង្គជំនុំ៖**

ហើយអង្គជម្រះគិតថា សម្រាករយៈពេលម្ភៃនាទីសិន ។ មើលទៅមានការនឿយហត់ច្រើនសហព្រះរាជអាជ្ញា ។ ដូច្នេះ សូមប្រកាសសម្រាកម្ភៃនាទីសិន ។

*[សវនាការសម្រាកពីម៉ោង១៥:០៩នាទី ដល់ម៉ោង១៥:៣៣នាទី]*

[១៥:៣៣:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចប្រកាស បន្តកិច្ចដំណើរការសវនាការរបស់យើងតទៅទៀត សូមអញ្ជើញលោកសហព្រះរាជអាជ្ញាឡើងអានជាបន្ត ។

**លោក រ៉ូបឺត ពើទីត៖**

ឯកសារដើម

អរគុណលោកប្រធាន ខ្ញុំមានអារម្មណ៍ថា រាងស្រួលបន្តិចហើយបន្ទាប់ពីបានសម្រាក ។

ខ្ញុំជាដំបូងសូមធ្វើការកែប្រែការដែលខ្ញុំភ្លេចអានចំពោះអង្គហេតុនៅក្រោមចំណងជើង "ស្ថានភាពនៃការឃុំខ្លួននៅទួលស្លែង" គឺកថាខណ្ឌ១៦០៖ ការបង្អត់អាហារអ្នកទោសជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺអង្គហេតុនេះបានយល់ព្រមដែរ ដែលខ្ញុំរំលង ។ ខ្ញុំសូមបន្តថា ក្រោមលក្ខខណ្ឌឃុំខ្លួននៅទួលស្លែង គឺអង្គហេតុខាងក្រោមនេះមិនតវ៉ា ។

កថាខណ្ឌ១៣៩៖ អ្នកទោសជាទូទៅត្រូវបានគេចងមុខ និងដាក់ខ្នោះដៃនៅពេលនាំចូលក្នុងមន្ទីរស-២១ ។

កថាខណ្ឌ១៥០៖ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យនិយាយគ្នា ឬនិយាយជាមួយឆ្មាំគុកឡើយ ។

កថាខណ្ឌ១៥១៖ នៅពេលដែលអ្នកទោសបានមកដល់មន្ទីរស-២១ ដំបូងពួកគេត្រូវបានសម្រាតសម្លៀកបំពាក់ចេញដោយទុកតែខោខ្លីប៉ុណ្ណោះ ។

កថាខណ្ឌ១៥៣៖ អ្នកទោសភាគច្រើនគ្មានគ្រែសម្រាប់ដេកឡើយ ហើយត្រូវដេកផ្ទាល់លើឥដ្ឋ អ្នកទោសសំខាន់ៗខ្លះត្រូវបានគេផ្តល់កន្ទេល ឬពូកចាស់ៗឲ្យសម្រាប់ដេក ។

កថាខណ្ឌ១៥៤៖ អ្នកទោសជាច្រើននាក់ត្រូវបានមូសខាំឡើងសុសខ្លួន ។

កថាខណ្ឌ១៥៦៖ គ្មានសម្ភារៈសម្រាប់ងូតទឹកឡើយ ហើយគេមិនបានដោះខ្នោះចេញទេ ពេលដែលអ្នកទោសងូតទឹក ។ ការងូតទឹកត្រូវបានគេបាញ់ទុយោទឹកពីមាត់ទ្វារចូលក្នុងបន្ទប់ គោលបំណងជាចម្បងនៃការបាញ់ទឹកនេះគឺ ដើម្បីលាងសម្អាតលាងបន្ទប់ឃុំឃាំងមិនមែនសម្អាតអ្នកទោសទេ ។

កថាខណ្ឌ១៥៧៖ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យចេញពីបន្ទប់ឃុំខ្លួនដើម្បីទៅបង្គន់ទេ ប៉ុន្តែត្រូវបានបង្ខំឲ្យនោមដាក់ប៊ីដុងទឹក និងបន្ទោបង់ដាក់កេះគ្រាប់ក្នុងបន្ទប់ឃុំខ្លួនរបស់ពួកគេ ។

កថាខណ្ឌ១៥៨៖ ជាធម្មតាអ្នកទោសបានទទួលអាហារគ្មានគុណភាពពីរដងក្នុងមួយថ្ងៃ ដែលជាបបររាវ។

កថាខណ្ឌ១៦៣៖ សេវាពេទ្យនៅស-២១ ត្រូវបានផ្តល់ជូនដោយក្រុមពេទ្យដែលមានគ្នាបីទៅប្រាំនាក់ ដែលមិនបានសិក្សាវិជ្ជាពេទ្យទេ ។ ហើយពេលខ្លះគ្រាន់តែជាកូនក្មេង និងធ្វើការដោយគ្មានការត្រួតពិនិត្យពីគ្រូពេទ្យឡើយ ។

កថាខណ្ឌ១៦៤៖ មានអ្នកទោសខ្លះបានទទួលការចាក់ថ្នាំតាមសរសៃរនៅពេលល្ងាច ហើយបានឃើញស្លាប់នៅពេលព្រឹកថ្ងៃបន្ទាប់ ។

កថាខណ្ឌ១៦៥៖ អ្នកទោសជាច្រើនដែលត្រូវការជាចាំបាច់ នូវការព្យាបាលជាបន្ទាន់ ត្រូវបានគេទុកចោលដោយមិនរវីរវល់ ឬបានព្យាបាលដែលមិនត្រឹមត្រូវ ។

កថាខណ្ឌ១៧០៖ អ្នកទោស៨ឬ៩នាក់ ដែលនៅរស់ ដែលនៅរួមបន្ទប់ជាមួយ វ៉ាន់ ណាត បានស្លាប់ក្នុងរយៈពេល១ខែ។

ទាំងអស់នេះគឺជាអង្គហេតុដែលពាក់ព័ន្ធ ហើយបានយល់ព្រម និងមិនតវ៉ានៅក្រោមស្ថានភាពនៃការឃុំខ្លួននៅស-២១ ។ ដូច្នេះ ខ្ញុំស្នើសុំមេធាវីការពារក្តីឲ្យសុំបញ្ជាក់ទៅលើអង្គហេតុទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ មេធាវីការពារក្តីយល់ស្រប ចំពោះអង្គហេតុដែលបានយល់ស្រប និងមិនតវ៉ា ចំពោះកថាខណ្ឌដែលបានអានឡើងទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួននៅទួលស្លែង ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាសូមបន្តទៀត ។

**លោក រ៉ូបឺត ពើទីត៖**

អរគុណលោកប្រធាន នៅក្រោមចំណងជើងស្ថានភាពឃុំខ្លួននៅព្រៃស អង្គហេតុដូចខាងក្រោមមិនតវ៉ា ។

កថាខណ្ឌ១៧២៖ នៅស-២៤ មនុស្សត្រូវបានគេបង្ខំឲ្យធ្វើតាមបែបដាក់ទណ្ឌកម្មដើម្បីកសាងខ្លួន ឬដែលគេតែងនិយាយថាការលត់ដំខ្លួន ។

កថាខណ្ឌ១៧៤៖ អ្នកទោសដែលត្រូវបានបញ្ជូនទៅស-២៤ បានឃាមការពារយ៉ាងតឹងរ៉ឹងទាំងនៅពេលធ្វើការនិងទាំងនៅពេលយប់ ។

កថាខណ្ឌ១៧៥៖ អ្នកដែលត្រូវបានបញ្ជូនទៅព្រៃស ត្រូវបានចែកជាបីកម្រិត៖ ក្រុមទីមួយ គឺសម្រាប់លត់ដំស្រាលៗ កម្រិតទីពីរ គឺសម្រាប់ករណីមធ្យម និងកម្រិតទីបី គឺសម្រាប់ករណីធ្ងន់ធ្ងរបំផុត ។

កថាខណ្ឌ១៧៦៖ អ្នកទាំងឡាយណាដែលស្ថិតនៅក្នុងកម្រិតទីបី ត្រូវបានគេដាក់ខ្នោះនៅពេលយប់ ហើយមិនត្រូវបានគេអនុញ្ញាតឲ្យរស់នៅក្នុងផ្ទះធម្មតាឡើយ ។

កថាខណ្ឌ១៧៧៖ អ្នកជាប់ឃុំបានទទួលរបបអាហារពីរដងក្នុងមួយថ្ងៃ ម្តងនៅពេលថ្ងៃត្រង់ និងម្តងនៅពេលល្ងាច ។ មានករណីលើកលែងតិចតួចប៉ុណ្ណោះ តែជាទូទៅអ្នកទោសនៅព្រៃសទទួលបានអាហារមិនគ្រប់គ្រាន់ទេ ។ ចំពោះអ្នកជាប់ឃុំក្នុងកម្រិតទីបី បានទទួលរបបអាហារតិចជាងអ្នកដទៃទៀត ។

[១៥:៣៩:៥៩]

កថាខណ្ឌ១៧៩៖ អ្នកជាប់ឃុំនៅព្រៃសក្នុងនោះរួមទាំងស្ត្រីនិងកុមារផងត្រូវបានគេបង្ខំឲ្យធ្វើការងារក្នុងវាលស្រែ រកត្រី ដាំបន្លែ ស្ទូងស្រូវ លើកទំនប់ ជីកប្រឡាយ និងជីកស្រះ ។

កថាខណ្ឌ១៨០៖ អ្នកជាប់ឃុំបានធ្វើការទាំងថ្ងៃទាំងយប់ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ និងមិនត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកក្នុងពេលធ្វើការឡើយ ។ នៅព្រៃស បែបផែននៃថ្ងៃធ្វើការ គឺចាប់ផ្តើមពីព្រលឹមស្រាងៗ គឺនៅចន្លោះម៉ោង៤ និងម៉ោង៧ ព្រឹក និងបញ្ចប់នៅចន្លោះម៉ោង១០ និង១២ យប់ ដោយមានពេលឈប់សម្រាកពីរម៉ោងដើម្បីហូបអាហារ ។

កថាខណ្ឌ១៨១៖ ការបំពេញការងារស្ថិតនៅក្រោមការឃ្លាំមើលរបស់អ្នកយាម ដែលតម្រូវឲ្យអ្នកទោសប្រឹងប្រែងធ្វើការ និងមិនមានការអត់ឱនឡើយប្រសិនបើពួកគេធ្វើការយឺតយ៉ាវ ។

កថាខណ្ឌ១៨២៖ ពេលអ្នកទោសទាំងនោះឈឺ ឬមកយឺត ឬធ្វើការងារមិនបានពេញចិត្ត ពួកគេត្រូវបានវាយដំ និងជេរប្រមាថ ។

កថាខណ្ឌ១៨៣៖ អ្នកទោសត្រូវបានដាក់ទារុណកម្ម ចំពោះទង្វើខុសសីលធម៌ផ្លូវភេទ ការធ្វើពុតជាឈឺ និងការលួច ។

កថាខណ្ឌ១៨៤៖ អ្នកទោសនៅរួមជាមួយនឹងឈ្មោះ X ត្រូវបានគេវាយដំចំនួនពីរដង ពីរទៅបីលើកដែរ ។

កថាខណ្ឌ១៨៥៖ ជួនពេលខ្លះអ្នកយាមនៅមន្ទីរស-២៤ ដាក់ទណ្ឌកម្មអ្នកទោស តាមរយៈការបង្អត់អាហារ ។

កថាខណ្ឌ១៨៦៖ អ្នកទោសភ័យខ្លាចថា ប្រសិនបើពួកគាត់មិនខិតខំធ្វើការតាមតែពួកគាត់អាចធ្វើទៅបាននោះ ពួកគាត់នឹងត្រូវបានយកទៅសម្លាប់ចោលជាមិនខាន។

កថាខណ្ឌ១៨៧៖ ការប្រជុំណែនាំត្រូវបានធ្វើឡើងជាទៀងទាត់នៅឯព្រៃស ដែលក្នុងអំឡុងពេល

នោះអ្នកទោសត្រូវបានណែនាំឲ្យធ្វើការងារឲ្យឆាប់ ឲ្យរហ័សរហួន និងឲ្យបានផលច្រើន ។ ពួកគេបានត្រូវអប់រំនិងបំពាក់បំប៉នននយោបាយ ហើយតម្រូវឲ្យចូលរួមក្នុងអង្គប្រជុំស្វ័យទិតៀន ដែលជាពេលដែលពួកគេត្រូវបានបង្ខំឲ្យសារភាពអំពីកំហុសរបស់ខ្លួន និងប្រាប់អំពីកំហុសរបស់អ្នកដទៃ ។

កថាខណ្ឌ១៨៨៖ ការបាត់ខ្លួនអ្នកទោសនាពេលយប់ វាជារឿងសាមញ្ញទៅហើយ ។ ហើយកាលណាអ្នកណាម្នាក់ត្រូវបានគេនាំយកទៅ អ្នកនោះមិនដែលបានត្រឡប់មកវិញឡើយ ។

កថាខណ្ឌ១៨៩៖ អ្នកទោសនៅព្រៃសខ្លះ គឺមនុស្សមកពីកម្រិតទីបី ត្រូវចាប់បញ្ជូនទៅប្រហារជីវិតនៅជើងឯក ។

កថាខណ្ឌ១៩០៖ យ៉ាងហោចណាស់មានមនុស្សចំនួន៥៧១នាក់ ដោយរាប់បញ្ចូលទាំងអ្នកទោសនិងបុគ្គលិកមន្ទីរស-២៤ ខ្លួនឯងផងដែរត្រូវបានបញ្ជូនពីមន្ទីរស-២៤ ទៅកាន់ទួលស្លែង ។

អង្គហេតុទាំងអស់នេះ គឺអង្គហេតុដែលមិនបានតវ៉ាទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួន នៅស-២៤ ។ ខ្ញុំសូមឲ្យមេធាវីការពារក្តី ធ្វើការបញ្ជាក់ចំពោះអង្គហេតុទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ មេធាវីការពារក្តីសូមធ្វើការបញ្ជាក់ថា មេធាវីការពារក្តីមិនធ្វើការតវ៉ាចំពោះកថាខណ្ឌទាំងឡាយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួននៅស-២៤។ សូមអរគុណ។

**ចៅក្រម និល ណុន៖**

សហព្រះរាជអាជ្ញាបន្តទៀត ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន ។ ក្រោមចំណងជើងថា ការសួរចម្លើយ អង្គហេតុដូចខាងក្រោមត្រូវបានយល់ស្រប។

កថាខណ្ឌ១៩១៖ ភាគច្រើននៃអ្នកទោសដែលត្រូវជាប់ឃុំនៅមន្ទីរស-២១ ត្រូវបានគេសួរចម្លើយជាលក្ខណៈប្រព័ន្ធ ។

កថាខណ្ឌ១៩២៖ ការសួរចម្លើយត្រូវបានធ្វើឡើង ដោយបុគ្គលិកមន្ទីរស-២១ ដែល ឌុច និង អនុប្រធានរបស់គាត់បានរៀបចំបែងចែកជាក្រុម ជាច្រើនក្រុមផ្សេងៗគ្នា ។

កថាខណ្ឌ១៩៣ ។ យល់ព្រម ។ អ្នកសួរចម្លើយមិនអាចជ្រើសរើសអ្នកទោសដែលខ្លួនចង់សួរបានឡើយ ប៉ុន្តែត្រូវបានចាត់តាំងឲ្យទទួលយកអ្នកទោសទៅសួរចម្លើយ។ យល់ព្រម ។

កថាខណ្ឌ១៩៥៖ តាមបែបផែននៅក្នុងបន្ទប់សួរចម្លើយ អ្នកទោសត្រូវបានគេដាក់ខ្នោះជើងជាប់នឹងតុ ។ បន្ទាប់មកខ្នោះដៃត្រូវបានដោះចេញ ដើម្បីទុកឲ្យមានការសួរចម្លើយអ្នកទោស និងសរសេរចម្លើយសារភាព ។ យល់ព្រម ។

កថាខណ្ឌ១៩៦៖ អ្នកសួរចម្លើយបានសួរអ្នកទោសអំពីជីវប្រវត្តិ និងសកម្មភាពរបស់ពួកគេដែលនាំឲ្យមានការចាប់ខ្លួន។ យល់ព្រម ។

កថាខណ្ឌ១៩៧៖ រាល់ការសួរចម្លើយទាំងអស់ មិនតែងតែឈានទៅដល់ចម្លើយសារភាពជាលាយលក្ខណ៍អក្សរជានិច្ចនោះទេ ។ យល់ព្រម។

កថាខណ្ឌ១៩៩៖ មិនមានគោលការណ៍ជាទូទៅណាមួយ ថាតើអ្នកទោសម្នាក់ត្រូវសួរចម្លើយប៉ុន្មានលើក ឬក៏ក្នុងការសួរចម្លើយមួយលើកត្រូវចំណាយពេលយូរប៉ុនណានោះទេ ។ យល់ព្រម ។

កថាខណ្ឌ១៩៩(ក)៖ ការសួរចម្លើយត្រូវបានបញ្ចប់ លុះត្រាតែចម្លើយសារភាពរបស់អ្នកទោសទាំងនោះ ត្រូវបានពិចារណាថាចប់សព្វគ្រប់ ។ យល់ព្រម។

កថាខណ្ឌ១៩៩(ខ)៖ អ្នកទោសអាចត្រូវបានសួរចម្លើយច្រំដែលៗ និងត្រូវបានបង្ខំឲ្យសរសេរព្រាងចម្លើយសារភាពរបស់ខ្លួនជាច្រើនលើកច្រើនសា។ យល់ព្រម។

កថាខណ្ឌ២០១៖ ឌុច បានណែនាំវិធីសាស្ត្រសួរចម្លើយចំនួនបី នៅមន្ទីរស-២១ "វិធីសាស្ត្រត្រជាក់" "វិធីសាស្ត្រក្តៅ" និង "វិធីសាស្ត្រអង្កៀម"។ យល់ព្រម។

កថាខណ្ឌ២០១(ក)៖ វិធីសាស្ត្រត្រជាក់ គឺជាការសួរចម្លើយតាមរបៀប ប្រើប្រាស់ការបញ្ចុះបញ្ចូលឃោសនា ដោយមិនធ្វើទារុណកម្ម ឬជេរស្តីឡើយ។ អង្គហេតុដូចខាងក្រោមមិនបានតវ៉ា ក្រោមចំណងជើង "ការសួរចម្លើយ" ។

កថាខណ្ឌ១៩៨៖ ការសួរចម្លើយមានជារៀងរាល់ថ្ងៃពីម៉ោង៧ព្រឹក ដល់ម៉ោង១១ព្រឹក ពីម៉ោង២រសៀល ដល់ម៉ោង៥រសៀល និងពីម៉ោង៧យប់ ដល់ម៉ោង១១យប់ ។ ទាំងអស់នេះគឺជាអង្គហេតុដែលបានព្រមព្រៀង និងមិនបានតវ៉ានៅក្រោមចំណងជើងថា ទាក់ទងទៅនឹងការសួរចម្លើយ ។ ដូច្នេះ

ខ្ញុំសូមឲ្យមេធាវីការពារក្តីធ្វើការបញ្ជាក់ទៅលើអង្គហេតុទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីការពារក្តី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីការពារក្តីសូមធ្វើការបញ្ជាក់ថា មានការយល់ព្រមទៅលើអង្គហេតុទាំងអស់នេះ ហើយគ្មានការ មិនមានការតវ៉ាទៅលើកថាខណ្ឌ ដែលសហព្រះរាជអាជ្ញាបានទើបតែអានទាក់ទងទៅនឹងការសួរចម្លើយនៅស-២១។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកសហព្រះរាជអាជ្ញាអានបន្តទៀត ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន ។ នៅក្រោមចំណងជើងថា "ការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធក្នុងពេលសួរចម្លើយ" អង្គហេតុដូចខាងក្រោមត្រូវបានយល់ព្រម។

កថាខណ្ឌ២០៤៖ សៀវភៅកំណត់ដៃចំនួនបីក្បាលរបស់អ្នកសួរចម្លើយ នៅមន្ទីរស-២១ មានដូចជា "បញ្ជីស្ថិតិនៃមន្ទីរសន្តិបាលស-២១ នយោបាយមនោគមវិជ្ជា និងអង្គការចាត់តាំង" "សៀវភៅកំណត់ដៃរបស់ X" និង "សៀវភៅកំណត់ហេតុដៃរបស់ X និង Y" ដែលបានកត់ត្រា ទុកនូវការណែនាំដែលបានទទួលពាក់ព័ន្ធនឹងការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរស-២១ ។ យល់ព្រម ។

កថាខណ្ឌ២០៤(ក)៖ បញ្ជីស្ថិតិនេះមានការណែនាំផ្នែកនយោបាយ និងការសួរចម្លើយដែលត្រូវបានបង្រៀនដល់អ្នកសួរចម្លើយដូចជា "ឲ្យបំបាក់ស្មារតីអ្នកទោសដោយការអប់រំសតិអារម្មណ៍ ឬការធ្វើទារុណកម្ម" និង "ប្រសិនបើអង្គការប្រាប់ថាកុំឲ្យវាយ កុំវាយដាច់ខាត ។ ប្រសិនបើបក្សបញ្ជាឲ្យយើងវាយ យើងត្រូវវាយដោយម្ចាស់ការ វាយពួកវាឲ្យទាល់តែនិយាយ កុំឲ្យរួចខ្លួនដោយសេចក្តីស្លាប់ កុំឲ្យពួកវាអស់កម្លាំងដល់ថ្នាក់ធ្លាក់ខ្លួនឈឺ ហើយស្លាប់" ។ យល់ព្រម ។

កថាខណ្ឌ២០៤(ខ)៖ ការណែនាំ និងមនោគមន៍វិជ្ជានយោបាយ ដែលមាននិយាយនៅក្នុងសៀវភៅកំណត់ដៃរបស់ X និងបញ្ជីស្ថិតិបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដអំពីការបង្រៀន និងការណែនាំរបស់ ឌុច នៅមន្ទីរស-២១ ហើយជា "គំនិត" របស់គាត់ ។ យល់ព្រម ។

កថាខណ្ឌ២០៨៖ គោលបំណងនៃការធ្វើទារុណកម្មនៅមន្ទីរស-២១ គឺដើម្បីទទួលបាននៅ

ចម្លើយពេញលេញមួយដែលរួមមានបទល្មើស ដែលអ្នកទោសត្រូវគេចោទ និងដែលមានកំណត់ឈ្មោះជន ដែលគេបានអះអាងថា ជាខ្មាំងនៃរបបនោះ ។ យល់ព្រម ។

កថាខណ្ឌ២០៤៖ ទាក់ទិននឹងអ្នកទោសវៀតណាម គោលបំណងនៃការសួរចម្លើយគឺដើម្បីទទួលបាននូវចម្លើយសារភាពដែលបង្ហាញ "វៀតណាមបានឈ្លានពានប្រទេសកម្ពុជា ដើម្បីបញ្ចូលកម្ពុជាក្នុងសហព័ន្ធឥណ្ឌូចិន" ។ យល់ព្រម ។

កថាខណ្ឌ២១១៖ ខុសពីអ្នកទោសកម្ពុជា ការសួរចម្លើយអ្នកទោសវៀតណាមត្រូវគេថតយកសំឡេង ហើយបន្ទាប់មកចម្លើយសារភាពមួយចំនួនរបស់ពួកគេត្រូវបានផ្សព្វផ្សាយ តាមវិទ្យុក្នុងគោលដៅធ្វើការឃោសនា ។ អង្គហេតុដូចខាងក្រោមនេះ ទាក់ទងទៅនឹងការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធក្នុងពេលសួរចម្លើយ មិនមានការតវ៉ា ។

កថាខណ្ឌ២០៥៖ ផលវិបាកផ្នែករាងកាយអំពីការរងទារុណកម្ម ស្នាមរបួស ការហូរឈាម ស្នាមជាំអ្នកទោស សន្លប់ អ្នកខ្លះបាត់ក្រចកដៃ ឬក្រចកជើង គឺគេអាចមើលឃើញយ៉ាងច្បាស់ នៅលើអ្នកទោសដែលបានជាប់គុកនៅមន្ទីរស-២១ និងអ្នកដែលត្រូវបានកត់សម្គាល់ដោយបុគ្គលិកមន្ទីរស-២១ ។

កថាខណ្ឌ២០៦៖ អ្នកទោសភាគច្រើននៅមន្ទីរស-២១ "មានរបួស ហើយមានហើមមុខ និងខ្លោចម្ភុំត្រចៀកដោយសារឆក់ខ្សែភ្លើង" ។

កថាខណ្ឌ២០៧៖ អ្នកយាមមួយចំនួននៅមន្ទីរស-២១ ពួកគេផ្ទាល់ក៏ធ្លាប់បានឃើញ និងបានឮអំពីការធ្វើទារុណកម្ម ដែលត្រូវបានប្រព្រឹត្តនៅទីនោះដែរ ។

កថាខណ្ឌ២១៤៖ ថ្ងៃមួយនៅក្នុងបន្ទប់ជាងគំនូរ ឌុច បានបញ្ជា X ឲ្យវាយតប់ជាមួយគ្នាជាមួយជាងចម្លាក់ម្នាក់ឈ្មោះ X ដោយឲ្យវាយគ្នាទៅវិញទៅមកនឹងទុយោកៅស៊ូ ។ ហើយទាំងអស់នេះនៅក្នុងការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធក្នុងពេលសួរចម្លើយ ដែលយើងបានលើកឡើងជាអង្គហេតុដែលបានយល់ព្រម និងមិនមានការតវ៉ា ។ ដូច្នេះ ខ្ញុំសូមឲ្យមេធាវីការពារក្តីធ្វើការបញ្ជាក់ទៅលើអង្គហេតុទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ទាក់ទងទៅនឹងកថាខណ្ឌ ដែលទើបតែបានអានអម្បាញ់មិញនេះ ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធក្នុងពេលសួរចម្លើយ តាងនាមឲ្យជនជាប់ចោទមេធាវីការពារក្តី សូមធ្វើការបញ្ជាក់អំពីការយល់ព្រម ហើយនិងការមិនតវ៉ា ។ ខ្ញុំសូមឲ្យមានការបំភ្លឺ ដែលលោក លោកស្រី ធ្វើការកត់សម្គាល់ឃើញនៅទីនេះ ។ យើងបានយល់ព្រមជាមួយនឹងសហព្រះរាជអាជ្ញា គឺយើងមិនអានកថាខណ្ឌ២០៣ ទេ យើងបានយល់ព្រមមិនអានកថាខណ្ឌនេះ ទោះបីជា វាបញ្ជាក់ថា ឌុច យល់ព្រមក៏ដោយ ។ ប៉ុន្តែ កថាខណ្ឌនេះ គឺកថាខណ្ឌដែលនៅក្នុងដីកាដំណោះស្រាយ គឺយើងចង់ឲ្យមានការដកយកទាំងស្រុងតែម្តង ដើម្បីឲ្យយើងយល់ថា ជនជាប់ចោទគឺគាត់យល់ព្រម ដូចដែលនៅកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះមួយចំនួន ។

កថាខណ្ឌ២១៤ ដែលលោកបានអាន វាបានលើកឡើងនៅក្នុងការចូលរួមរបស់ ឌុច រួចទៅហើយ គឺវាមានចែងនៅក្នុងផ្នែកនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន ។ ក្រោមចំណងជើងថា ការចូលរួមធ្វើទារុណកម្មដោយផ្ទាល់របស់ឌុច អង្គហេតុដូចខាងក្រោម បានយល់ស្រប ។

កថាខណ្ឌ២១៥(ក)៖ មនុស្សម្នាក់ក្នុងចំណោមមនុស្ស ដែលបានទទួលបញ្ជាបែបដូច្នេះពី ឌុច គឺសមមិត្ត X ដែល “ចូលចិត្តធ្វើទារុណកម្មណាស់” ។ យល់ព្រម ។

កថាខណ្ឌ២១៥(ខ)៖ នៅពេលដែល X មិនអាចធ្វើឲ្យអ្នកទោសណាម្នាក់ឆ្លើយ នោះគាត់ត្រូវបាន ឌុច ប្រាប់ឲ្យ “ប្រើការធ្វើទារុណកម្ម” ។

[១៥:៥៤:៤៤]

កថាខណ្ឌ២១៧៖ ឌុច បានទទួលបញ្ជាពីថ្នាក់លើរបស់គាត់ ដោយរួមទាំង X និង សុន សេន ផងថា គេធ្វើទារុណកម្មលើអ្នកទោសមួយចំនួន និងអនុវត្តនូវបញ្ជាទាំងនោះ ។ យល់ព្រម ។

កថាខណ្ឌ២១៩៖ វិធីធ្វើទារុណកម្ម ដែលប្រើជាទូទៅនៅមន្ទីរស-២១ គឺការវាយដោយដំបង ពីព្រោះវិធីផ្សេងៗទៀត ធ្វើឲ្យខាតពេលវេលា ។ យល់ព្រម ។

កថាខណ្ឌ២២០៖ ប្រសិនបើអ្នកទោសមិនសារភាពឲ្យបាន “ត្រឹមត្រូវ” ទេ ការធ្វើទារុណកម្ម កាន់តែធ្ងន់ធ្ងរឡើង ។ ការសារភាពមួយមិនច្បាស់លាស់ បើវាមិនត្រូវបានរៀបរាប់ឲ្យបានគ្រប់គ្រាន់ ឬ មិនមានរៀបរាប់ឈ្មោះជនក្បត់ផ្សេងទៀត ។ យល់ព្រម ។

កថាខណ្ឌ២២១៖ បានយល់ព្រម ។ ឌុច បានដឹងអំពីការអនុវត្តនៅមន្ទីរស-២១ អំពីការចាក់ទម្លុះ និងការដកក្រចកដៃ និងក្រចកជើង ។ យល់ព្រម ។

កថាខណ្ឌ២២៣៖ ឌុច បានទទួលស្គាល់ថា ទឹកត្រជាក់ និងកង្ហារ គឺជាវិធីធ្វើទារុណកម្មមួយ ដែលបានប្រើនៅមន្ទីរស-២១ ហើយថាគាត់មិនបានជំទាស់នឹងការអនុវត្តនេះទេ ។ យល់ព្រម ។

កថាខណ្ឌ២២៦៖ ក៏យល់ព្រមដែរ ។ ការអនុវត្តមួយទៀតដែលមានកើតឡើងនៅមន្ទីរស-២១ គឺការបង្ខំឲ្យអ្នកទោស ឲ្យលុតជង្គង់គោរពរូបឆ្កែ ។ ឌុច បានដឹងឮអំពីការអនុវត្តនេះ ហើយបានជំរុញ ឲ្យមានការធ្វើបែបនោះ នៅក្នុងវគ្គបណ្តុះបណ្តាលអ្នកសួរចម្លើយមួយកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៧៨ ។ គឺខ្ញុំសុំកែប្រែ គឺកថាខណ្ឌ២១៥(ក) ទៅដល់កថាខណ្ឌ២២៦ គឺឋិតនៅក្រោមចំណងជើងថា “វិធីធ្វើទារុណកម្ម” ហើយអង្គហេតុទាំងអស់នោះ ពី២១៤(ក) ទៅដល់ ២២៦ គឺខ្ញុំយល់ស្រប ។ ហើយ នៅក្រោមប្រធានបទដដែល គឺវិធីសាស្ត្រធ្វើទារុណកម្ម អង្គហេតុទាំងអស់មិនបានតវ៉ា ។

កថាខណ្ឌ២២៤៖ វិធីធ្វើទារុណកម្មមួយទៀត ដែលបានប្រើនៅមន្ទីរស-២១ គឺការសម្រាតខោ អ្នកទោស រួចយកប្រដាប់ឆក់មកឆក់ប្រដាប់ភេទ ឬត្រចៀកអ្នកទោស ។

កថាខណ្ឌ២២៨៖ អ្នកទោសនៅមន្ទីរស-២១ម្នាក់ឈ្មោះ X ត្រូវបានវាយនឹងឈើមួយកំណាត់ នៅលើខ្នងរបស់គាត់ជាច្រើនលើកច្រើនសា ហើយក្រចកជើងទាំងសង្ខាងរបស់គាត់ត្រូវបានចាប់ដក ចេញ ។ គាត់បានទទួលរងនូវការឆក់ភ្លើងទៅនឹងទងត្រចៀករបស់គាត់ ហើយនៅថ្ងៃទី៣ នៃការសួរ ចម្លើយ គាត់បានសន្លប់ចំនួនពីរដង ។ X ត្រូវបានគេប្រព្រឹត្តបែបនេះចំពោះគាត់អស់រយៈពេលចំនួន១២ ថ្ងៃ និង១២យប់ ។

កថាខណ្ឌ២២៩៖ អ្នកទោសនៅមន្ទីរស-២១ម្នាក់ឈ្មោះ Y ត្រូវបានបង្ហាញពីឧបករណ៍ធ្វើ ទារុណកម្មផ្សេងៗនៅក្នុងបន្ទប់សួរចម្លើយ ហើយប្រាប់គាត់ ប្រាប់ឲ្យគាត់ជ្រើសរើសឧបករណ៍ដែល នឹងត្រូវប្រើសម្រាប់ធ្វើទារុណកម្មលើរូបគាត់ ។ គាត់ត្រូវបានគេវាយនឹងខ្សែតី រំពាត់ផ្តៅ និងខ្សែភ្លើង លើខ្នងរបស់គាត់ពេលដែលដៃទាំងពីរជាប់ខ្នោះ និងត្រូវបង្ខំឲ្យដេកផ្កាប់មុខនៅលើដី ។ ខ្នងរបស់គាត់ មានស្នាមរបួសពាសពេញ ហើយឈាមហូរពាសពេញលើកម្រាលឥដ្ឋ ។ គាត់ត្រូវបានគេឆក់ខ្សែភ្លើង

ផងដែរ ។ Y ត្រូវគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃអស់រយៈពេលពីរសប្ដាហ៍ ។

ការអង្គហេតុទាំងអស់នៅក្នុងក្រោមចំណងជើងថា វិធីធ្វើទារុណកម្មត្រូវបានយល់ព្រម និងមិនមានការតវ៉ា ។ ដូច្នេះ ខ្ញុំសូមឲ្យមេធាវីការពារក្ដីធ្វើការបញ្ជាក់ទៅលើអង្គហេតុទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីការពារ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីការពារក្ដី សូមធ្វើការបញ្ជាក់អំពីការយល់ព្រមនិងការមិនតវ៉ាចំពោះកថាខណ្ឌដែលសហព្រះរាជអាជ្ញាទើបតែបានអានអម្បាញ់មិញនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាអានបន្តទៀត បាទ ។

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអរគុណ លោកប្រធាន ។

តទៅនេះ គឺថាក្រោមចំណងជើងថា ព្រៃស គឺអង្គហេតុដូចខាងក្រោមនេះ គឺមិនមានការតវ៉ា ។

កថាខណ្ឌ២៣៣៖ នៅក្នុងបន្ទប់មួយនៅស-២៤ អ្នកទោសប្រុសស្រី ត្រូវបានសួរចម្លើយដោយឆក់ខ្សែភ្លើង ។

កថាខណ្ឌ២៣៤៖ អ្នកដែលត្រូវបានបញ្ជូនឲ្យព្រៃសលុះដល់ត្រលប់មកវិញ ត្រូវគេកោរសក់ក្បាលអស់ ហើយស្បែកមានដំបៅរលួយដោយសារឆក់ខ្សែភ្លើង ការវាយដំ និងការវាយដោយរំពាត់នៅពេលសួរចម្លើយ ។ ទាំងអស់នេះ ជាអង្គហេតុដែលមិនបានតវ៉ានៅក្នុងព្រៃស ហើយខ្ញុំសូមឲ្យមេធាវីមេត្តាបញ្ជាក់ពីអង្គហេតុនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីការពារ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ ។ មេធាវីការពារសូមបញ្ជាក់ថា យើងមិនមានការតវ៉ាទេ ទើបនឹងកថាខណ្ឌដែលបានអានទាក់ទងទៅនឹងព្រៃស ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាបន្តទៀត។

**លោក រ៉ូប៊ឺត ពើទីត៖**

ក្រោមចំណងជើងថា អំណាចក្នុងការបញ្ជាឲ្យមានការសម្លាប់នោះ អង្គហេតុដូចខាងក្រោមនេះត្រូវបានយល់ព្រម ។

កថាខណ្ឌ២៣៩៖ ឌុច ហើយនិង X ជាអ្នកបញ្ជាឲ្យមានការសម្លាប់អ្នកទោសនៅក្នុងបរិវេណស-២១ ។ ឯកភាព ។

កថាខណ្ឌ២៤៣៖ តាមបែបផែននៅស-២១ អ្នកទោសត្រូវបានគេសម្លាប់ក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីពួកគេបញ្ចប់ចម្លើយសារភាពរបស់គេ ។

តទៅនេះគឺថា ទាក់ទងទៅនឹងអំណាចក្នុងការសម្លាប់នោះគឺថាដែលមិនតវ៉ា ។ អ្នកទោសជាងមួយ១២,៣៨០នាក់ ត្រូវបានគេសម្លាប់នៅស-២១ ។ នេះជាអង្គហេតុដែលបាន ដែលថាទាក់ទងទៅនឹងអំណាចក្នុងការសម្លាប់នោះត្រូវបានយល់ព្រម និងមិនតវ៉ា ។ សូមឲ្យមាការបញ្ជាក់មេធាវីការពារ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីការពារ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណ លោកប្រធាន ។

មេធាវីការពារ សូមបញ្ជាក់ថា ខ្លួនមិនតវ៉ា ហើយខ្លួនឯកភាពទាក់ទងទៅនឹងកថាខណ្ឌ ដែលទើបតែបានអាននេះ ហើយទាក់ទងទៅនឹងអំណាចក្នុងការបញ្ជាឲ្យមានការសម្លាប់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាបន្តទៀត ។

**លោក រ៉ូប៊ឺត ពើទីត៖**

ក្រោមចំណងជើងថា ការសម្លាប់នៅជើងឯក កថាខណ្ឌដូចខាងក្រោមនេះត្រូវបានយល់ព្រម ។

កថាខណ្ឌ២៤៧៖ ឌុច បានទៅជើងឯកក្នុងឆ្នាំ១៩៧៧ តាមការបញ្ជារបស់សុន សេន ។

កថាខណ្ឌ២៥១(ក)៖ ត្រូវបានឯកភាព ។ អ្នកទោសត្រូវបានចងបិទមុខ និងចងដៃទៅខាងក្រោយ ។ យល់ព្រម ។

កថាខណ្ឌ២៥៣៖ ឌុច ត្រូវបានបញ្ជាដោយ សុន សេន និង នួន ជា ឲ្យបញ្ជាអ្នកទោសដ៏ច្រើនដែលជាប់នៅមន្ទីរស-២១ ដើម្បីទៅជើងឯកដើម្បីសម្លាប់ក្នុងពេលមួយដងៗខុសៗគ្នា ។ គោលបំណងនៃការសម្លាប់ដ៏ច្រើនបែបនេះ គឺដើម្បីទុកទីកន្លែងសម្រាប់ដាក់អ្នកទោសជាច្រើន ដែលត្រូវបញ្ជូនមកពីមន្ទីរស-២១ ដែលមកពីការចាប់ខ្លួនជាទ្រង់ទ្រាយធំ ។

២៥៤៖ ការសម្លាប់ក្នុងទ្រង់ទ្រាយធំបានកើតឡើងតាមការបញ្ជាដែល ឌុច បានទទួលនិងបានបញ្ជូនបន្តទៅឲ្យអ្នកក្រោមបង្គាប់ធ្វើ ដោយគ្មានការសួរចម្លើយឡើង ។

២៥៤(ក)៖ នៅលើបញ្ជីអ្នកទោសមួយ ឌុច បានចារផ្ទាល់ដៃថា ពូម៉េង វាយចោលឲ្យម៉ដ្ឋ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ ។ យល់ព្រម ។

នៅក្នុងបញ្ជីមួយទៀត នៅចំណុច(ខ) នៅលើបញ្ជីអ្នកទោសមួយផ្សេងទៀត ដែលមានឈ្មោះអ្នកទោសចំនួន២៩នាក់ ឌុច បានបញ្ជាក់ថា ស្មើសួរបួននាក់ ក្រៅពីនោះវាយចោល ។

២៥២(គ)៖ ត្រូវបានឯកភាព ។ នៅខែធ្នូឆ្នាំ១៩៧៨ មានអ្នកទោសប្រហែលជា៣០០នាក់ មកពីភូមិភាគបូព៌ា ដែលត្រូវបានចោទប្រកាន់ថា បះបោរប្រឆាំង ត្រូវបានបញ្ជូនឆ្ពោះទៅជើងឯក ដើម្បីសម្លាប់ ។ ឯកភាព ។

[១៦:០៣:៥៣]

២៥៤(ឃ)៖ នៅថ្ងៃទី២ ឬទី៣ នៃខែមករា ឆ្នាំ១៩៧៩ នួន ជា បានបញ្ជា ឌុច ឲ្យកម្ទេចអ្នកទោសទាំងអស់នៅស-២១ ។ មានមនុស្សប្រហែលជា២០០នាក់ ដែលជាជនជាតិខ្មែរ និងជនជាតិវៀតណាមត្រូវបានគេបញ្ជូនទៅជើងឯក ហើយសម្លាប់ចោល ។

នៅក្រោមចំណងជើងថា ការសម្លាប់នៅជើងឯកអង្គហេតុដូចខាងក្រោមនេះ គឺមិនមានការតវ៉ា។

កថាខណ្ឌ២៥៤ មនុស្សរាប់ពាន់អ្នករួមមានបុរស ស្ត្រី និងកុមារត្រូវបានសម្លាប់ និងកប់នៅជើងឯក ។

កថាខណ្ឌ២៤៨ អ្នកទោសត្រូវបានដឹកតាមឡានទៅជើងឯក២ ឬ ៣ដងក្នុងមួយខែ ។

កថាខណ្ឌ២៤៨(ក) ឡានដែល X បានដឹកទៅជើងឯកមានអ្នកទោសពី៣០ទៅ៤០នាក់ក្នុងមួយឡាន ។

កថាខណ្ឌ ២៤៨(ខ)អ្នកទោសត្រូវបានប្រាប់ថា គេដឹកប្តូរទៅផ្ទះថ្មីដើម្បីកុំឲ្យអ្នកទោសស្រែកនៅពេលដឹកជញ្ជូន ។

កថាខណ្ឌ២៤៨(គ)៖ នៅក្នុងឡានអ្នកទោសត្រូវបានដាក់ខ្នោះដៃនិងចងមុខ ។

កថាខណ្ឌខ២៤៨(ឃ)៖ នៅពេលធ្វើដំណើរអ្នកយាមពីរនាក់នៅផ្នែកខាងក្រោយឡានដើម្បីកុំឲ្យអ្នកទោសអាចលោតចេញពីឡានបាន ។

កថាខណ្ឌ២៤៩៖ មានអ្នកយាមពីរ-បីនាក់ យាមប្រចាំការនៅជើងឯកជាទៀងទាត់ ។ នៅពេលបានជួបជាមួយនឹងអ្នកយាមតាមការដឹកជញ្ជូន មានអ្នកយាមច្រើនរហូតដល់ដប់នាក់ ដែលមានវត្តមានសម្រាប់ធ្វើការសម្លាប់ ។

២៥០៖ ក្រុមអ្នកសម្លាប់មានបីក្រុម កងពិសេស កង X ហើយនិងកង Y ។ អ្នកទោសត្រូវបាននាំចេញទៅក្រៅម្តងមួយៗ ដោយគេនិយាយថាទៅផ្ទះមួយផ្សេងទៀត ។ X បានឈរនៅខាងក្រៅរណ្តៅ ហើយកត់ឈ្មោះអ្នកទោសនៅក្នុងបញ្ជីមុនពេលដែលពួកគេត្រូវបាននាំឆ្ពោះទៅកាន់រណ្តៅដើម្បីសម្លាប់។ អ្នកទោសត្រូវបានគេសម្លាប់ដោយប្រើដំបងដែក ដែកភ្ជួរទេះ និងបំពងទីប ដោយវាយត្រង់កញ្ចឹងក ។

កថាខណ្ឌ២៥១(ច)៖ បន្ទាប់មកទៀតអ្នកទោសត្រូវបានធាក់ទម្លាក់ទៅក្នុងរណ្តៅបន្ទាប់ពីត្រូវបានដោះខ្នោះដៃចេញ ។ ចំណុច(ឆ) បន្ទាប់ពីខ្លួនអ្នកទោសធ្លាក់ទៅក្នុងរណ្តៅ អ្នកយាមវះពោះឬអារ-ក ។

[១៦:០៦:២០]

ការសម្លាប់ជាទ្រង់ទ្រាយធំជាច្រើនបានកើតឡើងនៅជើងឯក ។ នៅក្រោមចំណងជើងថា ការសម្លាប់នៅជើងឯក នេះជាអង្គហេតុដែលបានយល់ព្រមនិងមិនតវ៉ា ។ ខ្ញុំសូមឲ្យមេធាវីផ្តល់ការបញ្ជាក់។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព! មេធាវីការពារ គឺថាជនជាប់ចោទគឺបានផ្តល់ការឯកភាព គឺមិនតវ៉ាទៅនឹងអង្គហេតុដែលសហព្រះរាជអាជ្ញា លោកទើបតែបានអានឲ្យស្តាប់នៅពេលនេះ ។

គឺមានបញ្ហាក្នុងការបកប្រែមួយ ហើយថា នៅក្នុងអត្ថបទខ្មែរបានចង្អុលបង្ហាញច្បាស់ថា គឺថា មិនតវ៉ានៅក្នុងកថាខណ្ឌ២៥១.(ឆ) គួរតែពិនិត្យការបកប្រែ គឺ២៥១នេះ គឺថាមិនបានអានទេ ។ ប៉ុន្តែ បើពិនិត្យមើលទៅនៅក្នុងអត្ថបទបកប្រែខ្មែរនោះបានចង្អុលបង្ហាញថា គឺថាមិនយល់ព្រម ។ អ៊ីចឹងគឺថា ២៥១(ឆ) ដើម្បីកំណត់ត្រាដល់ប្រតិចារឹកនោះ ខ្ញុំសូមបញ្ជាក់ថា កថាខណ្ឌនៃ២៥១(ឆ) មិនមែនជាកម្មវត្ថុនៃការឯកភាពនោះទេ ។ អ៊ីចឹងហើយត្រូវធ្វើកំណត់ត្រា ប៉ុន្តែគឺថានៅក្នុងបកប្រែត្រូវបានដាក់បញ្ចូលនោះផងដែរ ។

**លោក រ៉ូបឺត ពើទីត៖**

សូមអរគុណលោកប្រធាន នៅទីបញ្ចប់នេះ ក្រោមចំណងជើងថា "ការសម្លាប់នៅទួលស្លែង" ។ អង្គហេតុដូចខាងក្រោយនេះត្រូវបានយល់ព្រម ។

កថាខណ្ឌ២៥៥ នៅពេលដែលជើងឯកត្រូវបានប្រើប្រាស់ជាកន្លែងពិឃាតដ៏សំខាន់ក៏ដោយ ក៏អ្នកទោសសំខាន់ៗមួយចំនួនដូចជា កុយ ធួន, វ៉ន ដូចជា X, Y, Z និង S នៅតែត្រូវបានសម្លាប់នៅបរិវេណទួលស្លែង ឬនៅកន្លែងជិតខាងនោះ ។

២៥៧៖ តាមការណែនាំរបស់ថ្នាក់លើ ។ យល់ព្រម ។

កថាខណ្ឌ២៥៧៖ តាមការសំណើរបស់ថ្នាក់លើ បន្ទាប់ពីការសម្លាប់ ឌុច បានឲ្យគេថតរូបសាកសពអ្នកទោសសំខាន់ៗរួមមាន លី ប៉ែល, វ៉ន វេត ហើយនិង ហុក ។ គោលបំណងនៃការថតរូបនេះ គឺដើម្បីផ្តល់ភស្តុតាងថា បញ្ជាក់ថា អ្នកទោសទាំងនេះមិនត្រូវបានដោះលែង ឬត្រូវបានគេចខ្លួន ។

[១៦:១០:៣០]

អង្គដែលបានឯកភាព២៥៨៖ នៅក្នុងឆ្នាំ១៩៧៨ មានជនបរទេសចំនួន៤នាក់ ។ សូមអភ័យទោសខ្ញុំសូមដកមកវិញ-- ដកពាក្យមកវិញ ។

អង្គហេតុដូចខាងក្រោមនេះត្រូវបានយល់ព្រម២៦៤នេះ ។ យុទ្ធជនដែលមកពីកងឃោធាមួយត្រូវបាន-- មានឈ្មោះថា យ-៨ ក៏ត្រូវបានគេចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរស-២១ ត្រូវបានសម្លាប់ដោយអ្នកសួរចម្លើយឈ្មោះ ណាន ដោយប្រើដំពុះទុង ។ សាកសពរបស់ពួកគេទាំងនោះហើយ ដែលនៅសល់លើគ្រែនៅស-២១ ដែលទាហានវៀតណាបានប្រទះឃើញនៅពេលដែលគេមកដល់ស-២១ ។

កថាខណ្ឌដែលមិនតវ៉ា ២៥៦៖ រណ្តៅសាកសពរួមមានជាច្រើននៅក្នុង និងជុំវិញបរិវេណទួលស្លែង ។

កថាខណ្ឌ២៥៩(ខ)៖ X ត្រូវបានទទួលបញ្ជាដោយ Y ចំនួននេះពីរលើកឲ្យធ្វើបញ្ជីឈ្មោះអ្នកទោសដែលត្រូវបូមឈាម ។ ចំណុច(ឃ) អ្នកទោសនៅស-២១ ដែលត្រូវគេធ្វើតាមវិធីដូច្នេះ ត្រូវបានគេបូមឈាមក្នុងម្នាក់ៗពី៤ទៅ៥ប្លោក ដែលធ្វើឲ្យអ្នកទាំងនោះលែងដឹងខ្លួន ។ ចំណុច(ង) អ្នកទោសតែងតែស្លាប់នៅពេលមួយក្រោយពេលដែលបូមឈាម ហើយមានឡានចូលមកដឹកសាកសពទៅជើងឯក ។

២៦០៖ កូនៗរបស់អ្នកទោសនៅស-២១ ត្រូវបានគេបំបែកចេញពីឪពុកម្តាយ សម្លាប់ និងកប់

នៅទីតាំងខាងជើងគុក ។

នេះជាអង្គហេតុដែលបានលើកឡើងឋិតនៅក្រោមចំណងជើងថា "ការសម្លាប់នៅទួលស្លែង" ហើយដែលបានឯកភាព ហើយមិនតវ៉ា ។ ខ្ញុំសូមឲ្យមេធាវីបញ្ជាក់ពីការ ឯកភាព ឬមិនឯកភាព ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារសូមបញ្ជាក់ថា ឌុច បានទទួលស្គាល់ថា អង្គហេតុនោះ ដែលបានអានដោយសហព្រះរាជអាជ្ញាដែលពាក់ព័ន្ធទៅនឹងការសម្លាប់ ។ ដែលថា ចំណុចមួយដែលគាត់បានឯកភាព ឬក៏ចំណុចដែលគាត់មិនតវ៉ានោះក្តី ហើយប្រហែលជាសុំឲ្យមានសេចក្តីបញ្ជាក់មួយទៀតនៅក្នុងនេះ ។ ដែលថាជនជាប់ចោទសុំស្នើថា ការប្រើស-២១ នោះ គឺមិនមែនត្រូវប្រើពាក្យថាទួលស្លែងទេ ។ ដែលមិនបានទទួលស្គាល់ថា ពាក្យនោះគឺបានប្រើឡើងក្រោយពីអង្គហេតុកើតឡើង ។ អ្វីដែលគាត់ព្រួយបារម្ភនោះ គឺគាត់ជាប្រធានស-២១ ។ រីឯទួលស្លែង ដែលជាពាក្យដែលផ្តល់ឈ្មោះក្រោយពីកងវៀតណាមចូលមកដល់ទេ ។

[១៦:១៣:៤៨]

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន ។ ដើម្បីសូមបញ្ជាក់ថា គឺថាអង្គហេតុនោះគឺថាការលើកឡើងនេះគឺត្រឹមត្រូវ ហើយខ្ញុំពិនិត្យមើលអង្គហេតុបីដែលបានយល់ព្រម និងបញ្ជាក់ថា អង្គហេតុនេះបានយល់ព្រម ហើយដាក់បញ្ចូលនៅក្នុង២០១(ក), ២១១, ហើយនិង២៦២ ។ ហើយខ្ញុំបានអានហើយ ហើយខ្ញុំភ្លេចមិនបានថា បានឯកភាព ឬក៏យល់ព្រម ។ ដូច្នេះហើយខ្ញុំបានបញ្ចប់ ហើយបានអានអង្គហេតុដែលបានលើកឡើងដែលមានយល់ព្រម ឬក៏មិនតវ៉ា ដោយសហព្រះរាជអាជ្ញា ។ ហើយនិងមេធាវីបានផ្តល់ការយល់ព្រម ហើយខ្ញុំសូមអរគុណចំពោះសេចក្តីអំណត់ និងធ្វើការងាររួមគ្នានេះ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការប្រព្រឹត្តិទៅនៃសវនាការថ្ងៃនេះក៏ដល់ទីបញ្ចប់ត្រូវឈប់សម្រាកហើយ អង្គជម្រះសូមប្រកាសផ្អាកសវនាការនៅថ្ងៃនេះ ត្រឹមនេះ ។ សវនាការនឹងបន្តនៅព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។

អង្គជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និង

បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សវនាការវិញនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំហិត ។ សូមជម្រាបដល់អ្នកចូលរួមនៅក្នុងនីតិវិធីនិងសាធារណជន សូមអញ្ជើញចូលមកកាន់សាលសវនាការបានមុនម៉ោងប្រាំបួនព្រឹកដូចកាលបរិច្ឆេទខាងលើនេះ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១៦នាទី]*